01678767

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារ D384/7

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦២)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 09 / 2021
ម៉ោង (Time/Heure): 12:43
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ៖ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១
ភាសាដើម៖ ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

**សហព្រះរាជអាជ្ញា**

ជា លាង
Brenda J. HOLLIS

**សហមេធាវីការពារក្តី យឹម ទិត្យ:**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

# មាតិកា

I. ប្រវត្តិនីតិវិធី ..... 2

II. បទដ្ឋាននៃការត្រួតពិនិត្យឡើងវិញ ..... 16

III. ភាពអាចទទួលយកបាន ..... 17

IV. គោលការណ៍គតិយុត្តិនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ..... 18

V. អង្គសេចក្តី ..... 23

VI. សេចក្តីសម្រេច ..... 24

VII. យោបល់របស់ចៅក្រមប្រាក់ គឹមសាន ចៅក្រមន័យ ថុល និងចៅក្រម ហួត វុទ្ធី ..... 25

VIII. យោបល់របស់ចៅក្រម KANG JIN BAIK និងចៅក្រម OLIVIER BEAUVALLET .. 26

ក. មូលដ្ឋានទី ១÷ ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសម្រេចថា លក្ខខណ្ឌតម្រូវពីទំនាក់ទំនងសម្រាប់សហឧក្រិដ្ឋកម្មរួម ក (គោលនយោបាយ ប.ក.ក ទាំង ៤) អនុលោមតាមវិធាន ២៣ស្ទួន(១)(ខ) ត្រូវបានបំពេញដោយជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅភូមិភាគពាយ័ព្យតែប៉ុណ្ណោះ ..... 26

១. អំណះអំណាង ..... 26

២. ការពិភាក្សា ..... 34

ក. ច្បាប់ជាធរមាន ..... 34

ខ. មូលដ្ឋានទី ១(១) ..... 35

គ. មូលដ្ឋានទី១ (២) ..... 40

ឃ. មូលដ្ឋានទី១ (៣) ..... 46

ខ. មូលដ្ឋានទី២÷ ការចោទប្រកាន់ពីការខកខានមិនបានពិចារណាអង្គហេតុនានាដែលបានដកចេញ អនុលោមតាមវិធាន៦៦ ស្ទួននៃវិធានផ្ទៃក្នុង នៅក្នុងការសម្រេចអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ..... 50

01678769



១.អំណះអំណាង ....................................................................................................50

២. ការពិភាក្សា ....................................................................................................53

**គ. មូលដ្ឋានទី៣៖ ការចោទប្រកាន់ពីការមិនបានផ្តល់សេចក្តីសម្រេចដោយមានសំអាងហេតុ សម្រាប់ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ....................................59**

១. អំណះអំណាង ....................................................................................................59

២. ការពិភាក្សា ....................................................................................................61

**ឃ. មូលដ្ឋានទី៤៖ ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ និងកំហុសអង្គហេតុចំពោះការមិនបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ ....................................................................69**

១. អំណះអំណាង ....................................................................................................69

២. ការពិភាក្សា ....................................................................................................72

**ង. មូលដ្ឋានទី ៥៖ ការចោទប្រកាន់ពីកំហុសឆ្គងត្រង់ចំណុចថា ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២ និងសំណុំរឿង ០០៤/០១ ពីសំណុំរឿង០០៤ មិនគួរកម្រិតទៅលើភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ ............................................................80**

១. អំណះអំណាង ....................................................................................................80

២. ការពិភាក្សា ....................................................................................................83

**សេចក្តីសន្និដ្ឋាន........................................................................................................*88***

01678770

សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦២)

ឯកសារលេខ D384/7

# តារាងអក្សរកាត់

| ពាក្យ | ពាក្យចំពេញ/អក្សរកាត់ |
|---|---|
| កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ | កិច្ចព្រមព្រៀង អ.វ.ត.ក |
| ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | ច្បាប់ អ.វ.ត.ក |
| វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ដែលបានធ្វើវិសោធនកម្ម) | វិធានផ្ទៃក្នុង |
| តុលាការព្រហ្មទណ្ឌអន្តរជាតិ | តុលាការ ICC |
| សហឧក្រិដ្ឋកម្មរួម | JCE |
| កម្ពុជាប្រជាធិបតេយ្យ | DK |
| បក្សកុម្មុយនីស្ដកម្ពុជា | ប.ក.ក |
| អង្គភាពគាំពារជនរងគ្រោះ | VSS |
| ទម្រង់បែបបទព័ត៌មានជនរងគ្រោះ | VIF |
| ទម្រង់បែបបទព័ត៌មានបន្ថែមរបស់ជនរងគ្រោះ | SIF |

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ស្ដីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី" ដែលបានដាក់ដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវី") នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ("បណ្ដឹងឧទ្ធរណ៍" ឬ "បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី")[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានបញ្ជូនការខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង មកអង្គបុរេជំនុំជម្រះ ដោយរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិ បានខ្វែងយោបល់លើការកាត់សេចក្ដី ឧក្រិដ្ឋកម្មថ្មីដែលបានកំណត់ នៅក្នុងដីកាសន្និដ្ឋានបន្ថែម[2]។ នៅថ្ងៃដដែលនេះដែរ សហព្រះរាជអាជ្ញាអន្តរជាតិ បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ដោយស្នើសុំរកការបើកកិច្ចស៊ើបសួរប្រឆាំង យឹម ទិត្យ ជាផ្នែកមួយនៃសំណុំរឿង ០០៤ ដោយរួមមានការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៦ ("ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦")[3]។

2. នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ដោយមិនអាចរកបានសម្លេងភាគច្រើនលើសលប់ នៅក្នុងការធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នានេះ អង្គបុរេជំនុំជម្រះបានបង្គាប់ទៅសហព្រះរាជ

---

[1] សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤") បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ដែលបានជូនដំណឹងនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០ ឯកសារ D384/5 ("បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5)")។

[2] ការខ្វែងយោបល់ ០០១/១៨-១១-២០០៨-អវតក/អបជ សេចក្ដីប្រកាសជាលាយលក្ខណ៍អក្សរ របស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីអង្គហេតុនិងសំអាងហេតុ នៃការខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ Doc. No. 1។

[3] សំណុំរឿង ០០៤/២០-១១-២០០៨/អវតក/កសចស ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។

អាជ្ញាអន្តរជាតិ ឱ្យបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី ទៅសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង[4]។

3. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ដោយស្នើសហចៅក្រមស៊ើបអង្កេត ឱ្យផ្តួចផ្តើមការស៊ើបអង្កេតតាមផ្លូវតុលាការ ប្រឆាំង យឹម ទិត្យ ជាផ្នែកមួយនៃសំណុំរឿង ០០៤[5]។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនបួន ពាក់ព័ន្ធនឹង យឹម ទិត្យ ដើម្បីពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង[6]។

4. ចាប់តាំងពីពេលចាប់ផ្តើមការស៊ើបសួរ មានមនុស្សចំនួន ២.០១៤ នាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤[7]។

---

[4] ការខ្វែងយោបល់ ០០១/១៨-១១-២០០៨-អវតក/អបជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ៤៥។

[5] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។

[6] សំណុំរឿង ០០៤ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានា នៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D65 (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ (D65)”)។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហឹង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D191 (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ (ឯកសារ D191)”)។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹង ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តតាមាក់ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ D254/1។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D272/1 (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន (D272/1)”)។

[7] សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 (“ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384)”) កថាខណ្ឌ ២។

5. នៅក្នុងអំឡុងពេលស៊ើបអង្កេត លើសំណុំរឿង០០៤ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានទទួលព័ត៌មានថា មានអ្នកដាក់ពាក្យសុំនៅក្នុងសំណុំរឿង ០០៤ ចំនួន ៤៧ នាក់ បានស្លាប់[8]។ សិទ្ធិវ័ន្តរបស់អ្នកដាក់ពាក្យសុំមួយរូប ដែលបានបាត់បង់ជីវិត បានបង្ហាញចេតនាបន្តបណ្តឹងក្នុងនាមអ្នកស្លាប់[9]។ អ្នកដាក់ពាក្យសុំបីនាក់ បានស្នើសុំដកពាក្យសុំរបស់ខ្លួនវិញ[10]។

6. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត បានប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert HAMILL និងលោកស្រី សេង ចាន់ធារី មិនអាចទទួលយកបាន[11]។ អ្នកដាក់ពាក្យសុំតាំងខ្លួនទាំងនេះបានប្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចស្តីពីភាពមិនអាចទទួលយកបាននេះ[12]។ នៅថ្ងៃទី១៤ និងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួន ពាក់ព័ន្ធបណ្តឹងឧទ្ធរណ៍របស់អ្នកដាក់ពាក្យសុំទាំងពីររូប ដោយប្រកាសថា អង្គជំនុំជម្រះមិនអាចទទួលបាន សម្លេងភាគច្រើនលើសលប់តាមការតម្រូវ ដើម្បី

[8] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៨។

[9] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៨ *យោងទៅ* សំណុំរឿង ០០៤ លិខិតរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធ "សំណើរបស់សិទ្ធិវ័ន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព ដើម្បីបន្តការទាមទារសំណងរដ្ឋប្បវេណី ឯកសារ D5/641" ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៦ ឯកសារ D5/641/3។

[10] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៨ *យោងទៅ* សំណុំរឿង ០០៤ លិខិតផ្ញើរជូនមេធាវី ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ ឯកសារ D5/1114/3។ លិខិតផ្ញើរជូនមេធាវី ពាក់ព័ន្ធការដកខ្លួនរបស់លោក ឌី ដានី ពីសំណុំរឿង០០៣ សំណុំរឿង ០០៤ និង០០៤/២ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ ឯកសារ D5/1921/3។ សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/១") ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D307 កថាខណ្ឌ ៧។

[11] សំណុំរឿង ០០៤ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert HAMILL ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D5/2/3។ សំណុំរឿង ០០៤ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D5/1/3។

[12] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ស្តីពីភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ឯកសារ D5/1/4/1។ សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ស្តីពីភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill (D11/2/3) (សំណុំរឿង ០០៣ និង ០០៤) ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១ ឯកសារ D5/2/4/2។

ចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ឡើយ[13]។ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ លោកស្រី សេង ចាន់ធារី បានដកពាក្យសុំតាំងខ្លួន ចេញពីសំណុំរឿង ០០៤ ដែលការស្នើសុំនេះត្រូវបានទទួលស្គាល់ដោយក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត តាមរយៈលិខិតចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤[14]។ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ លោក Robert HAMILL បានស្នើដល់សហចៅក្រមស៊ើបអង្កេត ឱ្យធ្វើការពិចារណាឡើងវិញលើដីកាសម្រេចរបស់ពួកគាត់[15]។ សហចៅក្រមស៊ើបអង្កេតមិនបានចេញដីកាសម្រេចថ្មី លើភាពអាចទទួលយកបានរបស់លោក Robert HAMILL ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ នៅពេលនោះ[16]។

7. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្តីប្រកាសព័ត៌មានដោយជូនដំណឹងដល់សាធារណជន និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អំពី

---

[13] សំណុំរឿង ០០៤ (អបជ ០២) សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងជំទាស់នឹងដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D5/2/4/3 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់លោក Robert HAMILL (D5/2/4/3)")។ សំណុំរឿង ០០៤ (អបជ ០១) សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងជំទាស់នឹងដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី សេង ចាន់ធារី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D5/1/4/2 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់លោកស្រី សេង ចាន់ធារី (D5/1/4/2)")។

[14] សំណុំរឿង ០០៤ សំណើសុំដកពាក្យជាអ្នកដាក់ពាក្យបណ្តឹងលេខ 11-VSS-00001 សេង ចាន់ធារី ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ ឯកសារ D5/1/5។ សំណុំរឿង ០០៤ លិខិតរបស់ក្រឡាបញ្ជី ក.ស.ច.ស ផ្ញើរជូនមេធាវី ជួង ជូងី ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D5/1/6។ លិខិតរបស់ក្រឡាបញ្ជី ក.ស.ច.ស ផ្ញើរជូនមេធាវី សំ សុគង់ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D5/1/7។ លិខិតរបស់ក្រឡាបញ្ជី ក.ស.ច.ស ផ្ញើរជូនមេធាវី Emmanuel Jacomy ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D5/1/8។ *សូមមើលផងដែរ* ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៥។

[15] សំណុំរឿង ០០៤ សំណើសុំឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាសាជាថ្មី ចំពោះការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert HAMILL (D11/2/3) (សំណុំរឿង ០០៣ និង ០០៤) ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ ឯកសារ D5/2/5។

[16] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៦។

ទីតាំងឧក្រិដ្ឋកម្ម ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ក្នុងសំណុំរឿង ០០៤[17]។

8. នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានទទួលយកអ្នកដាក់ពាក្យសុំចំនួន ៣០ នាក់ ជាដើមបណ្ដឹងរដ្ឋប្បវេណី[18]។

9. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធការស៊ើបអង្កេតបន្ថែមនៅក្នុងសំណុំរឿង ០០៤ នោះ បានចេញសេចក្ដីប្រកាសមួយ ដោយជូនដំណឹងដល់សាធារណជន អំពីទីតាំងឧក្រិដ្ឋកម្មបន្ថែមទាំង១៤ ដែលស្ថិតក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤[19]។

10. សំណុំរឿងរបស់ យឹម ទិត្យ ជាកម្មវត្ថុនៃការខ្វែងយោបល់សម្ងាត់ជាច្រើន រវាងសហចៅក្រមស៊ើបអង្កេត (បានចុះបញ្ជីនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និងថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩)[20]។ ការខ្វែងយោបល់ទាំងអស់នេះ មិនត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះឡើយ។

11. នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ដំណាលគ្នានឹងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់ខ្លួននៅថ្ងៃតែមួយនោះ[21] សហព្រះរាជអាជ្ញាអន្តរជាតិបានប្រកាសថា គាត់បានស្នើ

---

[17] សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្ដីប្រកាសព័ត៌មានរបស់ សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ (០០៤/០៧-០៩-២០០៩/អវតក/កសចស)" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/press-release-co-investigating-judges-regarding-civil-parties-case-004។

[18] *សូមមើល* ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៧។

[19] សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្ដីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធទីតាំងឧក្រិដ្ឋកម្មបន្ថែមក្នុងសំណុំរឿង ០០៤" ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/articles/statement-international-co-investigating-judge-regarding-additional-crime-sites-case-file។

[20] *សូមមើល* សំណុំរឿង ០០៤ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382)"), កថាខណ្ឌ ៣, ៧, ២១។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381 ("ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D381)") កថាខណ្ឌ ១៣។

[21] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ (ឯកសារ D191)។

សុំឱ្យមានការស៊ើបសួរ អំពីអំពើហិង្សាលើយេនឌ័រឬផ្លូវភេទ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាផ្នែកមួយនៃសំណុំរឿង ០០៤[22]។ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ យឹម ទិត្យ ពីបទរំលោភបំពានទៅលើមាត្រា ៥០១ និង៥០៦ (អំពើមនុស្សឃាតដោយចេតនា) នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[23]។ នៅថ្ងៃដដែលនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីប្រកាសព័ត៌មាន ពាក់ព័ន្ធបទចោទទាំងអស់នេះ[24]។ ទាំង យឹម ទិត្យ និងសហមេធាវីការពារក្តីរបស់គាត់ សម្រេចមិនចេញសេចក្តីប្រកាសឡើយ នៅពេលបង្ហាញខ្លួនជាលើកដំបូង[25]។

12. នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ តាមរយៈសំណើសុំមតិយោបល់ពាក់ព័ន្ធអង្គហេតុដែលបានចោទប្រកាន់ ហើយមិនត្រូវធ្វើការស៊ើបអង្កេតបន្តទៀតនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងដល់ភាគីនានាថា គាត់មានចេតនាដកចេញនូវអង្គហេតុមួយចំនួន ពីការស៊ើបអង្កេត ហើយស្នើសុំមតិរបស់ភាគីនានាលើបញ្ហានេះ[26]។ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ បន្ទាប់ពីបានទទួលមតិយោបល់ពីសហមេធាវីការពារក្តី យឹម ទិត្យ និងសហព្រះរាជអាជ្ញាអន្តរជាតិរួចហើយនោះ[27] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងដល់ភាគីថា អង្គហេតុដែលបានចោទ

[22] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក “សេចក្តីប្រកាសរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ Nicholas KOUMJIAN ពាក់ព័ន្ធសំណុំរឿង ០០៤” ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/node/30196។

[23] សំណុំរឿង ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D281 (“កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ (D281)”)។

[24] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក “សេចក្តីប្រកាសព័ត៌មានរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធសំណុំរឿង ០០៤” ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/node/35023។

[25] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ (D281)។

[26] សំណុំរឿង ០០៤ សំណើសុំមតិយោបល់ ទាក់ទងនឹងការចោទប្រកាន់ អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ D302 (“សំណើសុំមតិយោបល់ (D302)”)។

[27] សំណុំរឿង ០០៤ សារណារបស់ យឹម ទិត្យ ទាក់ទងនឹងការចោទប្រកាន់ អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតបន្ថែមទៀត ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D302/1។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹង

ប្រកាន់មួយចំនួន ជាកម្រិតបឋម (*prima facie*) ហាក់ដូចជាកម្មវត្ថុនៃវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង ហើយអង្គហេតុដែលបានចោទប្រកាន់មួយចំនួនផ្សេងទៀត ហាក់ដូចជាកម្មវត្ថុនៃការលើកលែងចោទប្រកាន់ អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង[28]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្អាកជាបណ្ដោះអាសន្ន នូវការស៊ើបអង្កេតលើអង្គហេតុទាំងអស់នេះ ហើយបានជូនដំណឹងដល់ភាគីនានាថា សេចក្ដីសម្រេចស្ថាពរ លើការសម្រេចលើកលែងចោទប្រកាន់ដោយផ្អែកអនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ឬការអនុវត្តវិធាន ៦៦ស្ទួននៃវិធានផ្ទៃក្នុង នឹងត្រូវធ្វើឡើងនៅពេលបិទបញ្ចប់ការស៊ើបអង្កេត[29]។

13. នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ និងថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្គាប់ឲ្យមានអ្នកតំណាងតាមផ្លូវច្បាប់ សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ក្នុងសំណុំរឿង ០០៤[30]។

14. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ និងថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្ដីជូនដំណឹងបន្ថែម អំពីការផ្អាកបណ្ដោះអាសន្ន និងជូនដំណឹងដល់ភាគីនានា អំពីចេតនារបស់ខ្លួន ក្នុងការផ្អាកកិច្ចស៊ើបសួរ ទៅលើអង្គហេតុបន្ថែមដែលជាកម្រិតបឋមហាក់ដូចជាកម្មវត្ថុ នៃវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង[31]។

---

សំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សុំយោបល់ទាក់ទងនឹងការចោទប្រកាន់ ពីអង្គហេតុដែលមិនស៊ើបអង្កេតបន្ថែម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ឯកសារ D302/2។

[28] សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ ទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D302/3 (“សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ (D302/3)”)កថាខណ្ឌ ៨-១៦។

[29] សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ (D302/3) កថាខណ្ឌ ៣៤-៣៦។

[30] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ១០។

[31] សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្ដោះអាសន្ន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ ឯកសារ D342 (“សេចក្ដីជូនដំណឹងអំពីគោលបំណងដាក់បន្ថែម និងការផ្អាកកិច្ចស៊ើបសួរ (D342)”)។ សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរលើអង្គហេតុពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ឯកសារ D349 (“សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ (ទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង) (D349)”)។ សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងយោងតាមវិធាន ៦៦ ស្ទួន (២) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D354 (“សេចក្ដីជូនដំណឹងតាមវិធាន ៦៦*ស្ទួន*(២) (D354)”)។

01678778



15. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមរយៈដីកាសម្រេចតាមផ្លូវតុលាការ បានកែសម្រួលបទចោទប្រឆាំង យឹម ទិត្យ ហើយបន្ថែមទម្រង់នៃការទទួលខុសត្រូវពាក់ព័ន្ធឧក្រិដ្ឋកម្មដែលបានចោទប្រកាន់កន្លងមក នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥[32]។

16. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានចោលរាល់សំណើសុំវិធានការការពារ របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤[33]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប បានដាក់ពាក្យស្នើសុំវិធានការការពារ[34]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានចេញសេចក្តីសម្រេចលើសំណើនេះឡើយ នៅពេលនេះ[35]។

17. នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីនានា អំពីការបិទបញ្ចប់ការស៊ើបអង្កេត តាមផ្លូវតុលាការទៅលើ យឹម ទិត្យ អនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង[36]។ នៅថ្ងៃដដែលនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញនូវអង្គហេតុដែលបានចោទប្រកាន់មួយ អនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង[37]។

---

[32] សំណុំរឿង ០០៤ ដីកាសម្រេចកែប្រែបទចោទប្រឆាំង យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ឯកសារ D350។ សំណុំរឿង ០០៤ ឧបសម្ព័ន្ធ៖ សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ឯកសារ D350.1។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងអំពីគោលបំណងដាក់បន្ថែម និងការផ្អាកកិច្ចស៊ើបសួរ (D342)។

[33] សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើសុំវិធានការការពារ របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ឯកសារ D353។

[34] សំណុំរឿង ០០៤ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស៊ុន ឈើវហុង ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ (ដាក់នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧) ឯកសារ D5/2008។

[35] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ១១។

[36] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D358 ("សេចក្តីជូនដំណឹងលើកទីមួយតាមវិធាន ៦៦(១) (D358)")។

[37] សំណុំរឿង ០០៤ ដីកាសម្រេចកាត់បន្ថយវិសាលភាព នៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D359 ("ដីកាសម្រេចតាមវិធាន ៦៦ស្ទួន (D359)")។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងអំពីការផ្អាក

18. នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្ដីជូនដំណឹងលើកទីពីស្ដីពីការបិទបញ្ចប់ការស៊ើបសួរតាមផ្លូវតុលាការប្រឆាំង យឹម ទិត្យ[38]។

19. នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេត បានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដោយស្នើសុំដល់សហព្រះរាជអាជ្ញា ឱ្យដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ក្នុងរយៈពេលបីខែ[39]។

20. នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរ ស្នើសុំលើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំង យឹម ទិត្យ[40] ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ បានស្នើសុំចោទប្រកាន់ យឹម ទិត្យ បញ្ជូនទៅជំនុំជម្រះ (រួមគ្នាហៅថា "ដីកាសន្និដ្ឋានស្ថាពរ")[41]។ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ សហមេធាវី យឹម ទិត្យ បានដាក់ចម្លើយតបចំពោះដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ដែលស្នើសុំលើកលែងការចោទប្រកាន់ប្រឆាំង យឹម ទិត្យ[42]។

21. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា។ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ("ដីកាសម្រេចលើកលែងចោទប្រកាន់") ដោយលើកលែងរាល់បទចោទទាំងអស់ប្រឆាំង យឹម

---

កិច្ចស៊ើបសួរ (D302/3)។ សេចក្ដីជូនដំណឹងអំពីគោលបំណងដាក់បន្ថែម និងការផ្អាកកិច្ចស៊ើបសួរ (D342)។ សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ (ទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង) (D349)។ សេចក្ដីជូនដំណឹងតាមវិធាន ៦៦*ស្ទួន*(២) (D354)។

[38] សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងលើកទីពីរអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D368 ("សេចក្ដីជូនដំណឹងលើកទីពីរតាមវិធាន ៦៦(១) (D368)")។

[39] សំណុំរឿង ០០៤ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ឯកសារ D378។

[40] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ឯកសារ D378/1។

[41] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D378/2។

[42] សំណុំរឿង ០០៤ ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពរ របស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D378/5។

ទិត្យ ដោយផ្អែកលើមូលដ្ឋានថា គាត់មិនមែនជាកម្មវត្ថុនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ជា "មេដឹកនាំជាន់ខ្ពស់" ឬស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឡើយ[43]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ដោយចោទប្រកាន់ យឹម ទិត្យ បញ្ជូនគាត់ទៅជំនុំជម្រះ ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ខណៈដែលសន្និដ្ឋានថា យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ក្នុងនាមជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់ ចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម[44]។

22. នៅថ្ងៃដដែល គឺថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេច ច្រានចោលពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី ("ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមជាតិ)") ដោយច្រានចោលពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ នៅក្នុងសំណុំរឿង ០០៤ ដោយផ្អែកលើមូលដ្ឋានថា រាល់បទចោទប្រកាន់លើ យឹម ទិត្យ ត្រូវបានបដិសេធចោល ដោយសារតែមិនមានយុត្តាធិការ[45]។ ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមជាតិ) មិនបានពិនិត្យមើលជាក់លាក់ លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗឡើយ[46]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចផ្សេង លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ("ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) ដោយប្រកាសថាអាចទទួលយកបាន នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចមានក្នុងឧបសម្ព័ន្ធ ក នៃដីកាសម្រេចរបស់គាត់ និងច្រានចោលដោយមិនអាចទទួលយកបាន នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចមានក្នុងឧបសម្ព័ន្ធ

---

[43] ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D381)។

[44] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) (បន្ថែមពីលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបិទបញ្ចប់ជាផ្លូវការនូវការស៊ើបអង្កេតលើអង្គហេតុ ដែលបានដកចេញតាមដីកាសម្រេចយោងតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង ហើយបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ដោយផ្អែក ដោយលើកលែងបទចោទប្រកាន់ យឹម ទិត្យ មួយចំនួន)។

[45] សំណុំរឿង ០០៤ ដីកាសម្រេចបដិសេធ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D383 ("ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមជាតិ) (ឯកសារ D383)") កថាខណ្ឌ ១២-១៣។

[46] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមជាតិ) (ឯកសារ D383) ។

ខ នៃដីកាសម្រេចរបស់គាត់ ដែលក្នុងនោះមានលោក Robert HAMILL ផងដែរ[47]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធបន្ថែមលើសំណើសុំវិធានការការពារ ដែលបានស្នើឡើងដោយអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប[48]។

23. នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ និងថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើពីរផ្សេងគ្នា សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់បណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុងរបស់ខ្លួន ប្រឆាំងភាពមិនអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី និងស្នើសុំការអនុញ្ញាតិដាក់ឯកសារតែមួយភាសា ដោយឯកសារបកប្រែនឹងដាក់ជូនតាមក្រោយ[49]។

24. នៅថ្ងៃទី២២ ខែសីហា ឆ្នា២០១៩ អង្គបុរេជំនុំជម្រះបានអនុញ្ញាត ចំពោះសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ ដោយពន្យាកាលបរិច្ឆេទដាក់ឯកសារបន្ថែមចំនួន៣០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាភាសាខ្មែរ ដោយបង្កើនការកម្រិតកំណត់ចំនួនទំព័រ សម្រាប់សារណាបណ្តឹងឧទ្ធរណ៍ដល់ ៤៥ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង និង ៩០ទំព័រ ជាភាសាខ្មែរ ហើយអនុញ្ញាតឲ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់សារណាជាមួយភាសា គឺភាសាអង់គ្លេស ឬភាសាខ្មែរ ហើយឯកសារបកប្រែត្រូវដាក់ជូនតាមក្រោយ[50]។

---

[47] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៥០-៥១។ *សូមមើលផងដែរ* សំណុំរឿង ០០២ ឧបសម្ព័ន្ធ ខ៖ បញ្ជីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលយក ឧបសម្ព័ន្ធនៃដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384.2 (“ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (D384.2)”)។

[48] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៤៩,៥៣។

[49] សំណុំរឿង ០០៤ សំណើបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលានិងបង្កើនចំនួនទំព័រ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D384/1។ សំណុំរឿង ០០៤ សំណើបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលានិងបង្កើនចំនួនទំព័រ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ឯកសារ D384/3។

[50] សំណុំរឿង ០០៤ (អបជ ៦២) សេចក្តីសម្រេចលើសំណើបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលានិងបង្កើនចំនួនទំព័រ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន

25. ឯកសារបកប្រែជាភាសាខ្មែរនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងឯកសារបកប្រែជាភាសាអង់គ្លេស នៃដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវបានជូនដំណឹងនៅថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០១៩ និងថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩។

26. នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គបុរេជំនុំជម្រះ[51]។ នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ដែលបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយបានស្នើសុំផងដែរឱ្យច្រានចោលដីកាសម្រេចដែលរងការជំទាស់ ហើយស្នើអង្គបុរេជំនុំជម្រះ ធ្វើការពិចារណាឡើងវិញ លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធនោះ[52]។ មិនមានភាគណាមួយបានដាក់ ចម្លើយតបចំពោះបណ្តឹងឧទ្ធរណ៍នេះឡើយ។

27. នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិបានដាក់ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[53]។ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ និងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់[54]។ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ សហមេធាវី យឹម ទិត្យ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍

---

ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ ឯកសារ D384/4 ("សេចក្តីសម្រេចលើសំណើរបស់សហមេធាវី (D384/4)")។

[51] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5)។

[52] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៦៤-៦៥។

[53] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ D382/4។

[54] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/4។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/11។

ប្រឆាំង ដីកាដំណោះស្រាយទាំងពីរ[55]។ ភាគីបានដាក់សារណាបណ្ដឹងឧទ្ធរណ៍ និងចម្លើយតបនានា[56]។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុង បានសម្រេចធ្វើការសម្រេចលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំ

---

[55] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/7 & D382/9។

[56] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/4/1។ សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនិងការចេញដីកាដំណោះស្រាយចំនួនពីរក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/18 & D382/21។ សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនិងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D382/22 (ដាក់នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩)។ សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381) ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/19 (ដាក់នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩)។ សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ប្រឆាំងដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/20 (ដាក់នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩)។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D382/27 (ជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០)។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង ០០៤ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D381/25 & D382/28 (ជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០)។ សំណុំរឿង ០០៤ ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D381/26។ សំណុំរឿង ០០៤ ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ ឯកសារ D382/29។ សំណុំរឿង ០០៤ ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ ឯកសារ D381/27 & D382/30។ សំណុំរឿង ០០៤ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់គាត់ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ប្រឆាំង យឹម ទិត្យ (D381) ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ឯកសារ D381/28។

រឿង ០០៤ ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ និងបន្តដំណើរការនីតិវិធីនេះ ដោយមិនមានសវនាការផ្ទាល់មាត់[57]។

28. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយ*ក្នុងនោះ*បានសន្និដ្ឋានថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ដែលរំលោភទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[58] និងបានសន្និដ្ឋានថា អង្គជំនុំជម្រះពុំអាចរកសម្លេងភាគច្រើនលើសលប់ដើម្បីធ្វើសេចក្តីសម្រេច ផ្អែកលើសំអាងហេតុរួម លើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[59] បានទេ។ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះយល់ឃើញថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺខុសច្បាប់។ យឹម ទិត្យ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការទេ ហើយសំណុំរឿងប្រឆាំង យឹម ទិត្យ គួរតែបញ្ជូនទៅតម្កល់ទុកក្នុងបណ្ណសាររបស់ អ.វ.ត.ក[60]។ ចៅក្រមអន្តរជាតិយល់ឃើញថា ដីកាលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិត្រូវចាត់ទុកជាមោឃៈ និងបានចេញ*ហួសដែនអំណាច។* ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុលោមទៅតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងមានសុពលភាព ហើយ យឹម ទិត្យ គួរត្រូវបានបញ្ជូនទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង យោងតាមគោលការណ៍នៃការបន្តកិច្ចស៊ើបសួរ និងការចោទប្រកាន់[61]។

---

[57] សំណុំរឿង ០០៤ ដីកាសម្រេចលើសវនាការផ្ទាល់មាត់ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/41 & D382/40។

[58] សំណុំរឿង ០០៤ (អបជ ៦១) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (D381/45 & D382/43)") កថាខណ្ឌ ៨៤-១១៥។

[59] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (D381/45 & D382/43) កថាខណ្ឌ ៨៤-១១៦។

[60] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (D381/45 & D382/43) យោបល់របស់ចៅក្រមជាតិ ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៣១។

[61] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (D381/45 & D382/43) យោបល់របស់ចៅក្រមអន្តរជាតិ ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១៧៧, ៥២២-៥២៣។

## II. បទដ្ឋាននៃការត្រួតពិនិត្យឡើងវិញ

29. វិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុង តម្រូវថា ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលព្យាយាមច្រានចោលដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញថា ដីកាសម្រេចដែលរងការជំទាស់ ត្រូវបានធ្វើឡើងផ្អែកលើកំហុសអង្គហេតុ និង/ឬ កំហុសអង្គច្បាប់[62]។ អង្គបុរេជំនុំជម្រះសូមរម្លឹកថា ចំពោះបណ្តឹងឧទ្ធរណ៍កំហុសអង្គច្បាប់ដែលត្រូវបានចោទប្រកាន់ ត្រូវត្រួតពិនិត្យ *ជាថ្មី*ឡើងវិញ (*de novo*) ដើម្បីសម្រេចថា តើសេចក្តីសម្រេចអង្គច្បាប់ត្រឹមត្រូវដែរឬទេ ចំណែកកំហុសអង្គហេតុដែលត្រូវបានចោទប្រកាន់ ត្រូវត្រួតពិនិត្យតាមបទដ្ឋាននៃភាពសមហេតុផល ដើម្បីសម្រេចថា តើមានអ្នកវិនិច្ឆ័យលើអង្គហេតុដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចចំពោះអង្គហេតុដែលចោទជាបញ្ហានេះដែរឬទេ[63]។

---

[62] វិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (អបជ ៣៦) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 ("សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D269/4)") កថាខណ្ឌ ៣១។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២") (អបជ ៥៨) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកស្តាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 (សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ (D362/6)") កថាខណ្ឌ ២៨។ សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 ("សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ (D404/2/4)") កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D411/3/6 ("សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ (D411/3/6)") កថាខណ្ឌ ៣៤។

[63] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D269/4) កថាខណ្ឌ ៣១។ សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ២៨។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/២") (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី០៩ ធ្នូ ឆ្នាំ២០១៩ ឯកសារ D259/24 & D360/33 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D259/24 & D360/33)") យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ

## III. ភាពអាចទទួលយកបាន

30. សហមេធាវីបានប្តឹងឧទ្ធរណ៍ ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុលោមតាមវិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុង និងបានលើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍គឺដាក់ទាន់ពេលវេលា និងអនុលោមទៅតាមការកំណត់នៃចំនួនទំព័រ[64]។

31. អង្គបុរេជំនុំជម្រះសូមរម្លឹកថា អនុលោមតាមវិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង "ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត [...] មិនទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"[65]។ វិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុង ចែងថា បណ្តឹងឧទ្ធរណ៍ត្រូវដាក់"ក្នុងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង នៃសេចក្តីសម្រេចអំពីភាពអាចទទួលយកបាន នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"[66]។ អង្គជំនុំជម្រះពិចារណាថា បណ្តឹង

---

៣៨១ យោងទៅសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/២") (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) (D427/1/30) កថាខណ្ឌ ១១៣។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ("សាលដីកាលើសំណុំរឿង ០០២/១ (F36)") កថាខណ្ឌ ៨៩-៩០។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៣៤។

[64] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៦-៧។

[65] វិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣០។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៣។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៣។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៣។

[66] វិធាន ៧៧ ស្ទួននៃវិធានផ្ទៃក្នុង សូមមើលផងដែរ សំណុំរឿង០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣០។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៣។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៣។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៣។

ឧទ្ធរណ៍ត្រូវបានដាក់ អនុលោមទៅតាមការណែនាំរបស់អង្គជំនុំជម្រះ ដោយរំឭកអំពីសេចក្តីសម្រេចរបស់ខ្លួន ក្នុងការអនុញ្ញាតជាពិសេស ចំពោះសហមេធាវីនូវការបន្ថែមពេលវេលា៣០ថ្ងៃ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន[67]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។

## IV. គោលការណ៍គតិយុត្តិនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី

32. នៅក្នុងការវាយតម្លៃលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវី អង្គបុរេជំនុំជម្រះយល់ឃើញថា ជាការសមស្របក្នុងការរម្លឹកឡើងវិញអំពីគោលការណ៍គតិយុត្តិនានា ដែលបញ្ញត្តិអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងនៅចំពោះមុខ អ.វ.ត.ក។

33. វិធាន ២៣*ស្ទួន*(១) នៃវិធានផ្ទៃក្នុង កំណត់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖

> ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ៖
>
> ក) បង្ហាញពីអត្តសញ្ញាណឱ្យបានច្បាស់លាស់ និង
>
> ខ) បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព។

---

[67] សេចក្តីសម្រេចលើសំណើរបស់សហមេធាវី (ឯកសារ D384/4) (អង្គបុរេជំនុំជម្រះអនុញ្ញាត តាមសំណើរបស់សហមេធាវី បន្ថែមពេលវេលាក្នុងការដាក់បណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន ចំនួន៣០ថ្ងៃ បន្ទាប់ពីបានទទួលការជូនដំណឹង អំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) ជាភាសាខ្មែរ និងបង្កើនចំនួនទំព័រកំណត់ដល់៤៥ទំព័រ ជាភាសាអង់គ្លេសឬបារាំង ឬ៩០ទំព័រ ជាភាសាខ្មែរ។ ឯកសារបកប្រែ ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨។ ដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨)។

នៅពេលពិចារណាអំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ។

34. ដូចអង្គបុរេជំនុំជម្រះបានកត់សម្គាល់ពីមុនរួចហើយ[68] ធាតុផ្សំគតិយុត្តិ ដែលមានចែងនៅក្នុងវិធាន ២៣*ស្ទួន*(១) នៃវិធានផ្ទៃក្នុង រួមមាន៖ (ក) អត្ថិភាពនៃទំនាក់ទំនងរវាងឧក្រិដ្ឋកម្ម និងព្យសនកម្ម (ខ) ការខូចខាត និង (គ) ភស្តុតាងនៃអត្តសញ្ញាណ។ វិធាន ២៣*ស្ទួន*(១) នៃវិធានផ្ទៃក្នុងក៏ចែងផងដែរអំពីកម្រិតនៃភស្តុតាងពាក់ព័ន្ធ ដែលត្រូវតែមានការបង្ហាញអំពីធាតុផ្សំទាំងនេះ។ នៅក្នុងដំណើរការពិនិត្យមើលទៅលើបណ្តឹងឧទ្ធរណ៍ អង្គជំនុំជម្រះនឹងពិភាក្សាអំពីទិដ្ឋភាពគតិយុត្តិជាក់លាក់នៃធាតុផ្សំទាំងនេះ និងកម្រិតនៃភស្តុតាងពាក់ព័ន្ធនឹងការវាយតម្លៃសារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវី។ នៅក្នុងផ្នែកនេះ អង្គជំនុំជម្រះផ្តល់ជូននូវសេចក្តីសង្ខេបទូទៅដូចខាងក្រោមនេះ។

35. ជាបញ្ហាបឋម អង្គបុរេជំនុំជម្រះយល់ឃើញថា (i) កិច្ចព្រមព្រៀង អ.វ.ត.ក (ii) ច្បាប់ អ.វ.ត.ក (iii) វិធាន ២១, ២៣, ២៣ស្ទួន, ២៣ស្ទួនពីរ, ២៣ស្ទួនបី, ២៣ស្ទួនបួន និង១១៤ នៃវិធានផ្ទៃក្នុង និង (iv) សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ បង្កើតបានជាផ្នែកនៃបរិបទជាធរមាននៅក្នុងការបកស្រាយអំពីលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី[69]។ ការណែនាំក៏អាចស្វែងរកឃើញផងដែរនៅក្នុងគោលការណ៍ទូទៅស្តីពីជនរងគ្រោះដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ[70]។

---

[68] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៣។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៥៧។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៥៧។

[69] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣១។

[70] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៤។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៧។

36. ចំពោះអត្ថិភាពនៃទំនាក់ទំនងហេតុនិងផល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែបង្ហាញថា ព្យសនកម្មត្រូវតែជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ[71]។ ទោះបីជាព្យសនកម្មត្រូវតែមានលក្ខណៈជារូបវន្តក៏ដោយ ក៏លក្ខខណ្ឌតម្រូវនៃព្យសនកម្ម ជាផលវិបាកដោយផ្ទាល់នៃបទល្មើស ពុំកម្រិតការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីត្រឹមជនរងគ្រោះផ្ទាល់នោះទេ ប៉ុន្តែអាចរួមបញ្ចូលនូវជនរងគ្រោះមិនផ្ទាល់ផងដែរ ដែលបានទទួលរងព្យសនកម្មផ្ទាល់ខ្លួន ជាផលវិបាកផ្ទាល់នៃបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តមកលើជនរងគ្រោះផ្ទាល់[72]។ ដូច្នេះ យុត្តិសាស្ត្រ អ.វ.ត.ក ទទួលស្គាល់ទាំងជនរងគ្រោះផ្ទាល់ និងជនរងគ្រោះមិនផ្ទាល់។ ជនរងគ្រោះផ្ទាល់សំដៅលើ "ក្រុមបុគ្គលណាដែលសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន ឬ

---

សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣២។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣២ (ឯកសារទាំងអស់នេះយោងលើ *សេចក្តីប្រកាសស្ដីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ និងការបំពានអំណាច* សេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៤០/៣៤ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ("គោលការណ៍ស្ដីពីជនរងគ្រោះឆ្នាំ១៩៨៥") និង *គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្ដីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ* សេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៦០/១៤៧ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦ ឯកសារ អ.ស.ប. លេខ A/RES/៦០/១៤៧ ("គោលការណ៍ស្ដីពីជនរងគ្រោះឆ្នាំ២០០៥"))។

[71] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៥។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៧១។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៧១។

[72] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៥។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក ("សំណុំរឿង ០០១") សាលដីកា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ("សាលដីកាសំណុំរឿង ០០១ (ឯកសារ F28)") កថាខណ្ឌ ៤១៨។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣។

ទទួលរងការប៉ះពាល់ ដែលបណ្ដាលមកពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់"[73] ចំណែកជនរងគ្រោះមិនផ្ទាល់គឺជាបុគ្គលដែល "ទទួលរងដោយផ្ទាល់នូវព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តលើជនរងគ្រោះផ្ទាល់"[74]។

37. ចំពោះព្យសនកម្មវិញ វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង ចែងថា ព្យសនកម្មត្រូវតែជាការខូចខាតខាងរាងកាយ សម្ភារៈ ឬ ផ្លូវចិត្ត[75]។ ការខូចខាតរាងកាយ "មានន័យថាជាការខូចខាតខាងជីវសាស្ត្រ ខាងសរីរាង្គ ឬ ខាងប្រព័ន្ធដំណើរការនៃសរីរាង្គ" និង "អាចជារបួសស្នាម កាយវិកលកម្ម ការខូចទ្រង់ទ្រាយ មានជំងឺ ការបាត់បង់ ឬ ការមិនដំណើរការនៃសរីរាង្គណាមួយ ឬមរណភាព"[76]។ ព្យសនកម្មខាងសម្ភារៈ "សំដៅដល់ការបាត់បង់តម្លៃជាវត្ថុរូបិយ ដូចជាការខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងស្រុង ឬមួយផ្នែក ឬការបាត់បង់ប្រាក់ចំណូលជាដើម"[77]។ ចំណុច

---

[73] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៥។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០១ សាលដីកា (ឯកសារ F28) កថាខណ្ឌ ៤១៦។

[74] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៥។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០១ សាលដីកា (ឯកសារ F28) កថាខណ្ឌ ៤១៨។

[75] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៦។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣។

[76] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៦។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៩។ សំណុំរឿង ០០១ សាលដីកា (ឯកសារ F28) កថាខណ្ឌ ៤១៥។

[77] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៦។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៩។ សំណុំរឿង ០០១ សាលដីកា (ឯកសារ F28) កថាខណ្ឌ ៤១៥។

ចុងក្រោយ ព្យសនកម្មខាងផ្លូវចិត្ត អាច "[រួមបញ្ចូល] ទាំងជំងឺផ្លូវចិត្ត ឬវិកលចរិត ដូចជាជំងឺបាក់ស្បាត"[78]។

38. ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវសម្រាប់អ្នកដាក់ពាក្យសុំទាំងអស់ ក្នុងបង្ហាញអត្តសញ្ញាណឱ្យបានច្បាស់នោះ អង្គបុរេជំនុំជម្រះធ្លាប់បានអនុម័តវិធីសាស្ត្រមួយដែលមានលក្ខណៈបត់បែន[79] ដែលរួមមាន ឧទាហរណ៍ ទទួលយកជាភ័ស្តុតាងនៃអត្តសញ្ញាណ នូវសេចក្តីបញ្ជាក់នានាដែលចេញដោយអ្នកភូមិចាស់ទុំ ឬមេភូមិជាដើម[80]។

39. ទាក់ទិននឹងកម្រិតនៃភ័ស្តុតាង ដែលត្រូវតែមានការបង្ហាញអំពីធាតុផ្សំខាងលើនេះ អនុលោមតាមវិធាន ២៣*ស្ទួន*(១) នៃវិធានផ្ទៃក្នុង នៅក្នុងការវាយតម្លៃលើសម្ភារដែលបានដាក់ជាផ្នែកនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ អង្គបុរេជំនុំជម្រះត្រូវតែ "ជឿជាក់ថា អង្គហេតុដែលបានអះអាងដើម្បីគាំទ្រដល់ពាក្យសុំនោះ មានភាពពិតប្រាកដ"[81]។

---

[78] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៦។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣។ សំណុំរឿង ០០១ សាលដីកា (ឯកសារ F28) កថាខណ្ឌ ៤១៥។

[79] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៧។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៤០។

[80] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៩៥។

[81] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៨។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៤១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៩៤។

# V. អង្គសេចក្ដី

40. ទោះបីជាសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ស្ដីពីភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ ត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើក្ដី បន្ទាប់ពីប្រជុំពិភាក្សារួចហើយ អង្គជំនុំជម្រះមិនអាចទទួលបានសម្លេងភាគច្រើនលើសលប់នៃសម្លេងគាំទ្រចំនួនបួនតាមការកំណត់ ដើម្បីឈានទៅសេចក្ដីសម្រេចផ្អែកលើសំអាងហេតុរួមលើអង្គសេចក្ដីឡើយ។ អនុលោមតាមវិធាន ៧៧(៤) នៃវិធានផ្ទៃក្នុង យោបល់របស់សមាជិកនានានៃអង្គបុរេជំនុំជម្រះ ត្រូវបានភ្ជាប់មកជាមួយសេចក្ដីពិចារណានេះ។

# VI. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ ជាឯកច្ឆ័ន្ទ៖**

- **ប្រកាស** ថា អង្គបុរេជំនុំជម្រះមិនអាចទទួលបានសម្លេងគាំទ្រយ៉ាងតិចបួនសម្លេង សម្រាប់ចេញសាលដីកា ផ្អែកលើសំអាងហេតុរួម លើអង្គសេចក្តីបានឡើយ។

អនុលោមតាមវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ត្រូវជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីនានា អំពីសាលដីកានេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី សូមលើកឡើងនូវយោបល់របស់ខ្លួនទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។

ចៅក្រម Kang Jin BAIK និងចៅក្រម Olivier BEAUVALLET សូមលើកឡើងនូវយោបល់របស់ខ្លួនទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។

## VII. យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី

41. ទាក់ទិននឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមជាតិនៃ អបជ មានមតិបន្ថែមដូចតទៅ៖

42. ចៅក្រមជាតិនៃ អបជ បានយល់ឃើញថា ការដែលសហចៅក្រមស៊ើបអង្កេតជាតិសម្រេចថា៖ អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ ឡើយ និងលើកលែងការចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ គឺជាការត្រឹមត្រូវ។ ចៅក្រមជាតិនៃ អបជ សម្រេច៖ បិទសំណុំរឿង ០០៤ ដែលមាន យឹម ទិត្យ ជាជនត្រូវចោទ និងបញ្ជូនទៅតម្កល់ទុកនៅបណ្ណសារ នៃ អ.វ.ត.ក។

43. តាមវិធាន ២៣ ស្ទួននៃវិធានផ្ទៃក្នុង ចៅក្រមជាតិនៃ អបជ យល់ឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**ទាំងអស់**គប្បីបដិសេធ។

44. ហេតុដូច្នេះ ចៅក្រមជាតិនៃ អបជ សម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០៤។

**រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១**

| | | |
|---|---|---|
| **ចៅក្រម ប្រាក់ គឹមសាន** | **ចៅក្រម ន័យ ថុល** | **ចៅក្រម ហួត វុទ្ធី** |

## VIII. យោបល់របស់ចៅក្រម KANG JIN BAIK និងចៅក្រម OLIVIER BEAUVALLET

45. ចៅក្រមអន្តរជាតិនឹងបង្ហាញអំពីការពិចារណារបស់ខ្លួន ទៅលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដូចតទៅ។

**ក. មូលដ្ឋានទី ១÷ ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសម្រេចថា លក្ខខណ្ឌតម្រូវពីទំនាក់ទំនងសម្រាប់សហឧក្រិដ្ឋកម្មរួម ក (គោលនយោបាយ ប.ក.ក ទាំង ៤) អនុលោមតាមវិធាន ២៣ស្ទួន(១)(ខ) ត្រូវបានបំពេញដោយជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅភូមិភាគពាយ័ព្យតែប៉ុណ្ណោះ**

*១. អំណះអំណាង*

46. យោងតាមមូលដ្ឋានទី ១ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវី") អះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយខកខានមិនបានសម្រេចថា ជនរងគ្រោះនៃគោលនយោបាយ ប.ក.ក នៅទូទាំងប្រទេស ដែលស្ថិតនៅក្រៅភូមិភាគពាយ័ព្យ ក៏ទទួលរងព្យសនកម្មដោយផ្ទាល់ ដោយសារលទ្ធផលនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើ យឹម ទិត្យ។ ស្របតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះដែលថា លក្ខខណ្ឌតម្រូវនៃចំណងទាក់ទងហេតុនិងផល អនុលោមតាមវិធាន ២៣*ស្ទួន*(១)(ខ) គួរត្រូវបានបកស្រាយក្នុងន័យ "ទូលាយ" សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរទទួលស្គាល់ថា (i) ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងអនុលោមតាមគោលនយោបាយ ប.ក.ក នៅទូទាំងប្រទេស ដែលត្រូវបានអនុវត្តនៅក្រោមសហឧក្រិដ្ឋកម្មរួម ("JCE")[82] (ii) ជនរងគ្រោះនៃក្រុមគោលដៅដូចគ្នា ដែលបានទទួលរងព្យសនកម្មជាសមូហភាព ដោយមិនគិតពីតាំងរបស់ពួកគេ[83] និង (iii) ជនរងគ្រោះ ដែលទទួល

---

[82] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ១៨-១៩។

[83] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ១៩។

រងព្យសនកម្មពីគោលនយោបាយ និងឧក្រិដ្ឋកម្មដែលបានអនុវត្ត *នៅក្នុង*ទីតាំងឧក្រិដ្ឋកម្ម និងភូមិភាគ ដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[84]។

47. យោងតាមមូលដ្ឋានទី១(១) សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយផ្តោតតែលើឧក្រិដ្ឋកម្មដែលទាក់ទងនឹងគោលនយោបាយ ប.ក.ក ដែលបានប្រព្រឹត្តឡើងនៅភូមិភាគពាយ័ព្យ ទោះបីមានការចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ថា យឹម ទិត្យ បានចូលរួម និងអនុវត្តគោលនយោបាយ ក្រោមសហឧក្រិដ្ឋកម្មរួមដែលមានវិសាលភាពនៅទូទាំងប្រទេស[85]។ សហមេធាវីអះអាងថា អង្គបុរេជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសំណុំរឿង ០០២ ថា វិធាន ២៣*ស្ទួន*(១)(ខ)នៃវិធានផ្ទៃក្នុង តម្រូវឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញអំពីទំនាក់ទំនងរវាង "ព្យសនកម្មខាងរូបកាយ ខាងសម្ភារៈ ឬ ខាងផ្លូវចិត្ត" ជាមួយ "ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់" ដែលបង្កើតបានជា "ការកំណត់បទចោទទៅលើស្ថានភាពអង្គហេតុ ដែលត្រូវបានធ្វើការស៊ើបអង្កេត" ជាជាងអង្គហេតុដែលបានស៊ើបអង្កេត[86]។ ដូច្នេះ ក្នុងករណីអំពើឃោរឃៅទ្រង់ទ្រាយធំ ដែលប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ស្របតាមគោលនយោបាយទូទាំងប្រទេស អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនចាំបាច់តម្រូវឱ្យបង្ហាញ ពីទំនាក់ទំនងរវាងព្យសនកម្មរបស់ខ្លួនទៅនឹងទីតាំងឧក្រិដ្ឋកម្មមួយក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មនានា ឬឧប្បត្តិហេតុអង្គហេតុនានា ដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ[87]។

---

[84] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ១៩។

[85] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២០។

[86] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២០-២១ *យោងទៅ* វិធាន ២៣ *ស្ទួន*(១)(ខ)។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៥២, ៥៩, ៦៦, ៦៨-៦៩, ៧២, ៧៧។ តុលាការពិសេសសម្រាប់ប្រទេសឡេបាណន់ រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Ayyash និងជនជាប់ចោទ ផ្សេងទៀត* សំណុំរឿងលេខ STL-11-01/PT/PTJ សេចក្តីសម្រេចទីបួនស្តីពីការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ១៥។

[87] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២០-២១ *យោងទៅ* សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧២, ៧៨។ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេ

48. សហមេធាវីអះអាងថា ការសម្រេចនៅក្នុងសំណុំរឿង ០០២ របស់អង្គបុរេជំនុំជម្រះ អនុវត្តដូចគ្នាក្នុងកិច្ចដំណើរការនៃករណីនេះ ដោយសារ យឹម ទិត្យ បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម នៅទូទាំងប្រទេស ដោយមានគោលដៅអនុវត្តគោលនយោបាយ ប.ក.ក នៅទូទាំងប្រទេសកម្ពុជាក្រៅពីភូមិភាគពាយ័ព្យ[88]។ សហមេធាវីចោទប្រកាន់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដាក់បញ្ចូល យឹម ទិត្យ ជា "មនុស្សចំបងម្នាក់ ដែលមានការទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងតំបន់ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គាត់" និងអះអាងថា សហឧក្រិដ្ឋកម្មរួមនៅទូទាំងប្រទេសត្រូវបានអនុវត្ត តាមរយៈបណ្ដាញសហគ្រាសនៅថ្នាក់តំបន់ រួមទាំងអនុវត្តដោយ យឹម ទិត្យ នៅក្នុងតំបន់ក្រោមការបង្គាប់បញ្ជារបស់គាត់[89]។ ដើម្បីគាំទ្រការអះអាងទាំងនេះ សហមេធាវីយោងទៅការចោទប្រកាន់ដែលថា យឹម ទិត្យ បានធ្វើជាប្រធានកិច្ចប្រជុំជាប្រចាំ បានចុះមើលការដ្ឋាន ចុះសួរសុខទុក្ខនៅតាមមន្ទីរសន្តិសុខ និងមានសិទ្ធិអំណាចលើអង្គភាពយោធា បញ្ហាបុគ្គលិក គោលនយោបាយសន្តិសុខ និងគោលនយោបាយសេដ្ឋកិច្ចនៅក្នុងតំបន់ដែលគាត់ទទួលខុសត្រូវ[90]។ សហមេធាវីកត់សម្គាល់ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថា តួនាទី និងសកម្មភាពរបស់ យឹម ទិត្យ "អាចប្រៀបធៀបបានយ៉ាងងាយជាមួយ" តួនាទី និងសកម្មភាពរបស់ អោ អាន, មាស មុត ឬ កាំង ហ្គេចអ៊ាវ ហៅ ឌុច និង "ជួនកាលទៀតអាចលើសច្រើនជាងនេះទៀតផង"[91]។

---

អូន រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Sesay និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ SCSL-04-15-T សាលក្រម ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២៦២។

[88] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៣ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ (D191) កថាខណ្ឌ ១៤។

[89] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៣-២៤ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០២០។

[90] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៤ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៦៤-៣៦៧, ៣៧៤។

[91] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៤ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៩៩៩។

49. សហមេធាវីគូសបញ្ជាក់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានរកឃើញថា យឹម ទិត្យ បានអនុវត្ត និងបាន "ចូលរួមចំណែកសំខាន់" នៅក្នុងគោលនយោបាយជាតិទាំងបួននៅថ្នាក់តំបន់ (រួមគ្នាហៅថា សហឧក្រិដ្ឋកម្មរួម ក)[92] ក៏ដូចជា សហឧក្រិដ្ឋកម្មរួមពីរបន្ថែមទៀតដើម្បី (i) បោសសម្អាតទាំងស្រុង ឬមួយផ្នែកនៃទឹកដីខ្មែរក្រោម (សហឧក្រិដ្ឋកម្មរួម ខ) និង (ii) ជំរុញដល់ប្រព័ន្ធនៃការធ្វើបាបនៅមន្ទីរសន្តិសុខវត្តព្រះធាតុ (សហឧក្រិដ្ឋកម្មរួម គ) [93]។

50. ដូច្នេះ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយផ្តោតតែលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅភូមិភាគពាយ័ព្យ ក្នុងការកំណត់ការទទួលយកជនរងគ្រោះនៃ សហឧក្រិដ្ឋកម្មរួម ក ជាដើមបណ្តឹងរដ្ឋប្បវេណី "ទោះបីជាមានការបង្ហាញយ៉ាងច្បាស់អំពី "ទិដ្ឋភាពជារួម" នៃការទទួលខុសត្រូវរបស់ មាស មុត"[94]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរពិចារណាអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្រៅភូមិភាគពាយ័ព្យ ដែលវាបង្កើតបានជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែល យឹម ទិត្យ ត្រូវបានចោទប្រកាន់ថាជាសមាជិកម្នាក់ដែរ[95]។ សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងឧបសម្ព័ន្ធ ខ និង គ ដែលបានទទួលរងព្យសនកម្មជាផលវិបាកផ្ទាល់នៃការអនុវត្ត សហឧក្រិដ្ឋកម្មរួម ក ថ្នាក់ជាតិនេះ[96]។

---

[92] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៥ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦, ១០២១-២០២២ (ដែលរៀបរាប់អំពីគោលនយោបាយទូទាំងប្រទេសលើកទីបួនស្តីពី "ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ។ បទបញ្ញត្តិអាពាហ៍ពិពាហ៍ដែលត្រូវបានអនុវត្ត *ជាអាទិ៍* អាពាហ៍ពិពាហ៍ប្រជាជនដោយបង្ខំ ការអប់រំអ្នកដែលហៅថា "សមាសធាតុមិនល្អ" និងការសម្លាប់ខ្មាំង និង "សមាសធាតុមិនល្អ" ទាំងក្នុងជួរ និងក្រៅជួរ ប.ក.ក ព្រមទាំងការកំណត់គោលដៅជាក់លាក់")។

[93] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៥ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦(ii), (iii)។

[94] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៦។

[95] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៦។

[96] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៧-២៨។ សហមេធាវីយោងទៅឧបសម្ព័ន្ធ ខ (សំណុំរឿង ០០៤ ឧបសម្ព័ន្ធ ខ៖ ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយសារគោលនយោបាយមួយចំនួននៃ JCE ក ឧបសម្ព័ន្ធភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5.2.2 ("ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.2)")) និងឧបសម្ព័ន្ធ គ

51. យោងតាមមូលដ្ឋានទី១(២) សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយសារបានកម្រិតវិសាលភាពភូមិសាស្ត្រនៃភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រឹមជនរងគ្រោះ ដែលរស់នៅក្នុងតំបន់រដ្ឋបាលគ្រប់គ្រងដោយ យឹម ទិត្យ ពីព្រោះសមាជិកនៃសហគមន៍គោលដៅជាក់លាក់ និងក្រុមនៅក្រៅតំបន់ទាំងនេះ ក៏ទទួលរងនូវព្យសនកម្មពីការខូចខាតជាសមូហភាពផងដែរ[97]។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ "សច្ចធារនៃការខូចខាតជាសមូហភាព" ដែលពង្រីកលើសពីសមាជិកនៃក្រុម ឬសហគមន៍គោលដៅតែមួយ នៅពេលដែលឧក្រិដ្ឋកម្មសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ ត្រូវបានចោទប្រកាន់ ដោយបដិសេធរាល់លក្ខខណ្ឌនៃការស្ថិតនៅជិតគ្នាផ្នែករូបរាងកាយរវាងសមាជិកនៃក្រុមមនុស្ស ឬ សហគមន៍គោលដៅតែមួយនោះ[98]។ សហមេធាវីចោទប្រកាន់បន្ថែមទៀតថា ការយល់ព្រមទទួលស្គាល់របស់ អ.វ.ត.ក ចំពោះ "ការខូចខាតជាសមូហភាព" ស្របជាមួយការអនុវត្តជាអន្តរជាតិ[99] ពីព្រោះសញ្ញាណនេះត្រូវបានទទួលស្គាល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)[100] គោលការណ៍

---

(សំណុំរឿង ០០៤ ឧបសម្ព័ន្ធ គ៖ ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយសារគោលនយោបាយកំណត់ជាគោលដៅនៃ JCE ក ឧបសម្ព័ន្ធភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5.2.3 ("ឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.3)")) ដែលបង្ហាញអត្តសញ្ញាណអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធ ដែលបានទទួលរងព្យសនកម្មដោយសារតែផលវិបាកនៃគោលនយោបាយលើកទីបួន ដែលបានអនុវត្តដើម្បីជម្រុញផែនការឧក្រិដ្ឋរួមនៃសហក្រិដ្ឋកម្មរួម (JCE) ក រួមមាន អន ដារ៉ាវុធ (17-VSS-00043), សេវ ហៀម (13-VSS-00282) និង ប៉ែន ហឿន (11-VSS-00094)។

97 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៩។

98 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣០ *យោងទៅ* សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៨៣-៩៣។

99 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣១។

100 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣១ *យោងទៅ* តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo* អង្គជំនុំជម្រះតុលាការកំពូល សំណុំរឿងលេខ ICC-01/04-01/06-1432 សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៣៥។

គ្រឹះរបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៨៥ និង ២០០៥[101] និងស្ថាប័នសិទ្ធិមនុស្សផ្សេងទៀត ដូចជា គណៈកម្មការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក និងតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង[102]។

52. សហមេធាវីអះអាងថា យឹម ទិត្យ ទទួលខុសត្រូវចំពោះការកំណត់គោលដៅក្រុម ឬ សហគមន៍ជាក់លាក់នៅភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ នៅភូមិភាគនិរតី[103] ហើយចោទប្រកាន់ថា តាមសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ការសន្មតអំពីការខូចខាតជាសមូហភាពដែលកើតចេញពីព្យសនកម្មដែលទទួលរងដោយជនរងគ្រោះផ្ទាល់នៅភូមិភាគពាយ័ព្យ និងភូមិភាគនិរតី បានពង្រីករហូតដល់សមាជិកទាំងអស់នៃក្រុម ឬសហគមន៍គោលដៅជាក់លាក់ទាំងនេះ ដោយមិនគិតអំពីទីកន្លែងរបស់ពួកគេឡើយ[104]។

53. ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិអះអាងទទួលស្គាល់គោលការណ៍ នៃការខូចខាតជាសមូហភាពនៅក្នុងសេចក្ដីសន្និដ្ឋានរបស់គាត់ និងទទួលស្គាល់បន្ថែមទៀតថា ជនរងគ្រោះនៃសហឧក្រិដ្ឋកម្មរួម ក្នុងការលុបបំបាត់ខ្មែរក្រោម (សហឧក្រិដ្ឋកម្មរួម ខ) "មិនចាំបាច់ត្រូវកម្រិតកំណត់ដោយទីតាំងភូមិសាស្ត្រតែចំពោះទីតាំងជាក់លាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកា

---

[101] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣១ *ដែលដកស្រង់*គោលការណ៍ជាមូលដ្ឋានសម្រាប់ជនរងគ្រោះ ឆ្នាំ១៩៨៥ ឧបសម្ព័ន្ធ ក.១។ គោលការណ៍សម្រាប់ជនរងគ្រោះ ឆ្នាំ២០០៥ បុព្វកថា។ .

[102] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣១ *យោងទៅ* គណៈកម្មាធិការអាហ្វ្រិកស្ដីពីសិទ្ធិមនុស្ស និងប្រជាជន *មជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍសិទ្ធិជនជាតិភាគតិច (កេនីយ៉ា) និងក្រុមអន្តរជាតិការពារសិទ្ធិជនជាតិភាគតិច តំណាងឱ្យក្រុមប្រឹក្សា Endorois Welfare ទល់នឹង ប្រទេសកេនីយ៉ា* សំណុំរឿងលេខ ២៧៦/០៣ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ២៤៨។ គណៈកម្មាធិការ អ.ស.ប ទទួលបន្ទុកផ្នែកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ យោបល់ទូទៅលេខ ២១ មាត្រា ១៥(១)(ក) (*សិទ្ធិរបស់មនុស្សម្នាក់ៗដើម្បីចូលរួមក្នុងជីវិតវប្បធម៌*) សម័យប្រជុំលើកទី ៤៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ អ.ស.ប លេខ E/C. 12/GC/21 កថាខណ្ឌ ៣៧។ តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក *សំណុំរឿងរបស់ជនជាតិដើម Kichwa នៃ Sarayaku ទល់នឹង ប្រទេស អេក្វាឌ័រ* សាលក្រម (អង្គសេចក្ដី និងការជួសជុលសំណង) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ ស៊េរី គ លេខ ២៤៥ កថាខណ្ឌ ២៣១-២៣២, ២៨៤។

[103] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣២ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១៩៦-២៧៥, ៣០៨, ៣១០, ៣១១, ៣១២-៣១៦, ១០២២។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (D1) កថាខណ្ឌ ១៧, ៥៩, ៩៨។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី១ (D65) កថាខណ្ឌ ១១-២០។

[104] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣២។

ដែលរងការជំទាស់]"[105] ក៏ដោយ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ "បានដាក់លក្ខខណ្ឌតម្រូវដោយខុសឆ្គងថា សមាជិកដែលរស់នៅក្នុងក្រុម ឬសហគមន៍គោលដៅតែមួយ ត្រូវតែស្ថិតនៅក្នុងភូមិភាគពាយ័ព្យ ឬ ទីតាំងជាក់លាក់ទាំងប្រាំមួយ នៅក្នុងភូមិភាគនិរតី"[106]។

54. សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាដែលរងការជំទាស់ និងទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលបានផ្ដល់ព័ត៌មានគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីសមាជិកភាពរបស់ពួកគាត់នៅក្នុងក្រុម ឬសហគមន៍ដែលបានកំណត់គោលដៅជាក់លាក់មួយ ឬច្រើន ដូចបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសេចក្ដីសន្និដ្ឋាននានា[107]។

55. យោងតាមមូលដ្ឋានទី១(៣) សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាត់ទុកថាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន មិនអាចទទួលយកបាន ទោះបីពួកគេទទួលរងព្យសនកម្ម ពីគោលនយោបាយ និងឧក្រិដ្ឋកម្ម ដែល យឹម ទិត្យ ទទួលខុសត្រូវក្នុងភូមិភាគពាយ័ព្យ និងទីតាំងកន្លែងឧក្រិដ្ឋកម្មចំនួន ៦ នៅភូមិភាគនិរតីក៏ដោយ[108]។ យោងតាមឧបសម្ព័ន្ធ ឃ របស់ខ្លួន សហមេធាវីចោទប្រកាន់ថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ចំនួន ៦៦ បានបំពេញតាមលក្ខណៈវិនិច្ឆ័យ "ន័យចង្អៀត" និង "ខុសឆ្គង" របស់ដីកាដែលរងការជំទាស់[109]។ ម្យ៉ាងវិញទៀត សហ

---

[105] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៣ *យោងទៅ* ដីកាសម្រេចអំពីដើមបណ្ដឹងរដ្ឋប្បវេណី (D384) កថាខណ្ឌ ២៨។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ២៨៩, ១០១៦(ii)។

[106] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៣។

[107] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៤-៣៥។ សហមេធាវីយោងទៅឧបសម្ព័ន្ធ គ របស់ខ្លួន (D384/5.2.3) ដែលបង្ហាញអត្តសញ្ញាណអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ ដែលបានទទួលរងព្យសនកម្មដោយសារតែផលវិបាកជាសមាជិកនៃក្រុម ឬសហគមន៍ជាគោលដៅ រួមមានអ្នកដាក់ពាក្យសុំចំនួន ០៨ នាក់ ដូចជា៖ នុត សារុន (11-VSS-00152), តែ គឹមស៊ាង (11-VSS-00015), សៀង ចាន់ធី (13-VSS-00396), ស៊ាង រី (12-VSS-00669), ពិន ដន (11-VSS-00027), ជា ជឿង (12-VSS-00503), លឹម ស៊ាងគាង (11-VSS-00020), ទេព ចាន់រ៉ា (11-VSS-00226) ព្រមទាំងអ្នកដាក់ពាក្យសុំពីរនាក់បន្ថែមទៀតគឺ៖ ផាត់ ហាន (12-VSS-00805) និង ជា សឿន (14-VSS-00061) ពីឧបសម្ព័ន្ធ ខ របស់សហមេធាវី (D384/5.2.2)។

[108] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៦។

[109] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៦។ ចៅក្រមអន្តរជាតិសង្កេតឃើញថា ចំនួនអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានរៀបរាប់ឈ្មោះនៅក្រោមបទចោទប្រកាន់ទី ១ ដល់ ៧ ក្នុងឧបសម្ព័ន្ធ ឃ របស់សហមេធាវី គឺ ៦៧ នាក់ មិនមែន ៦៦ នាក់ ដូចបានចោទប្រកាន់នៅក្នុងសារណារបស់ពួកគេនោះទេ។ *សូមមើល* សំណុំ

មេធាវីអះអាងថា អ្នកដាក់ពាក្យសុំចំនួន ២៦៨ នាក់ ដែលបានទទួលរងការខូចខាតនៅតាមកន្លែងទូទាំងភូមិភាគនិរតី ដែល យឹម ទិត្យ មានសិទ្ធិអំណាច ប៉ុន្តែមិនមែននៅទីតាំងមួយក្នុងចំណោមទីតាំងទាំង ៦ នៃភូមិភាគនិរតី ដែលត្រូវបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គួរត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី[110]។ ចំពោះបញ្ហានេះ សហមេធាវីយោងទៅការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិដែលថា យឹម ទិត្យ ជាអនុលេខា និងក្រោយមកក្លាយជាលេខាគណៈកម្មាធិការស្រុកគិរីវង់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានដឹកនាំគណៈកម្មាធិការតំបន់ ១៣ ហើយគាត់ក៏មានសិទ្ធិអំណាចតាមព្រឹត្តិន័យដ៏ទូលំទូលាយលើភូមិភាគនិរតី ចាប់ពីឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[111]។

56. សហមេធាវីបានសន្និដ្ឋានថា ទោះបីជាម្ចាស់បណ្តឹងឧទ្ធរណ៍ដែលបានទទួលរងព្យសនកម្មជាផលវិបាកផ្ទាល់នៃសហឧក្រិដ្ឋកម្មរួម ក ក៏ដូចជាជនរងគ្រោះនៃក្រុមគោលដៅ ឬ សហគមន៍ជាក់លាក់ដែលបានទទួលរងការខូចខាតជាសមូហភាព គួរតែត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីដូចចំណុចខាងលើក៏ដោយ[112] ក៏ទីតាំងនៃការខូចខាតដែលបានទទួលរងដោយម្ចាស់បណ្តឹងឧទ្ធរណ៍នៅទីតាំងឧក្រិដ្ឋកម្ម និងភូមិភាគដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបង្កើតបានជា "ទំនាក់ទំនងបន្ថែមទៀត រវាងព្យសនកម្មពួកគាត់ និងសកម្មភាពឧក្រិដ្ឋរបស់ យឹម ទិត្យ"[113]។

---

រឿង ០០៤ ឧបសម្ព័ន្ធ ឃ៖ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលរងព្យសនកម្មដោយសារការប្រព្រឹត្តិនៅតាមភូមិភាគ និងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងវិសាលភាពនៃសំណុំរឿង ០០៤ ឧបសម្ព័ន្ធភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5.2.4 ("ឧបសម្ព័ន្ធ ឃ ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.4)")។

[110] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៧ *យោងទៅ* ដីកាសម្រេចអំពីដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) (D384) កថាខណ្ឌ ៣៦ [*sic*]។

[111] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៨ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣២៧-៣៣២, ៣៣៤-៣៣៥, ៣៤៨-៣៥០។

[112] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៨។

[113] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៨។

## ២. *ការពិភាក្សា*

57. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឡើយ ចំពោះការកំណត់តែទៅលើឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ នៅភូមិភាគនិរតី ថាមានការពាក់ព័ន្ធទៅនឹងលក្ខខណ្ឌចំណងហេតុនិងផល អនុលោមតាមវិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង។ ទីមួយ ចៅក្រមអន្តរជាតិសង្កេតឃើញថា ដីកាដែលរងការជំទាស់ កម្រិតយ៉ាងត្រឹមត្រូវនូវការពិនិត្យលើអ្នកដាក់ពាក្យសុំដែលអាចក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ត្រឹមភូមិភាគពាយ័ព្យ ទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម ក។ ទីពីរ ដីកាដែលរងការជំទាស់បកស្រាយ និងអនុវត្តយ៉ាងត្រឹមត្រូវនូវសញ្ញាណនៃការខូចខាតជាសមូហភាព ទាក់ទងទៅនឹងជនរងគ្រោះដោយប្រយោល ដែលបានទទួលរងព្យសនកម្ម ដោយសារលទ្ធផលនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទៅលើជនរងគ្រោះដោយផ្ទាល់នៅភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ នៅភូមិភាគនិរតី។ ទីបី សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសដោយសារការដកចេញអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅខាងក្រៅទីតាំងឧក្រិដ្ឋកម្មដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។

### ក. ច្បាប់ជាធរមាន

58. វិធាន ២៣(១) នៃវិធានផ្ទៃក្នុង ដែលកំណត់គោលបំណងនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចែងថា៖

> គោលបំណងនៃបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺដើម្បី៖
>
> ក. ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់។ និង
>
> ខ. ទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដូចមានចែងក្នុងវិធាន ២៣*ស្ទួនបួន*។

59. វិធាន ២៣*ស្ទួន*(១) នៃវិធានផ្ទៃក្នុង ចែងអំពីលក្ខខណ្ឌនៃការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដូចខាងក្រោម៖

> ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវ៖
>
> ក. បង្ហាញពីអត្តសញ្ញាណឱ្យបានច្បាស់លាស់ និង
>
> ខ. បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋកម្មជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនរងគ្រោះ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព។ នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ។

### ខ. មូលដ្ឋានទី ១(១)

60. វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចែងថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវ "បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋកម្មជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនរងគ្រោះ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបកាយ សម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព"[114]។ ចៅក្រមអន្តរជាតិសង្កេតឃើញថា វិធានផ្ទៃក្នុងនេះ តម្រូវឱ្យមានចំណងទាក់ទងរវាង "ព្យសនកម្ម" និង "បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់"[115]។ ហេតុដូច្នេះ ព្យសនកម្ម ដែលទទួលរងដោយអ្នកដាក់ពាក្យ

---

[114] វិធាន ២៣ *ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង។

[115] វិធាន ២៣ *ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៤២។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៤២។

សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីពិចារណាសម្រេចទទួលស្គាល់នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលនេះ[116]។

61. ចៅក្រមអន្តរជាតិរំលឹកឡើងវិញនូវការបញ្ជាក់បំភ្លឺពីមុនរបស់អង្គបុរេជំនុំជម្រះ អំពីអត្ថន័យនៃវិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង[117]។ ជាពិសេស អង្គជំនុំជម្រះបានបញ្ជាក់ថា "វត្ថុបំណង និងគោលបំណងនៃវិធាន ២៣ស្ទួន (១) នៃវិធានផ្ទៃក្នុង មិនមែនបង្កើតឡើងសម្រាប់រឹតបន្តឹង ឬកំណត់ទៅលើសកម្មភាពរបស់ជនរងគ្រោះ ឬសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅ អ.វ.ត.ក នោះទេ។ ប៉ុន្តែ វិធាននេះបង្កើតឡើងសម្រាប់កំណត់លក្ខណៈវិនិច្ឆ័យក្នុងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"[118]។ ចៅក្រមអន្តរជាតិរំលឹកឡើងវិញថា នៅក្នុងសំណុំរឿង ០០២ ដែលពាក់ព័ន្ធនឹងជនជាប់ចោទជាច្រើននាក់ អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ទោះបីជា "អង្គហេតុដែលត្រូវស៊ើបអង្កេតកំណត់ត្រឹមតែទៅលើតំបន់ ឬទីតាំងឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ ក៏ការកំណត់បទចោទនៃអង្គហេតុទាំងនេះ [...] បានរួមបញ្ចូលនូវឧក្រិដ្ឋកម្ម [...] ដែលត្រូវបានចោទប្រកាន់ថា ជនត្រូវចោទបានធ្វើឡើងរួមគ្នា ក្នុងពេលអនុវត្តសហឧក្រិដ្ឋកម្មរួម ព្រមទាំងរួមបញ្ចូលឧក្រិដ្ឋកម្មដទៃទៀតដែលបានធ្វើឡើងប្រឆាំងប្រជាជន និង "នៅ*ទូទាំង*ប្រទេស""[119]។ ដូចបានកត់សំគាល់ដោយអង្គបុរេជំនុំជម្រះ "ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក ជាពិសេសក្នុងសំណុំរឿង ០០២ គឺស្ថិតក្នុងស្ថានភាពខុសគ្នាពីជនរងគ្រោះនៅចំពោះមុខតុលាការក្នុងស្រុក

[116] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៥៦ យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៥៨។

[117] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦២។ សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៦២។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៦២។

[118] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦២។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៦២។

[119] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៤២។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៤២។

01678806



និងស្វូម្បីតែជនរងគ្រោះនៅ អ.វ.ត.ក ក្នុងសំណុំរឿង ០០១ ក៏មានស្ថានភាពខុសគ្នាដែរ"[120]។ ដូច្នេះ នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពុំចាំបាច់ត្រូវភ្ជាប់ព្យសនកម្មរបស់ខ្លួនជាមួយទីតាំងឧក្រិដ្ឋកម្មទាំងឡាយ ដែលកំណត់នៅក្នុងដីកាដំណោះស្រាយនោះទេ "ដោយសារបទឧក្រិដ្ឋទាំងនោះ និងគោលនយោបាយជាមូលដ្ឋានរបស់ខ្មែរក្រហម បានបង្កើតជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានអនុវត្តនៅទូទាំងប្រទេកម្ពុជា"[121] ជាមួយបទល្មើសទាំងនោះ "រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌ[ឆ្នាំ១៩៥៦]"[122]។

62. ទោះជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិពិចារណាថា ការយោងរបស់សហមេធាវីទៅរកការសម្រេចមុនៗរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង ០០២ មិនគួរឲ្យជឿជាក់[123] ហើយកាលៈទេសៈក្នុងសំណុំរឿង ០០២ ខុសគ្នាពីសំណុំរឿងបច្ចុប្បន្ន។ ជាពិសេស ចៅក្រមអន្តរជាតិកត់សម្គាល់ថា នៅក្នុងសំណុំរឿង ០០២ ជនជាប់ចោទជាច្រើននាក់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទូទាំងប្រទេសកម្ពុជា[124]។ ផ្ទុយទៅវិញ ក្នុងករណីបច្ចុប្បន្ន យឹម ទិត្យ ត្រូវបានចោទប្រកាន់ចំពោះបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ នៅក្នុងភូមិភាគនិរតីតែប៉ុណ្ណោះ[125]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កំណត់ និងកម្រិតយ៉ាងច្បាស់អំពីវិសាលភាពភូមិសាស្ត្រ និងអង្គហេតុនៃរឿងក្ដីនេះដូចតទៅ៖ "យឹម ទិត្យ ជាមនុស្សចម្បងម្នាក់ដែលមានការទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយរបស់ ប.ក.ក ក្នុងតំបន់ដែល

---

[120] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦៩។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៦៩។

[121] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧២។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៧២។

[122] សំណុំរឿង ០០២ សាលដីកាលើគ្រប់ ណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧១។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៧១។

[123] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៣។

[124] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧៤-៧៥។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៧៤-៧៥។

[125] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) ទំព័រ ៧៣២-៧៤៥។

ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គាត់"[126] ដែលជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួមបីប្រភេទដោយឡែកពីគ្នា ដែលមានកម្មាភិបាល ប.ក.ក មានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយទាំងនេះ[127]។

63. ដូច្នេះ ចៅក្រមអន្តរជាតិពិចារណាថា កាលៈទេសៈដែលកំណត់ដោយអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០២ មិនឃើញមាននៅក្នុងរឿងក្តីនេះទេ ហើយយល់ឃើញថា ទឡ្ហីករណ៍របស់សហមេធាវីទាក់ទងនឹងការសម្រេចនានានៅក្នុងសំណុំរឿង ០០២ មិនពាក់ព័ន្ធឡើយ។

64. ម្យ៉ាងវិញទៀត សហមេធាវីអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីនៅទូទាំងប្រទេសកម្ពុជាគួរត្រូវបានទទួលស្គាល់ ហើយបញ្ជាក់ដដែលៗអំពីការចោទប្រកាន់ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដើម្បីគាំទ្រការអះអាងនេះ[128]។ ចៅក្រមអន្តរជាតិរំលឹកថា នៅដំណាក់កាលចេញដីកាដំណោះស្រាយ ឯកសារដែលមានអាជ្ញាព្រឹត្តិ គឺដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពុំមែនដីកាសន្និដ្ឋានមុនៗរបស់ការិយាល័យសហព្រះរាជអាជ្ញានោះទេ[129]។ ចៅក្រមអន្តរជាតិកត់សំគាល់បន្ថែមទៀតថា ចំណងហេតុផលដែលត្រូវបង្ហាញដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ មិនមែនដើម្បី "(i) វិសាលភាពទូលំទូលាយនៃកិច្ចស៊ើបសួរ (ii) អង្គហេតុ ដែលត្រូវបានបើកការស៊ើបអង្កេតរួចហើយ ឬ (iii) អង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ"[130]។

---

[126] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៩។

[127] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦-១០១៨។

[128] សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៣-២៥។

[129] *សូមមើល ឧទា.* វិធាន ៦៧(១)៖ ("សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវប្រកាន់ និង បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ")។

[130] *យោង*សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) យោបល់ [ខ្វែងគ្នា] របស់ចៅក្រម Catherine MARCHI-UHEL កថាខណ្ឌ ៣៩។

65. ចៅក្រមអន្តរជាតិបញ្ជាក់ជាថ្មីថា នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ ដើម្បីអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបង្ហាញថា ជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មយ៉ាងតិចមួយក្នុងចំណោមបទឧក្រិដ្ឋដែលបានចោទប្រកាន់ អ្នកដាក់ពាក្យសុំត្រូវតែទទួលរងព្យសនកម្មផ្លូវកាយ ខាងសម្ភារៈ ឬ ខាងផ្លូវចិត្ត ដែលអ្នកដាក់ពាក្យសុំបានយកមកជាសំអាងនៅក្នុងការទាមទារសំណងជាសមូហភាព និងសំណងផ្លូវចិត្ត[131]។

66. ចៅក្រមអន្តរជាតិសង្កេតឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះចោទប្រកាន់ យឹម ទិត្យ ពីបទឧក្រិដ្ឋនានា ដែលប្រព្រឹត្តនៅក្នុងតំបន់ភូមិសាស្ត្រកំណត់មួយចំនួន[132]។ អនុលោមតាមការចោទប្រកាន់ជាក់លាក់ទាំងនេះ ដីកាដែលរងការជំទាស់កំណត់យ៉ាងត្រឹមត្រូវលើវិសាលភាពនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចទទួលយកបានចំពោះអ្នកទាំងឡាយ (i) “ដែលបានទទួលរងព្យសនកម្មនៅភូមិភាគពាយ័ព្យចាប់ពីដើមឆ្នាំ១៩៧៧ រហូតដល់ យ៉ាងហោចណាស់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩” (ii) “ដែលបានទទួលរងព្យសនកម្ម ជាផលវិបាកនៃផែនការរួមទូទាំងប្រទេសដែលត្រូវបានចោទប្រកាន់ចាប់ពីឆ្នាំ១៩៧៦ រហូតដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដើម្បីលុបបំបាត់ខ្មែរក្រោមទាំងអស់ ឬ មួយផ្នែក” (iii) “ដែលបានទទួលរងព្យសនកម្ម ជាផលវិបាកនៃឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅមន្ទីរសន្តិសុខវត្តព្រះធាតុនៅចន្លោះយ៉ាងហោចណាស់ ខែកញ្ញា ដល់ ខែតុលា ឆ្នាំ១៩៧៥ រហូតដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩” និង (iv) “ដែលបានទទួលរងព្យសនកម្ម ជាផលវិបាកនៃឧក្រិដ្ឋកម្មណាមួយដែលត្រូវបានចោទប្រកាន់នៅមន្ទីរសន្តិសុខវត្តព្រះធាតុ ទីតាំងកាប់សម្លាប់ភូមិព្រាល ទីតាំងសម្លាប់វត្តអង្គុញ ទីតាំងកាប់សម្លាប់ភូមិព្រៃស្វែង ឬ ព្រៃសាខន និងទីតាំងកាប់សម្លាប់វត្តអង្គសិរីមុន្នី”[133]។

---

[131] វិធាន ២៣ *ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៦០។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៦២។

[132] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) ទំព័រ ៧៣២-៧៤៥។

[133] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ ៣៧-៣៨។

67. ផ្ទុយពីការចោទប្រកាន់របស់សហមេធាវី[134] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលរងព្យសនកម្ម ដែលមិនមែនកើតមកពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបំពេញតាមលក្ខខណ្ឌតម្រូវនៃចំណងហេតុនិងផល អនុលោមតាម វិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុងនោះទេ។

68. ចំណុចចុងក្រោយ ចៅក្រមអន្តរជាតិពិចារណាថា ភាគច្រើននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនអាចទទួលយកបាន បានគូសបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហមេធាវី និងអ្នកដាក់ពាក្យសុំនៅក្នុងឧបសម្ព័ន្ធ ខ[135] និងឧបសម្ព័ន្ធ គ[136] អាចទទួលរងព្យសនកម្ម ដោយសារអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំ ដែលកើតឡើងក្នុងរបបខ្មែរក្រហម។ ទោះជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិរកឃើញថាព្រឹត្តិការណ៍ដែលបានពិពណ៌នា ហើយដែលបានកើតឡើងនៅខាងក្រៅភូមិភាគពាយ័ព្យ មិនមែនជាឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ក្រោមសហឧក្រិដ្ឋកម្មរួម ក ដែលគ្របដណ្តប់លើទីតាំងឧក្រិដ្ឋកម្មនៅក្នុងភូមិភាគពាយ័ព្យតែមួយនោះទេ[137]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសអង្គច្បាប់ឡើយ នៅពេលពិចារណាតែទៅលើជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅភូមិភាគពាយ័ព្យ ឬ ដោយសារបានបដិសេធអ្នកដាក់ពាក្យសុំនៅក្នុងឧបសម្ព័ន្ធ ខ និង គ របស់សហមេធាវី ដែលថាមិនជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលមានចែងក្នុងភូមិភាគនេះ។ ហេតុនេះ មូលដ្ឋានទី១(១) ត្រូវបានច្រានចោល។

### គ. មូលដ្ឋានទី១ (២)

69. អនុលោមតាមវិធាន ២៣ ស្ទួន (១) (ខ) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវ "បង្ហាញ [...] ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត"[138]។ នៅក្នុងសំណុំរឿង០០២ អង្គបុរេជំនុំជម្រះ បានពិចារណាទៅលើលក្ខណៈ

[134] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ២៦។

[135] ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.2)។

[136] ឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.3)។

[137] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦(i) ទំព័រ ៧៣២-៧៤៥។

[138] វិធាន ២៣ *ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង។

និងទំហំនៃព្យសនកម្មផ្លូវចិត្តដែលបានទទួលរង ក្នុងបរិបទនៃអំពើឃោរឃៅទ្រង់ទ្រាយធំដែលបានប្រព្រឹត្តទូទាំងប្រទេសកម្ពុជា[139] និងបានសន្មតទុកជាមុនថា មានព្យសនកម្មផ្លូវចិត្តចំពោះជនរងគ្រោះមិនផ្ទាល់ ដែលមិនមានទំនាក់ទំនងគ្រួសារជាមួយជនរងគ្រោះដោយផ្ទាល់ ប៉ុន្តែពួកគាត់ជាផ្នែកមួយនៃក្រុមគោលដៅតែមួយ[140]។ អង្គជំនុំជម្រះ សង្កេតឃើញថា៖

> ការត្រឹមតែដឹងពីជោគវាសនារបស់មនុស្សណាម្នាក់ ដែលជាជនរងគ្រោះផ្ទាល់ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើង ដោយសារការអនុវត្តគោលនយោបាយរហូតមានការប៉ះពាល់យ៉ាងដូច្នេះ វាលើសពីការរំខានផ្លូវចិត្តទៅទៀតចំពោះមនុស្សដែលមានសភាពចិត្តធម្មតា។
>
> ការរំខានបែបនេះ មិនត្រឹមតែកើតចេញពីការបានឃើញដោយផ្ទាល់នូវការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះប៉ុណ្ណោះទេ តែក៏កើតចេញពីការគំរាមកំហែងដែលកើតមានជាបន្តបន្ទាប់ ដោយសារព្រឹត្តិការណ៍ទាំងនេះអាចនឹងបង្កជាការភ័យខ្លាចដល់អ្នកដទៃទៀតដែលថា ពួកគេនឹងជួបជោគវាសនាបែបនេះដែរ ដោយសារតែពួកគេស្ថិតនៅក្នុងក្រុម ឬសហគមន៍តែមួយ ជាមួយជនរងគ្រោះផ្ទាល់នៃបទឧក្រិដ្ឋណាមួយដែលបានប្រព្រឹត្តឡើង ជាផ្នែកមួយនៃការអនុវត្តនូវគោលនយោបាយទាំងនោះ[141]។

70. ក្រោយពីធ្វើការសង្កេតបែបនេះរួចមក អង្គបុរេជំនុំជម្រះបានសម្រេចថា "ចំពោះអ្នកដាក់ពាក្យទាំងឡាយណាដែលអះអាងថាបានទទួលរងព្យសនកម្មផ្លូវចិត្ត ដែលមិនមានភាពជិតស្និទ្ធជាមួយជនរងគ្រោះផ្ទាល់នោះ អង្គបុរេជំនុំជម្រះ ត្រូវអនុវត្តតាមការសន្មតថាជាព្យសនកម្មរួម" ក្នុងការវាយតម្លៃចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"[142]។

---

[139] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៨៦។

[140] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៨៣-៩៣។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៨៣-៩៣។

[141] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៨៦។

[142] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៩៣។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៩៣។

71. នៅក្នុងរឿងក្ដីនេះ ចៅក្រមអន្តរជាតិ បញ្ជាក់ថាជនរងគ្រោះមិនផ្ទាល់ អាចបង្ហាញព្យសនកម្មផ្លូវចិត្ត ទោះបីជាពុំមានទំនាក់ទំនងគ្រួសារជាមួយជនរងគ្រោះដោយផ្ទាល់ តាមរយៈសមាជិកភាពរបស់ខ្លួននៅក្នុងក្រុមគោលដៅតែមួយ ឬសហគមន៍ក៏ដោយ[143]។ ចៅក្រមអន្តរជាតិ កត់សម្គាល់ថា ជាក់ស្ដែង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រើប្រាស់វិធីសាស្ត្រនេះ ដូចបានសន្និដ្ឋាននៅក្នុងផ្នែកពាក់ព័ន្ធនៅក្នុងដីកាសម្រេចដែលរងការជំទាស់ថា៖

> ព្យសនកម្មខាងផ្លូវចិត្ត គឺរួមបញ្ចូលទាំងព្យសនកម្ម ដែលជនរងគ្រោះផ្ទាល់ទទួលរងដោយផ្ទាល់ពីឧក្រិដ្ឋកម្ម ឬជាព្យសនកម្មដែលជនរងគ្រោះមិនផ្ទាល់ បានទទួលរងដោយសារឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើជនរងគ្រោះផ្ទាល់ ឬដោយសារព្យសនកម្មដែលជនរងគ្រោះផ្ទាល់បានទទួលរង។ ជនរងគ្រោះមិនផ្ទាល់ អាចទទួលរងព្យសនកម្មបែបនេះ ទោះបីជាគាត់គ្មានទំនាក់ទំនងគ្រួសារជាមួយនឹងជនរងគ្រោះផ្ទាល់ក៏ដោយ ពោលគឺឲ្យតែពួកគាត់ជាសមាជិកនៅក្រុមគោលដៅតែមួយ ឬក្នុងសហគមន៍តែមួយ ឬប្រសិនបើជនរងគ្រោះមិនផ្ទាល់ បានទទួលរងព្យសនកម្មដោយសារតែជនរងគ្រោះផ្ទាល់បានទទួលរង[144]។

72. ផ្អែកលើមូលដ្ឋាននេះ សហមេធាវីលើកឡើងថា "ការសន្មតអំពីការខូចខាតជាសម្ងហភាពដែលកើតចេញពីព្យសនកម្ម ដែលជនរងគ្រោះផ្ទាល់បានទទួលរង នៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគនិរតី បានពង្រីករហូតដល់សមាជិកទាំងអស់នៃក្រុម ឬសហគមន៍ដែលជាគោលដៅជាក់លាក់ដោយមិនគិតគូរអំពីទីកន្លែងរបស់ពួកគេឡើយ"[145]។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេត រម្លឹកឡើងវិញថា វិធាន ២៣ ស្ទួន (១) (ខ)នៃវិធានផ្ទៃក្នុង តម្រូវឱ្យមានទំនាក់ទំនង រវាងព្យសនកម្ម និងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ រួមទាំងទំនាក់ទំនងទៅនឹងជនរងគ្រោះមិនផ្ទាល់[146]។

---

[143] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៦៤។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៦៨។

[144] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ ៣៤។

[145] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣២។

[146] វិធាន ២៣ ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង។

73. ខុសពីសំណុំរឿង ០០២ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ ត្រូវបានកម្រិត នៅក្នុងវិសាលភាពភូមិសាស្ត្រត្រឹមតែភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំមួយកន្លែង នៅក្នុងភូមិភាគនិរតី[147]។ ជាពិសេស ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ពិពណ៌នាអំពីការកំណត់គោលដៅក្រុមជាក់លាក់ ដូចខាងក្រោម៖

> យ៉ាងហោចណាស់ ក៏ចាប់ពីដើមឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែរ ដែល យឹម ទិត្យ តាម៉ុក និងកម្មាភិបាលជាទីទុកចិត្តពីភូមិភាគនិរតី បានធ្វើប្រតិបត្តិការនៅភូមិភាគពាយ័ព្យនៃកម្ពុជាប្រជាធិបតេយ្យ ដើម្បីអនុវត្តគោលនយោបាយនានារបស់ ប.ក.ក ស្តីពី [...] ការកំណត់គោលដៅក្រុមជាក់លាក់។ អ្នកចូលរួមប្រព្រឹត្ត [...] មានចេតនា និងបានអនុវត្តគោលនយោបាយទាំងនេះ តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញ។
>
> [...]
>
> យ៉ាងហោចណាស់ ក៏ចាប់ពីដើមឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែរ ដែល យឹម ទិត្យ តាម៉ុក និងកម្មាភិបាលភូមិភាគនិរតីឯទៀតបានរួមចំណែកនៅក្នុងគោលបំណងរួម ដើម្បីអនុវត្តនៅក្នុងតំបន់ជាក់លាក់នានានៃកម្ពុជាប្រជាធិបតេយ្យ នូវផែនការទូទាំងប្រទេសមួយក្នុងការកម្ទេចទាំងស្រុង ឬមួយផ្នែកនៃខ្មែរក្រោម។ អ្នកចូលរួមប្រព្រឹត្ត [...] មានចេតនា និងបានអនុវត្តផែនការនេះ តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយការសម្លាប់សមាជិកក្រុម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ព្រមទាំងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។
>
> [...]

---

[147] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦(i) ទំព័រ ៧៣២-៧៤៥។

យឹម ទិត្យ បានចូលរួមចំណែកយ៉ាងច្រើនដល់គោលនយោបាយនានារបស់ ប.ក.ក ក្នុងការសម្លាប់ខ្មាំង ការកម្ទេចខ្មែរក្រោម និងការកំណត់គោលដៅក្រុមជាក់លាក់ រួមទាំងកម្មាភិបាល ប.ក.ក នៅភូមិភាគ ពាយ័ព្យ អតីតមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ ប្រជាជន១៧មេសា អ្នកជម្លៀសមកពីបូព៌ា និងក្រុមគ្រួសាររបស់ពួកគេ [...][148]។

74. ដូចបានកត់សម្គាល់កន្លងមក ព្យសនកម្មដែលបានពិពណ៌នាដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ ដូចបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ[149]។ ផ្ទុយទៅវិញ សហមេធាវីអះអាងថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលបានលើកឡើងនូវព្យសនកម្ម ដោយសារជាសមាជិកនៃក្រុមដែលត្រូវបានកំណត់គោលដៅជាក់លាក់ អាចទទួលយកបាន ទោះបីជាព្យសនកម្ម មិនបណ្តាលមកពីការកំណត់គោលដៅជាសមាជិកនៃក្រុមជាក់លាក់នៅក្នុងភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំមួយកន្លែងនៅក្នុងភូមិភាគនិរតីក៏ដោយ[150]។ ឧទាហរណ៍ សហមេធាវី ពិពណ៌នាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ពិន ដន (11-VSS-00027) ជាព្រះសង្ឃ ដែលត្រូវបានចាត់ទុកថាជា "ប្រជាជនថ្មី" ត្រូវបានផ្សឹក ហើយបង្ខំឱ្យចាកចេញជាមួយក្រុមគ្រួសារពីភ្នំពេញទៅខេត្តកំពង់ចាម។ គាត់ត្រូវបានបង្ខំឱ្យលើកទំនប់ និងបង្ខំឱ្យរៀបការនៅទីនោះ[151]។ គាត់ក៏បានបាត់បង់សមាជិកគ្រួសារជាច្រើន ដែលត្រូវបានចោទថាជាទាហាន លន់ នល់ ក្នុងខេត្តកំពង់ចាម[152]។ ទោះបីជាចៅក្រមអន្តរជាតិ យល់ស្របថា ការណ៍នេះអាចបង្កឱ្យមានព្យសនកម្ម និងអាចមានទំនាក់ទំនងទៅនឹងគោលនយោបាយដែលត្រូវបានអនុវត្តទូទាំងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហមក៏ដោយ ក៏ព្យសនកម្មដែលត្រូវបានចោទប្រកាន់នោះ មិនបានបង្កឡើងដោយសារការកំណត់គោលដៅលើ "ប្រជាជនថ្មី" និងអតីតមន្ត្រី

---

[148] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦(i), (ii), ១០២២ (លុបការគូសបញ្ជាក់)។

[149] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៥៦។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៥៨។

[150] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣២-៣៣។

[151] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៥(៦)។

[152] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៥(៦)។

ឃោឆានៅក្នុងភូមិភាគពាយ័ព្យ ឬ ទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំមួយកន្លែងនៅក្នុងភូមិភាគនិរតីឡើយ។ ដូច្នេះ ឧក្រិដ្ឋកម្មទាំងនេះ ពុំអាចដាក់ឱ្យ យឹម ទិត្យ ទទួលខុសត្រូវឡើយ។

75. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា លក្ខខណ្ឌតម្រូវនៃទំនាក់ទំនងហេតុផលនៅក្នុងវិធាន ២៣ ស្ទួន (១) (ខ)នៃវិធានផ្ទៃក្នុង ចែងថា ការសន្មតទុកជាមុននៃព្យសនកម្មជាសមូហភាព នៅក្នុងរឿងក្ដីបច្ចុប្បន្ន ពង្រីកដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលអាចភ្ជាប់ព្យសនកម្មរបស់ពួកគេ ជាមួយនឹងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងប្រឆាំងនឹងជនរងគ្រោះដោយផ្ទាល់នៅក្នុងភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំមួយកន្លែងនៅក្នុងភូមិភាគនិរតី ដូចបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[153]។ ចៅក្រមអន្តរជាតិ គូសបញ្ជាក់សាជាថ្មីថា ត្រឹមជាសមាជិកនៃក្រុមតែមួយដែលត្រូវបានកំណត់គោលដៅតែមួយនៅក្នុងភូមិភាគនិរតី ដោយពុំមានទំនាក់ទំនងទៅនឹងភូមិភាគពាយ័ព្យ ឬទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំមួយកន្លែងនៅក្នុងភូមិភាគនិរតី ពុំគ្រប់គ្រាន់ទេ[154]។ ទោះបីជាចៅក្រមអន្តរជាតិ កត់សម្គាល់ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីភាគច្រើនដែលមិនអាចទទួលយកបាន បានបង្ហាញនៅក្នុងសារណារបស់សហមេធាវី និងអ្នកដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ គ អាចទទួលរងព្យសនកម្មផ្លូវចិត្ត ដោយសារតែពួកគេ (ត្រូវបានមើលឃើញថា) ជាសមាជិកនៃក្រុមដែលត្រូវបានកំណត់គោលដៅជាក់លាក់ក៏ដោយ ក៏ព្យសនកម្មរបស់ពួកគេ ពុំជាប់ទាក់ទងនឹង "ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់" ក្នុងរឿងក្ដីនេះទេ។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិ យល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសក្នុងការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះទេ ហើយចៅក្រមអន្តរជាតិ ច្រានចោលមូលដ្ឋានទី ១ (២)។

---

[153] *សូមមើលផងដែរ* សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៦៨។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៧២។

[154] *សូមមើល* សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៦៨។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៧២។

01678815



មូលដ្ឋានទី១ (៣)

76. ដូចបានកត់សម្គាល់ខាងលើ អនុលោមតាមវិធាន ២៣ ស្ទួន (១) (ខ)នៃវិធានផ្ទៃក្នុង ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវ "បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត"[155]។ អង្គបុរេជំនុំជម្រះ បានសម្រេចថា "ព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានទទួលរង ត្រូវតែមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីអាចយកមកពិចារណាពីភាពអាចទទួលយកបាននៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី"[156]។

77. យឹម ទិត្យ ត្រូវចោទប្រកាន់ពីបទប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងបទរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលត្រូវបានកម្រិតក្នុងវិសាលភាពភូមិសាស្ត្រត្រឹមតែភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំមួយកន្លែងនៅក្នុងភូមិភាគនិរតី[157]។ ចៅក្រមអន្តរជាតិ កត់សម្គាល់ថា យោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ[158] ដីកាដែលរងការជំទាស់ កម្រិតវិសាលភាពនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលទំនងជាអាចទទួលយកបាន ចំពោះ (១) អ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្មនៅភូមិភាគពាយ័ព្យ ពីដើមឆ្នាំ១៩៧៧ ដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (២) អ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មដោយសារផែនការរួមទូទាំងប្រទេស ដែលបានដាក់ជាបទចោទ អនុវត្តយ៉ាងហោចណាស់ពីឆ្នាំ១៩៧៦ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដើម្បីលុបបំបាត់ខ្មែរក្រោមទាំងស្រុង ឬមួយផ្នែក" (៣) "អ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មណាមួយ [...] ដែលត្រូវ

[155] *សូមមើល* ខាងលើ កថាខណ្ឌ ៣៣-៣៤, ៣៦, ៦០។

[156] *សូមមើល* ខាងលើ កថាខណ្ឌ ៣៣-៣៤, ៣៦, ៦០។

[157] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) ទំព័រ ៧៣២-៧៤៥។

[158] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) ទំព័រ ៧៣២-៧៤៥។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០១២-១០១៧, ១០២៦-១០៣៩។

01678816



បានចោទនៅមន្ទីរសន្តិសុខវត្តប្រធាតុ យ៉ាងហោចណាស់រវាងខែកញ្ញា-តុលា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩" និង (៤) អ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្មដោយសារឧក្រិដ្ឋកម្មណាមួយ [...] ដែលត្រូវបានចោទនៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីកន្លែងសម្លាប់មនុស្សភូមិព្រេល ទីកន្លែងសម្លាប់មនុស្សវត្តអង្គញដី ទីកន្លែងសម្លាប់មនុស្សព្រៃភូមិស្លែង ឬព្រៃសុខុន និង ទីកន្លែងសម្លាប់មនុស្សវត្តអង្គសិរិមុនី"[159]។

78. ទាក់ទងនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនអាចទទួលយកបានចំនួន ២៦៨ នាក់ ដែលបានកំណត់អត្តសញ្ញាណដោយសហមេធាវី នៅក្នុងឧបសម្ព័ន្ធ ឃ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងនេះត្រូវបានលើកឡើងថាបានទទួលរងព្យសនកម្មនៅក្នុងស្រុកគិរីវង់ និងតំបន់១២ នៅក្នុងភូមិភាគនិរតី (បទចោទទី៨) និងទីតាំងផ្សេងទៀតនៅក្នុងភូមិភាគនិរតី (បទចោទទី៩)[160] ជាកន្លែងដែល យឹម ទិត្យ មាន "សិទ្ធិអំណាចជាក់ស្តែងធំទូលាយ"[161]។

79. នៅក្នុងករណីនេះ ចៅក្រមអន្តរជាតិសង្កេតឃើញថា ពុំមានសហឧក្រិដ្ឋកម្មរួម (JCE) ណាមួយក្នុងចំណោមសហឧក្រិដ្ឋកម្មរួមបី ដែលយឹម ទិត្យ ត្រូវបានអះអាងថាជាសមាជិក គ្របដណ្តប់លើស្រុកគិរីវង់ និងតំបន់១៣ និងទីតាំងផ្សេងទៀតទូទាំងភូមិភាគនិរតីឡើយ[162]។ ក្រៅពីសហឧក្រិដ្ឋកម្មរួម សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ យឹម ទិត្យ ពីបទប្រព្រឹត្តដោយផ្ទាល់ ការធ្វើផែនការ ការបញ្ជា ការទទួលខុសត្រូវរបស់ថ្នាក់លើ និងការញុះញង់ ដែលជាឧក្រិដ្ឋកម្មអន្តរជាតិ "នៅតាមតំបន់នៃការទទួលខុសត្រូវរបស់គាត់ក្រោមមុខងារ*ផ្លូវការ*របស់ខ្លួន

---

[159] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ ៣៧-៣៨ (ដែលរៀបរាប់បន្ថែមថា "ឧក្រិដ្ឋកម្មបែបនោះអាចកើតឡើងដោយសារ [យឹម] ទិត្យ") (គូសបញ្ជាក់បន្ថែម)។

[160] សំណុំរឿង ០០៤ ឧបសម្ព័ន្ធ ឃ(១)៖ គន្លឹះនៃលេខកូដសម្គាត់សម្រាប់ភូមិភាគ និងទីតាំងឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសំណុំរឿង ០០៤ ឧបសម្ព័ន្ធភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5.2.4.1 ("ឧបសម្ព័ន្ធ ឃ(១) ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.4.1)")។

[161] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៨ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៤៨-៣៥០។

[162] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦(i), (ii), (iii)។

និងនៅក្នុងអំឡុងពេលដែលគាត់បានប្រើមុខងារទាំងនោះ”[163] និងសហប្រព្រឹត្តកម្ម ការធ្វើផែនការ និងការបញ្ជា ដែលជាឧក្រិដ្ឋកម្មក្នុងស្រុក “ក្នុងតំបន់នៃការទទួលខុសត្រូវរបស់គាត់ ផ្អែកតាមសិទ្ធិអំណាចផ្លូវការរបស់ខ្លួននៅលើតំបន់យ៉ាងធំទូលាយ នៅក្នុងអំឡុងពេលដែលគាត់បានប្រើសិទ្ធិអំណាចទាំងនោះ”[164]។ សហចៅក្រមអន្តរជាតិ សង្កេតឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានចោទប្រកាន់ យឹម ទិត្យ ពីឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅតាមតំបន់ដែលគាត់មានសិទ្ធិអំណាចជាក់ស្តែងដែល “គាត់បានដើរហួសពីការផ្តល់ឱ្យគាត់ជាផ្លូវការតាមរយៈការតែងតាំងជាផ្លូវការរបស់គាត់ទៅទៀត” ឡើយ[165]។ ដូច្នេះ ប្រសិនបើព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានទទួលរង បណ្តាលមកពីឧក្រិដ្ឋកម្មដែលមិនត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេនោះ ម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងនោះ មិនបំពេញលក្ខខណ្ឌទំនាក់ទំនងហេតុផល អនុលោមតាមវិធាន ២៣ ស្ទួន (១) (ខ) នៃវិធានផ្ទៃក្នុងឡើយ។ ចៅក្រមអន្តរជាតិ កត់សម្គាល់ថា ទោះជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនអាចទទួលយកបានចំនួន ២៦៨ នាក់ ដែលមានឈ្មោះក្នុងបទចោទទី៨ និងបទចោទទី៩ ក្នុងឧបសម្ព័ន្ធ ឃ អាចទទួលរងអំពីហោរឃៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ព្យសនកម្មរបស់ពួកគាត់មិនបានបង្កឡើងដោយឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅក្នុងភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំមួយកន្លែង នៅក្នុងតំបន់១៣ នៃភូមិភាគនិរតី ដូចបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ ដូច្នេះហើយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសទេក្នុងការដកចេញអ្នកដាក់ពាក្យសុំ ដែលត្រូវបានអះអាងថាបានទទួលរងព្យសនកម្មនៅក្នុងស្រុកគិរីវង់ និងតំបន់១៣ នៅក្នុងភូមិភាគនិរតី និងទីតាំងផ្សេងទៀតនៅក្នុងភូមិភាគនិរតី[166]។ ចៅក្រមអន្តរជាតិ ច្រានចោលទឡ្ហីករណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[167] ដែលថា អ្នកដាក់ពាក្យចំនួន ២៦៨ នាក់ដែលបានទទួលរង

---

[163] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០២៦-១០៣៣ [គូសបញ្ជាក់បន្ថែម]។

[164] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០៣៦-១០៣៨ [គូសបញ្ជាក់បន្ថែម]។

[165] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០២០។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៧, ១០៣០, ១០៣៤, ១០៣៩។

[166] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ ៣៧-៣៨ *យោងទៅ* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ERN) 01178399-01178402 [គូសបញ្ជាក់បន្ថែម]។

[167] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ ៣៨។

ព្យសនកម្មទូទាំងភូមិភាគនិរតី ជាទីកន្លែងដែល យឹម ទិត្យ "មានសិទ្ធិអំណាចដាក់ស្នែងធំទូលាយ" នោះ[168] គួរត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណី។

80. ទោះជាយ៉ាងនេះក្ដី ចៅក្រមអន្តរជាតិសង្កេតឃើញថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ចំនួន៦៧នាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណដោយសហមេធាវី នៅក្នុងឧបសម្ព័ន្ធ ឃ ត្រូវបានអះអាងថា បានទទួលរងព្យសនកម្មនៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ វត្តអង្គសិរិមុនី និងទីកន្លែងសម្លាប់មនុស្សព្រៃសុខុន នៅក្នុងភូមិភាគនិរតី (បទចោទទី១-៣) សហករណ៍ធិបតី ក្នុងតំបន់១ ភូមិភាគពាយ័ព្យ (បទចោទ ទី៤) ទីកន្លែងសម្លាប់មនុស្សទួលសេះញ៉ូវ ក្នុងតំបន់២ ភូមិភាគពាយ័ព្យ (បទចោទទី៦) និងទីតាំងផ្សេងទៀតទូទាំងភូមិភាគពាយ័ព្យ (បទចោទទី៧)[169]។ ដោយកត់សម្គាល់ថា ពាក្យសុំទាំងនេះ ជាប់ទាក់ទងនឹងទីតាំងភូមិសាស្ត្រ និងទីតាំងឧក្រិដ្ឋកម្មនៅក្នុងភូមិភាគពាយ័ព្យ និងទីតាំងឧក្រិដ្ឋកម្មចំនួនបីកន្លែងនៅក្នុងភូមិភាគនិរតី ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ[170] ចៅក្រមអន្តរជាតិ ពិចារណាថា វាជាប្រយោជន៍របស់ជនរងគ្រោះ ក្នុងការពិនិត្យមើលឡើងវិញនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦៧ នាក់ ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ឃ របស់សហមេធាវី ក្រោមបទចោទ ១-៧។

81. បន្ទាប់ពីបានពិនិត្យមើលលើម្ចាស់បណ្ដឹងឧទ្ធរណ៍ចំនួន ៦៧ នាក់ ដែលបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ឃ របស់សហមេធាវី ព្រមទាំងសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបដិសេធពាក្យសុំទាំងនេះ ចៅក្រមអន្តរជាតិសង្កេតឃើញថា ផ្ទុយពីការលើកឡើងរបស់សហមេធាវី[171] ពាក្យសុំភាគច្រើនក្នុងចំណោមពាក្យសុំទាំងនេះត្រូវបានសម្រេចមិនអាចទទួលយកបាន

---

[168] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ ៣៨ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៣២, ៣៣៤-៣៣៥, ៣៤៨-៣៥០, ៣៥២, ១០៣៩។

[169] ឧបសម្ព័ន្ធ ឃ(១) ភ្ជាប់ជាមួយបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5.2.4.1)។ ចៅក្រមអន្តរជាតិសង្កេតឃើញថា ចំនួនអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានរៀបរាប់ឈ្មោះនៅក្រោមបទចោទប្រកាន់ទី ១ ដល់ ៧ នៅក្នុងឧបសម្ព័ន្ធ ឃ របស់សហមេធាវី គឺមានចំនួន ៦៧ នាក់ មិនមែន ៦៦ នាក់ ដូចបានចោទប្រកាន់នៅក្នុងសារណារបស់ពួកគេនោះទេ។ *សូមមើល* ឧបសម្ព័ន្ធ ឃ ភ្ជាប់ជាមួយបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5.2.4)។

[170] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦ ទំព័រ ៧៣២-៧៤៥។

[171] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៦ *យោងទៅ* ឧបសម្ព័ន្ធ ឃ ភ្ជាប់ជាមួយបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5.2.4)។

ដោយហេតុថា ហេតុការណ៍ដែលបានចោទប្រកាន់នៅក្នុងពាក្យសុំ បានកើតឡើងនៅក្រៅវិសាលភាពពេលវេលា ឬវិសាលភាពដែនដីនៃសំណុំរឿង[172]។

82. ទោះជាយ៉ាងនេះក្តី ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងសេចក្តីសម្រេចរបស់ខ្លួន លើភាពអាចទទួលយកបានពាក់ព័ន្ធនឹងអ្នកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០ នាក់នៅក្រោមមូលដ្ឋានទី១(៣) និងពិចារណាថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោម គួរត្រូវបានទទួលយក ដូចបានផ្តល់សំអាងហេតុនៅក្នុងឧបសម្ព័ន្ធ ១៖ ចាន់ យន់ (11-VSS-00081) ជិន សាវៃ (13-VSS-00073) ហង់ សុខខី (13-VSS-00645) ឃុត ទូច (17-VSS-00016) មែន សាមឿន (13-VSS-00680) នួន សាម៉ាន (15-VSS-00141) អោម ឆៃឡាង (13-VSS-00358) ប្រាក់ ស៊ីណាន (13-VSS-00374) សូ សារឿន (15-VSS-00073) និង ទូន ប្រុញ (11-VSS-00337)។ សរុបសេចក្តីមក ចៅក្រមអន្តរជាតិយល់ឃើញថាមូលដ្ឋានទី១ (៣) ត្រូវបានទទួលយកក្នុងផ្នែកខ្លះ សម្រាប់ពាក្យសុំតាំងចំនួន ១០ និងបដិសេធម្ចាស់បណ្តឹងឧទ្ធរណ៍ដែលនៅសេសសល់។

## ខ. មូលដ្ឋានទី២៖ ការចោទប្រកាន់ពីការខកខានមិនបានពិចារណាអង្គហេតុនានាដែលបានដកចេញ អនុលោមតាមវិធាន៦៦ ស្ទួននៃវិធានផ្ទៃក្នុង នៅក្នុងការសម្រេចអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី

### *១. អំណះអំណាង*

83. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដោយបានកម្រិតវិសាលភាពភូមិសាស្ត្រនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី និងបានដកចេញជនរងគ្រោះដែលអាចទទួលយកបានមុនពេលចេញ*ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង* ("ដីកាសម្រេច តាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង*")[173]។ ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនពិចារណាទៅលើឧក្រិដ្ឋកម្ម

---

[172] *សូមមើល ឧទា.* អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី: តូច សំអាត (12-VSS-00625), ស្វាយ សារ៉ុម (12-VSS-00617), ជួន ណារី (13-VSS-00315), អ៊ាម រ៉េត (16-VSS-00004)។

[173] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៩។

ដែលត្រូវបានចោទប្រកាន់នៅក្រៅភូមិភាគពាយ័ព្យ ឬទីតាំងជាក់លាក់ចំនួនប្រាំមួយ នៅក្នុងភូមិភាគនិរតី បណ្តាលឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើម្ចាស់បណ្តឹងឧទ្ធរណ៍[174]។

84. ក្នុងការចេញដីកាសម្រេច តាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង*[175] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកចេញការចោទប្រកាន់លើអង្គហេតុមួយចំនួនពីកិច្ចស៊ើបសួរ[176] ខណៈដែលមានការបញ្ជាក់យ៉ាងច្បាស់ថាការដកចេញនូវអង្គហេតុទាំងនេះ មិនមានអានុភាពចំពោះភាពអាចទទួលយកបានជាអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ[177]។ ទោះបីជាថ្លែងដូច្នេះម្តងហើយម្តងទៀតក៏ដោយ ក៏ដីកាសម្រេចដែលរងការជំទាស់បានកំណត់វិសាលភាពភូមិសាស្ត្រនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ដែលរារាំងប្រកបដោយប្រសិទ្ធភាពដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីមុន មិនឲ្យពួកគេបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធី[178]។ ឧទាហរណ៍ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០ ត្រូវបានសម្រេចថាមិនអាចទទួលយកបាន ទោះបីជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាបណ្តឹងរដ្ឋប្បវេណី បានទទួលរងព្យសនកម្មនៅការដ្ឋានទំនប់ត្រពាំងថ្ម ដែលជាទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធមួយ

---

[174] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៩។

[175] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៤០ *យោងទៅ*ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359)។ សហមេធាវី បញ្ជាក់បន្ថែមទៅលើ "សំណើសុំមតិយោបល់" ដែលសហចៅក្រមស៊ើបអង្កេត "គួសបញ្ជាក់ពីអង្គហេតុចំនួនដប់បី [...] ចៅក្រម មិនមានចេតនាក្នុងការស៊ើបអង្កេតបន្ថែម" ។ *សូមមើល* សំណើសុំមតិយោបល់ (D302)។

[176] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៤០ *យោងទៅ* ការចោទប្រកាន់លើអង្គហេតុដែលត្រូវបានដកចេញពីកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន៦៦ស្ទួន នៃវិធានផ្ទៃក្នុង៖ ទីកន្លែងសម្លាប់មនុស្សដំណាក់វាំង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅជិតទំនប់កង្កួត ការដ្ឋានក្នុងតំបន់៥នៃភូមិភាគពាយ័ព្យ អន្លង់វិលប្រែង និងកន្លែងសម្លាប់មនុស្សដែលពាក់ព័ន្ធការដ្ឋានភ្នំត្រជាក់ចិត្ត ទីតាំងសម្លាប់មនុស្សបន្ទាយអូរតាគ្រី មន្ទីរសន្តិសុខវត្តកណ្តាល មន្ទីរសន្តិសុខបន្ទាយនាង និងមន្ទីរសន្តិសុខធម្មយុត។

[177] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៩-៤០ *យោងទៅ* ដីកាសម្រេច តាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* កថាខណ្ឌ១៤។ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ៣៩។

[178] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៤១ *យោងទៅ*ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ៣៧-៣៨ (ក) (ខ) (គ)។

ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបីក៏ដោយ[179]។

85. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាតែទៅលើការចោទប្រកាន់ស្ថិតនៅក្នុងវិសាលភាពដែលបានកម្រិតជាថ្មីក្នុងសំណុំរឿង ០០៤ ប៉ុណ្ណោះ ហើយលើកឡើងថា ការអនុវត្តនីតិវិធីជាធម្មតា ក្នុងគោលបំណងពន្លឿនកិច្ចដំណើរការនីតិវិធី ពុំគួរដកហូតសិទ្ធិជនរងគ្រោះក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពឡើយ[180]។ ការបកស្រាយដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីផលប៉ះពាល់នៃការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ "គឺប្រឆាំងនឹងសិទ្ធិរបស់ជនរងគ្រោះ" ដែលតម្រូវឱ្យ អ.វ.ត.ក មានទស្សនៈទូលំទូលាយចំពោះភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី និងតម្រូវឱ្យចៅក្រមយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាឱ្យមានការចូលរួមរបស់ជនរងគ្រោះប្រកបដោយអត្ថន័យ[181]។

86. ជាចុងក្រោយ សហមេធាវីស្នើឱ្យអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធដោយខុសឆ្គងចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកំណត់អត្តសញ្ញាណ នៅក្នុងឧបសម្ព័ន្ធ ង របស់ពួកគេ[182] ដែលពួកគាត់បានទទួលរងព្យសនកម្មដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទីតាំងមួយចំនួន នៅក្នុង

---

[179] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៤២ *យោងទៅ* សំណុំរឿង០០៤ ឧបសម្ព័ន្ធ ង៖ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានសម្រេចមិនអាចទទួលយកបាន ដោយសារការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ ឧបសម្ព័ន្ធភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5.2.5 ("ឧបសម្ព័ន្ធ ង ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.5)")។

[180] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៤៣។

[181] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៤៤ *យោងទៅ* សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ៦១, ៦៥។

[182] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៤៥ *យោងទៅ* បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.5)។

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីមួយ និងទីបី[183] ដែលក្រោយមកត្រូវបានដកចេញ អនុលោមតាមវិធាន៦៦ ស្ទួន នៃវិធានផ្ទៃក្នុង[184]។

## ២. *ការពិភាក្សា*

87. អនុលោមតាមវិធាន៦៦ ស្ទួន (១)នៃវិធានផ្ទៃក្នុង "នៅពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត អាចសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"[185]។ យោងតាមវិធាន៦៦ ស្ទួន (៣) សហចៅក្រមស៊ើបអង្កេត ត្រូវកំណត់អំពីអានុភាពនៃសេចក្តីសម្រេចដែលបានធ្វើឡើង "ទៅលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ"[186]។

88. ចៅក្រមអន្តរជាតិសង្កេតឃើញថា បន្ទាប់ពីបញ្ចប់កិច្ចស៊ើបសួរលើ យឹម ទិត្យ[187] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញអង្គហេតុមួយចំនួនពីកិច្ចស៊ើបសួរ ("អង្គហេតុ តាមវិធាន៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង")[188] ដោយបញ្ជាក់ថា អង្គហេតុដែលនៅសេសសល់ "តំណាងឱ្យវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកា

---

[183] ទីកន្លែងសម្លាប់មនុស្សដំណាក់វាំង ការដ្ឋានទំនប់កង្ហត មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង ការដ្ឋានត្រពាំងថ្ម និងអន្លង់វិលប្រែង និងកន្លែងសម្លាប់មនុស្សដែលពាក់ព័ន្ធ។

[184] សំណុំរឿង០០៤ ឧបសម្ព័ន្ធ ខ៖ បញ្ជីឈ្មោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនអាចទទួលស្គាល់ ឧបសម្ព័ន្ធភ្ជាប់ជាមួយដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384.2 ("ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (D384.2)")។

[185] វិធាន៦៦ ស្ទួន (១) នៃវិធានផ្ទៃក្នុង។

[186] វិធាន៦៦ ស្ទួន (៣) នៃវិធានផ្ទៃក្នុង។

[187] សេចក្តីជូនដំណឹងលើកទី១ យោងតាមវិធាន ៦៦ (១) (D358)។

[188] ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359)។ *សូមមើលបន្ថែម* សំណើសុំមតិយោបល់ (D302)។ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ (D302/3)។ សេចក្តីជូនដំណឹងអំពីគោលបំណង និងការផ្អាកកិច្ចស៊ើបសួរ (D342)។ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ (ទីកន្លែងឧក្រិដ្ឋកម្មចំនួនប្រាំមួយ) (D349)។ សេចក្តីជូនដំណឹង តាមវិធាន ៦៦ ស្ទួន (២) (D354)។

01678823



សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម [របស់សហព្រះរាជអាជ្ញាអន្តរជាតិ] ផ្នែកភូមិសាស្ត្រ ពេលវេលា និងអង្គសេចក្តី ទាក់ទងនឹងលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្ម ព្រមទាំងប្រភេទជនរងគ្រោះ"[189] ហើយការដកចេញអង្គហេតុទាំងនេះ "នឹងមិនប៉ះពាល់ដល់ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរឡើយ"[190]។ បន្ថែមពីនេះ ដីកាសម្រេចដែលត្រូវបានជំទាស់ លើកឡើងថា "អង្គហេតុដែលបានដកចេញយោងតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង [...] អាចនៅតែជាមូលដ្ឋាននៃដីកាសម្រេចលើភាពអាចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី"[191]។

89. នៅពេលពិនិត្យអំពីការចោទប្រកាន់របស់សហមេធាវី ដែលថា ដីកាសម្រេចតាមវិធាន៦៦ *ស្ទួន នៃវិធានផ្ទៃក្នុង* បានកម្រិតវិសាលភាពភូមិសាស្ត្រនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីនោះ[192] ចៅក្រមអន្តរជាតិសង្កេតឃើញថា អង្គហេតុទាំងអស់អនុលោមតាមវិធាន៦៦ស្ទួន ទាក់ទងទៅនឹងទីតាំង ភូមិសាស្ត្រ និងទីតាំងឧក្រិដ្ឋកម្មនៅក្នុងភូមិពាយ័ព្យ ជាពិសេស៖

- ក. ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងសម្លាប់មនុស្សដំណាក់វាំង (តំបន់១ ភូមិភាគពាយ័ព្យ)[193]
- ខ. ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅជិតទំនប់កង្ហត (តំបន់១ ភូមិភាគពាយ័ព្យ)[194]

---

[189] ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ១២។ *សូមមើលផងដែរ* សេចក្តីជូនដំណឹង តាមវិធាន ៦៦ ស្ទួន (២) (D354) កថាខណ្ឌ ១០។

[190] ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ១៤។ *សូមមើលផងដែរ* សេចក្តីជូនដំណឹង តាមវិធាន ៦៦ ស្ទួន (២) នៃវិធានផ្ទៃក្នុង (D354) កថាខណ្ឌ១២។

[191] ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ ៣៩។

[192] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៩-៤១។

[193] ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ៤ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ (D65) កថាខណ្ឌ៩។

01678824



គ. ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការដ្ឋានក្នុងតំបន់៥ ភូមិភាគពាយ័ព្យ[195]

ឃ. អន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ (តំបន់១ ភូមិភាគពាយ័ព្យ)[196]

ង. ការដ្ឋានភ្នំត្រជាក់ចិត្ត (តំបន់១ ភូមិភាគពាយ័ព្យ)[197]

ច. ទីតាំងសម្លាប់មនុស្ស បន្ទាយអូរតាក្រី (តំបន់១ ភូមិភាគពាយ័ព្យ)[198]

ឆ. មន្ទីរសន្តិសុខវត្តកណ្តាល (តំបន់៣ ភូមិភាគពាយ័ព្យ)[199]

ជ. មន្ទីរសន្តិសុខបន្ទាយនាង (តំបន់៣ ភូមិភាគពាយ័ព្យ) [200]

ឈ. មន្ទីរសន្តិសុខវត្តធម្មយុត (តំបន់៤ ភូមិភាគពាយ័ព្យ)[201]។

---

194 ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ៤ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន (D272/1) កថាខណ្ឌ៦។

195 ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ៤ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី (D1) កថាខណ្ឌ៧១ (ទីតាំងសម្លាប់មនុស្សវត្តចំការខ្នុរ) ៧៤-៧៥ (មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង) ៧៦ (មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សភូមិចក្រី ទីតាំងសម្លាប់មនុស្សព្រៃតារ៉ុត) ៧៧ (វត្តព្រះនេត្រព្រះ និងទីតាំងសម្លាប់មនុស្ស និងឃុំឃាំងដែលពាក់ព័ន្ធ) ៧៨ (ការដ្ឋានទំនប់ត្រពាំងថ្ម) ៧៩ (ការដ្ឋានទំនប់ស្ពានស្រែង និងព្រៃរនាម)។

196 ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ៤ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ (D65) កថាខណ្ឌ ៧។

197 ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ៤ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ (D65) កថាខណ្ឌ ៧។

198 ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ៤ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី (D1) កថាខណ្ឌ ៦១។

199 ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ៤ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី (D1) កថាខណ្ឌ ៦១-៦៥។

200 ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ៤ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី (D1) កថាខណ្ឌ ៦៩។

201 ដីកាសម្រេចតាមវិធាន៦៦*ស្ទួន នៃវិធានផ្ទៃក្នុង* (D359) កថាខណ្ឌ ៤ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី (D1) កថាខណ្ឌ ៦៣-៦៤។

ហេតុដូច្នេះ ការចោទប្រកាន់របស់សហមេធាវីដែលថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខាន មិនបានពិចារណាឧក្រិដ្ឋកម្មដែលបានកើតឡើង “នៅក្រៅភូមិភាគពាយ័ព្យ ឬទីតាំងជាក់ចំនួន ៦ នៅក្នុងភូមិភាគនីរតី”[202] ក្រោមមូលដ្ឋាននេះមិនសមស្របឡើយ។ ឧក្រិដ្ឋកម្មទាំងនេះមិនដែលត្រូវបានដកចេញ អនុលោមតាមវិធាន៦៦ ស្ទួន នៃវិធានផ្ទៃក្នុងឡើយ[203]។ ចៅក្រមអន្តរជាតិក៏សង្កេតឃើញថា ដីកាសម្រេចដែលត្រូវបានជំទាស់ បានពិចារណាភាពអាចទទួលយកបាន ជាអាទិ៍ចំពោះ “អ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មនៅ**ភូមិភាគពាយ័ព្យ** ពីដើមឆ្នាំ១៩៧៧ ដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[204] ហើយអ្នកដាក់ពាក្យសុំដែលមានទំនាក់ទំនងទៅនឹងអង្គហេតុ តាមវិធាន៦៦ ស្ទួន នៃវិធានផ្ទៃក្នុង គឺត្រូវបានទទួលស្គាល់ នៅពេលដែលបំពេញនូវលក្ខខណ្ឌដែលនៅសេសសល់[205]។

---

[202] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៣៩។

[203] ចៅក្រមអន្តរជាតិសង្កេតឃើញថា សហមេធាវី ក៏ទំនងជាយោងទៅ “វិសាលភាពពេញលេញនៃឧក្រិដ្ឋកម្ម” ក្នុងសំណុំរឿង ០០៤ មុនពេលបំបែកសំណុំរឿង ០០៤/១ និង០០៤/២ ផងដែរ។ បញ្ហានេះ នឹងត្រូវពិភាក្សា ក្រោមមូលដ្ឋានទី៥។

[204] ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ ៣៧ (លើកឡើងបន្ថែមថា លក្ខខណ្ឌតម្រូវនៃទំនាក់ទំនងហេតុផលត្រូវបានបំពេញ ជាអាទិ៍ នៅពេលដែល “ព្យសនកម្មដែលអ្នកដាក់ពាក្យសុំបានទទួលរង បណ្ដាលមកពីការអនុវត្តគោលនយោបាយដែលត្រូវបានចោទប្រកាន់ <u>នៅទីតាំងណាមួយ</u> នៅក្នុងភូមិភាគពាយ័ព្យ”) (គូសបញ្ជាក់បន្ថែម)។

[205] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលរង ព្យសនកម្មដែលមានទំនាក់ទំនងទៅនឹងអង្គហេតុ តាមវិធាន៦៦ស្ទួននៃវិធានផ្ទៃក្នុង ក្នុងករណីដែលពាក្យសុំទាំងនោះបំពេញនូវលក្ខខណ្ឌដែលពាក់ព័ន្ធផ្សេងទៀត ដែលបានពិពណ៌នាក្នុងដីកាដែលរងការជំទាស់ (វិសាលភាពនៃពេលវេលា បទដ្ឋានបង្ហាញភស្តុតាង ... ។ល។)។ ឧទាហរណ៍ ប្រាក់ ការ (13-VSS-00129), ជុំ ជិប (13-VSS-00130) និង ថន សាឃត (13-VSS-00171) ទទួលរងព្យសនកម្មដែលត្រូវបានចោទប្រកាន់នៅមន្ទីរសន្តិសុខភ្នំទ្រយោង (តំបន់៥ ភូមិភាគពាយ័ព្យ)។ អ៊ុំ សាមិត (15-VSS-00047) ទទួលរងព្យសនកម្មដែលត្រូវបានចោទប្រកាន់នៅភ្នំត្រដាក់ចិត្ត (តំបន់១)។ ព្រឿង សារីម (13-VSS-00531), ពិ សារ៉េត (13-VSS-00560) និង តោ ចាន់ទី (13-VSS-00561) ទទួលរងព្យសនកម្មដែលត្រូវបានចោទប្រកាន់នៅមន្ទីរសន្តិសុខវត្តកណ្ដាល (តំបន់៣)។ ចិន ថោន (13-VSS-00140), និត ល្អួន (13-VSS-00174), ធុន ធី (13-VSS-00247) និង ពេ ចួន (13-VSS-00266) ទទួលរងព្យសនកម្មដែលត្រូវបានចោទប្រកាន់នៅទំនប់ត្រពាំងថ្ម (តំបន់៥)។ *សូមមើល* សំណុំរឿង០០៤ ឧបសម្ព័ន្ធ ក៖ បញ្ជីឈ្មោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ ឧបសម្ព័ន្ធភ្ជាប់ជាមួយដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384.1 (“ឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយ

90. ជាងនេះទៅទៀត បន្ទាប់ពីបានពិនិត្យសំអាងហេតុសម្រាប់ការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកំណត់អត្តសញ្ញាណក្នុងឧបសម្ព័ន្ធ ង របស់សហមេធាវី *(អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារតែការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ)*[206] ចៅក្រមអន្តរជាតិសង្កេតឃើញថា មិនមានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់នៅក្នុងឧបសម្ព័ន្ធនេះ ត្រូវបានបដិសេធដោយសារការកាត់បន្ថយវិសាលភាព តាមវិធាន ៦៦ ស្ទួននៃវិធានផ្ទៃក្នុងឡើយ[207]។

91. ទោះជាយ៉ាងនេះក្តី ពាក្យសុំទាំងនេះ ត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយហេតុថាសហចៅក្រមស៊ើបអង្កេត មិនមានជំនឿថា អង្គហេតុដែលត្រូវបានចោទ ដែលគាំទ្រដល់ពាក្យសុំទាំងនេះ "មានភាពពិតប្រាកដ"[208] ឬដោយហេតុថាព្រឹត្តការណ៍ បានកើតឡើងនៅក្រៅវិសាលភាពពេលវេលានៃសំណុំរឿង។ ឧទាហរណ៍ ពាក្យសុំចំនួនបួន ត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារការលើកឡើងនូវអង្គហេតុដោយអ្នកដាក់ពាក្យសុំ គឺ"ដូចគ្នាគ្រប់ពាក្យ" ដែលធ្វើឱ្យ "ពិបាកជឿជាក់ [...] ថា វាមានភាពពិតប្រាកដដែលពួកគេបានទទួលរងព្យសនកម្មជាលទ្ធផលនៃឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានចោទប្រកាន់"[209]។ អ្នកដាក់ពាក្យសុំផ្សេងទៀត ត្រូវ

---

ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (D384.1)") នៅត្រង់ ERN (EN) 01620182 បន្ទាត់ទី១, ៤, ៧-៨, ១១-១២ ERN (EN) 01620189 បន្ទាត់ទី៣, ERN (EN) 01620217 បន្ទាត់ទី ៦-៧, ERN (EN) 01620230 បន្ទាត់ទី១០។

206 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៤២, ៤៥។ ឧបសម្ព័ន្ធ ង ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.5)។

207 ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (D384.2)។

208 វិធាន២៣ ស្ទួន (១) "នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេត ត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីនោះ មានភាពពិតប្រាកដ"។ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D384) (ចៅក្រមអន្តរជាតិ) កថាខណ្ឌ៤០។

209 អ្នកដាក់ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី៖ ឈឹម សំពឿង (13-VSS-00542), ម៉្លី គិមឆាត (13-VSS-00545), ខ្វែក ប៉ាច (13-VSS-00548), ប៊ុក អឿប (13-VSS-00543)។ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (D384.2) នៅត្រង់ ERN (EN) 01620233, បន្ទាត់ទី៥-៧,៩។

បានបដិសេធ ដោយសារផ្ដល់ព័ត៌មានផ្ទុយគ្នា និងមិនស៊ីសង្វាក់គ្នានៅក្នុងចម្លើយរបស់ពួកគេ[210] ពីព្រោះពួកគាត់បានផ្ដល់ព័ត៌មានមិនគ្រប់គ្រាន់អំពី ហេតុការណ៍មួយចំនួន ឬខកខានមិនបានបញ្ជាក់ពីថិរវេលា[211]។ ជាចុងក្រោយ ពាក្យសុំមួយចំនួន ត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារតែអាយុរបស់អ្នកដាក់ពាក្យនៅពេលនោះ ដូចបានកត់ត្រាក្នុងព័ត៌មានកំណត់អត្តសញ្ញាណរបស់ពួកគេ មិនស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលពួកគេបានផ្ដល់ក្នុងពាក្យសុំ (ឧទាហរណ៍ ពួកគេត្រូវធ្វើការធ្ងន់ ខណៈដែលពួកគេបានកើតក្រោយរបបកម្ពុជាប្រជាធិបតេយ្យ)[212]។

92. សរុបសេចក្ដីមក ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានកម្រិតដោយមិនសមស្រប ទៅលើវិសាលភាពនៃភាពអាចទទួលយកបានជាដើមបណ្ដឹងរដ្ឋប្បវេណី ឬបណ្ដាលឱ្យមានផលប៉ះពាល់ដល់អ្នកដាក់ពាក្យសុំនោះទេ។ ទោះជាយ៉ាងនេះក្ដី ចៅក្រមអន្តរជាតិយល់ឃើញថាវាជាប្រយោជន៍របស់ជនរងគ្រោះក្នុងការពិនិត្យឡើងវិញ ជាពិសេសចំពោះអ្នកដាក់ពាក្យសុំដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ង របស់សហមេធាវី ដោយសារតែពាក្យសុំទាំងនេះត្រូវបានលើកឡើងថាស្ថិតនៅក្នុងវិសាលភាពដែនដីនៃសំណុំរឿងនេះ។

93. បន្ទាប់ពីពិនិត្យឡើងវិញទៅលើឧបសម្ព័ន្ធ ង របស់សហមេធាវី រួចមក ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងសេចក្ដីសម្រេចរបស់គាត់លើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ០៤ នាក់ និងពិចារណាឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីខាងក្រោមនេះ គួរតែអាចទទួលយកបាន ដូចបានលើកសំអាងហេតុនៅក្នុងឧបសម្ព័ន្ធ ២ នៃសេចក្ដីពិចារណានេះគឺ៖ ជិន សាវ៉ៃ (13-

---

[210] អ្នកដាក់ពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណី៖ ញ៉ឹក យន់ (13-VSS-00147), អោម ឆៃឡាង (13-VSS-00358), ជ្រូក ភ័ស (13-VSS-00335), ប៉ាល់ រតន: (13-VSS-00431)។ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (D384.2) នៅត្រង់ ERN (EN) 01620233, បន្ទាត់ទី៣ 01620268, បន្ទាត់ទី១០, ១២ 01620269, បន្ទាត់ទី៦។

[211] អ្នកដាក់ពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណី៖ ឃុត ខុញ (13-VSS-00085), វិញ សាម៉ុញ (13-VSS-00026)។ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (D384.2) ERN (EN) 01620233, បន្ទាត់ទី៨, ១០។

[212] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជ្រូក ភ័ស (13-VSS-00335) ជិន សាវ៉ៃ (13-VSS-00073) ឃុត ខុញ (13-VSS-00085) មុ សាមៃ (13-VSS-00057)។ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅត្រង់ ERN (EN) 01620268 បន្ទាត់ទី១២, 01620233, បន្ទាត់ទី២, ៨, ១១។

VSS-00073), ជ្រុក ភ័ស (13-VSS-00335), ឃុត ខុញ (13-VSS-00085) និង អោម ឆៃឡាង (13-VSS-00358)។

## គ. មូលដ្ឋានទី៣៖ ការចោទប្រកាន់ពីការមិនបានផ្តល់សេចក្តីសម្រេចដោយមានសំអាងហេតុ សម្រាប់ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

### *១. អំណះអំណាង*

94. សហមេធាវីបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ ដោយមិនបានផ្តល់សេចក្តីសម្រេចដោយមានសំអាងហេតុ ក្នុងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីបានលើកទឡ្ហីករណ៍ថា ដីកាសម្រេចដែលរងការជំទាស់ មិនបានបំពេញតាមបទដ្ឋានតម្រូវអប្បបរមា ដើម្បីគោរពដល់គោលការណ៍នីត្យានុកូលភាព រួមទាំងតម្លាភាព និងសច្ចភាពផ្លូវច្បាប់ ដូចដែលបានកំណត់ដោយអង្គបុរេជំនុំជម្រះឡើយ[213]។ ក្នុងកម្រិតអប្បបរមា សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវ "បង្ហាញទាំងស្រុងនូវឯកសារសម្ភារៈ ដែលចៅក្រមបានយកមកពិចារណា នៅពេលចេញសេចក្តីសម្រេច"[214]។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី មិនបានទទួលព័ត៌មានអំពីសំអាងហេតុនោះ សិទ្ធិក្នុងការទទួលបានការត្រួតពិនិត្យនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុង នឹងទៅជាគ្មានន័យ[215]។

95. សហមេធាវីបានលើកទឡ្ហីករណ៍ថា កន្លងមកអង្គបុរេជំនុំជម្រះ បានកំណត់បទដ្ឋានអប្បរមាសម្រាប់សេចក្តីសម្រេចដោយមានសំអាងហេតុ ពាក់ព័ន្ធនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២ និងបានអះអាងថា ដីកាសម្រេចដែលរងការជំទាស់ "មិន

---

[213] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៦, ៤៨ និងជើងទំព័រ ១២២ ១២២ *យោងទៅក្នុងចំណោមផ្សេងទៀត* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៧-៣៨។

[214] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៦ ដកស្រង់ សំណុំរឿង ០០២ សាលដីកាបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៩។

[215] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៦។

01678829



បានបំពេញ" តាមបទដ្ឋានទាំងអស់នោះ[216]។ សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "យ៉ាងច្រើនលើសលប់ជារួម ដោយពុំបានធ្វើការពិចារណាត្រឹមត្រូវ លើពាក្យសុំនីមួយៗនោះឡើយ"[217]។ សហមេធាវីចោទប្រកាន់ថា ដូចគ្នានៅក្នុងសំណុំរឿង ០០២ ដីកាសម្រេចដែលរងការជំទាស់ ប្រើប្រាស់សំអាងហេតុ ឬមិនមានសំអាងហេតុ ដែល "មានត្រឹមពីរបីឃ្លាខ្លីៗ ជាឃ្លាដែលគេយកមកប្រើប្រាស់ឡើងវិញ"[218]។ ដីកាសម្រេចដែលរងការជំទាស់ បានបដិសេធ "ជិតពីរភាគបីនៃម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានជាទូទៅ"[219] ហើយមានបីករណី ដែលគ្រាន់តែបញ្ជាក់ឡើងវិញនូវអង្គហេតុ ដោយមិនបានផ្តល់សំអាងហេតុ សម្រាប់ការបដិសេធនោះឡើយ[220]។ កង្វះភាពជាក់លាក់ពាក់ព័ន្ធ ធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណី មិនអាចប្រើប្រាស់ដោយប្រសិទ្ធភាព នូវសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់ខ្លួនឡើយ[221]។

96. ជាចុងក្រោយ សហមេធាវីស្នើឱ្យអង្គបុរេជំនុំជម្រះប្រាទចោលដីកាសម្រេចដែលរងការជំទាស់ ហើយករណីដែលពាក្យសុំតាំងខ្លួន ត្រូវបានរកឃើញថាមិនអាចទទួលយកបាន ដោយសារតែ "ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង" និងក្នុងករណីដែលត្រូវបានចោទថា "មិនត្រូវបានបង្ហាញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលរងព្យសនកម្ម ជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់" ឬក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ "មិនបានផ្តល់សំអាង

[216] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៦-៤៨ និងជើងទំព័រ ១២២ ១២២ យោងទៅ *ក្នុងចំណោមផ្សេងទៀត* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៧-៣៨។

[217] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៨។

[218] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៨។

[219] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៨។

[220] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៨ យោងទៅ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈុន សាម៉ន (12-VSS-00582), ញឹម កុល (12-VSS-000672) និង អ៊ី ម៉ុយ (13-VSS-00707)។

[221] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៨។

01678830



ហេតុណាមួយ" ព្រោះការបដិសេធទាំងអស់នេះគឺមិនត្រូវបានសម្រេចឡើដោយដីកាសម្រេចដែលមានសំអាងហេតុនោះឡើយ[222]។

## ២. *ការពិភាក្សា*

97. ចៅក្រមអន្តរជាតិសូមរម្លឹកថា "លក្ខខណ្ឌតម្រូវដែលថា សេចក្ដីសម្រេចទាំងអស់របស់តុលាការតម្រូវឱ្យផ្ដល់សំអាងហេតុ [...] ជាបទដ្ឋានអន្តរជាតិ"[223]។ ទីមួយ ចៅក្រមអន្តរជាតិពិចារណាថា សេចក្ដីសម្រេចដោយមានសំអាងហេតុ គឺត្រូវបានតម្រូវសម្រាប់ភាគីនានា ក្នុងការប្រើប្រាស់ដោយប្រសិទ្ធិភាព នូវសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ ស្របតាមវិធាន ៧៤ នៃវិធានផ្ទៃក្នុង[224]។ នៅក្នុងសេចក្ដីសម្រេចកន្លងមករបស់ខ្លួន អង្គជំនុំជម្រះបានសម្រេចថា ទោះបីជា "មិនមានកាតព្វកិច្ច "ផ្ដល់ការយល់ឃើញទៅលើកត្តាទាំងអស់" ដែលបានពិចារណានៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចរបស់ខ្លួននោះឡើយ សំខាន់បំផុតគឺភាគីពាក់ព័ន្ធទាំងអស់ ដឹងអំពីមូលហេតុនៃសេចក្ដីសម្រេច

[222] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៩ យោងទៅ សំណុំរឿង ០០៤ ឧបសម្ព័ន្ធ ចះ មូលដ្ឋានស្ដីពីភាពមិនអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឧបសម្ព័ន្ធនៃបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5.2.6 ("ឧបសម្ព័ន្ធ ច នៃបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D384/5.2.6)")។

[223] សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៩២។ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៨៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨ យោងទៅ សំណុំរឿង ០០២ (អបជ០៦) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ២១។

[224] សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៩២។ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៨៤។ សូមមើលផងដែរ វិធាន ៧៤ នៃវិធានផ្ទៃក្នុង ("មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ") (ជាពិសេស វិធាន ៧៤ (៤) ចែងថា៖ "ដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង" ដីការបស់ចៅក្រមស៊ើបអង្កេតប្រកាស "មិនទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី")។

នីមួយៗ"[225]។ ការនេះធ្វើឱ្យភាគីអាចធ្វើការសម្រេចច្បាស់លាស់ ថាតើប្តឹងឧទ្ធរណ៍ឬយ៉ាងណា និងប្តឹងទៅលើមូលដ្ឋានអ្វីដែរ[226]។

98. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិចារណាលើកម្រិតនៃព័ត៌មានលម្អិត ដែលតម្រូវនៅក្នុងសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត នៅពេលសម្រេចទទួលយក ឬបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយអង្គបុរេជំនុំជម្រះសម្រេចថា៖

> ជាទូទៅសេចក្តីសម្រេចរបស់តុលាការ ត្រូវបង្ហាញទាំងស្រុងនូវសម្ភារៈ ដែលចៅក្រមបានយកមកពិចារណា នៅពេលចេញសេចក្តីសម្រេច។ ចំណុចត្រង់នេះនឹងធានាថាភាគីនានាដែលមិនទទួលបានជោគជ័យ នៅក្នុងពាក្យសុំរបស់ខ្លួន អាចត្រូវបានធានាថា

---

[225] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៩២។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៨៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨ *យោងទៅ* សំណុំរឿង ០០២ (អបជ ០៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/73 កថាខណ្ឌ ៦៦។ សំណុំរឿង ០០២ (អបជ ៦៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលគាំទ្រការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទអំពីឧក្រិដ្ឋកម្ម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D365/2/10 កថាខណ្ឌ ២៤។ សូមមើលផងដែរ សំណុំរឿង ០០២ (អបជ ៦២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំង 'ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ' ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១០ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ២៣។

[226] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៩២។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៨៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ (អបជ ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំលេខ D153, D172, D173, D174, D178 និង D284 (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ នួនជា) ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/5 កថាខណ្ឌ ៤១។

01678832



> អង្គហេតុដែលបានដាក់ជូន និងការលើកឡើងរបស់ខ្លួន ទាក់ទងទៅនឹងអង្គច្បាប់ ត្រូវបានយកមកពិចារណាយ៉ាងត្រឹមត្រូវ និងពេញលេញ។ អ្នកដាក់ពាក្យសុំចូលរួម ជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ មានសិទ្ធិទទួលបាននូវការពិចារណា ទៅលើពាក្យសុំជាឯកត្តបុគ្គលរបស់ខ្លួន និងទទួលបាននូវការបង្ហាញថា ចំណុចនេះពិតជាកើតឡើងមែន បើទោះបីជាសេចក្ដីសម្រេចនោះ ត្រូវបានចេញនៅក្នុងទម្រង់មួយខ្លី និងជាតារាងក៏ដោយ[227]។

ក្នុងករណីនេះ អង្គជំនុំជម្រះពិចារណាថា ចាំបាច់ត្រូវមានសំអាងហេតុដែលលម្អិតជាងនេះ សម្រាប់ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធ ព្រោះសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតគឺ “យ៉ាងច្រើនបំផុត” ត្រឹមពីរប្រយោគដែលមួយប្រយោគ មានត្រឹមប្រាំទៅដប់ប្រាំពាក្យ ហើយមិនមានពាក់ព័ន្ធជាក់លាក់ ចំពោះពាក្យសុំតាំងខ្លួននីមួយៗផង[228]។ អង្គជំនុំជម្រះសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្ត “កំហុសលើអង្គច្បាប់ដែលលេចធ្លោ”ដោយពិភាក្សាមិនគ្រប់គ្រាន់ទៅលើមូលដ្ឋាន នៃការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[229]។

---

[227] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៩។ សូមមើលបន្ថែមទៀត សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D269/4) កថាខណ្ឌ ៩៣។ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៨៥។

[228] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៣៧, ៣៩។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៧, ៣៩។ សូមមើលបន្ថែមទៀត សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) កថាខណ្ឌ ៩៤។ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៨៥។

[229] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៩-៤០។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៩-៤០។ សូមមើលបន្ថែមទៀត សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D269/4) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៩៤។ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើ

01678833



99. នៅក្នុងសំណុំរឿងបច្ចុប្បន្ន ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងដីកាសម្រេចដែលរងការជំទាស់ បានលើកឡើងពីគោលការណ៍គតិយុត្តិ និងលក្ខណៈវិនិច្ឆ័យ ដែលគាត់បានអនុវត្ត ក្នុងការសម្រេចលើភាពអាចទទួកយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[230]។ គោលការណ៍ទាំងអស់នេះ រួមមានប្រភេទនៃជនរងគ្រោះ និងព្យសនកម្មដែលពាក់ព័ន្ធ ជាមួយពាក្យសុំតាំងខ្លួនជា ដើមបណ្ដឹងរដ្ឋប្បវេណី ទំនាក់ទំនងហេតុនិងផលដែលបានតម្រូវរវាងព្យសនកម្មដែលបានទទួលរង និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ទៅលើជនត្រូវចោទ បទដ្ឋានបង្ហាញភស្តុតាង និងភាពគ្រប់គ្រាន់នៃព័ត៌មាន[231]។ បន្ថែមលើនេះ គាត់បានកំណត់អំពីវិសាលភាពនៃពាក្យសុំតាំងខ្លួន ដែលអាចទទួលយកបាន ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ យឹម ទិត្យ ដោយពន្យល់ផងដែរថា “អ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្ម នៅភូមិភាគពាយ័ព្យ ពីដើមឆ្នាំ១៩៧៧ ឬពាក់កណ្ដាលឆ្នាំ១៩៧៧ ដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ បានបំពេញលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងហេតុផល ប្រសិនបើមានលក្ខខណ្ឌចំនួនពីរ”[232] រួមជាមួយប្រភេទអ្នកដាក់ពាក្យសុំបីក្រុមបន្ថែមទៀត[233]។ បន្ថែមលើនេះ ឧបសម្ព័ន្ធពាក់ព័ន្ធ

---

បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៨៥។

[230] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384)។

[231] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ១៣-៣៦, ៤០-៤៨។

[232] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៣៧។ (លក្ខខណ្ឌទាំងពីរនេះគឺ៖ ទីមួយ ព្យសនកម្មដែលអ្នកដាក់ពាក្យសុំបានទទួលរង បណ្ដាលមកពីការអនុវត្តគោលនយោបាយដែលត្រូវបានចោទប្រកាន់ដូចដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅទីតាំងណាមួយនៃភូមិភាគពាយ័ព្យ និង ទីពីរ តាមការចោទប្រកាន់ការអនុវត្តគោលនយោបាយទាំងនេះអាចជាអំពើប្រល័យពូជសាសន៍ដែលមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ឬ ឧក្រិដ្ឋកម្មមួយ ឬលើសពីមួយ ក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ឬឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មថ្នាក់ជាតិដែលមានចែងក្នុងមាត្រា ៣ ថ្មី នៃច្បាប់ អ.វ.ត.ក ហើយឧក្រិដ្ឋកម្មបែបនោះអាចកើតឡើងដោយសារ យឹម ទិត្យ)។

[233] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៣៨។ (អ្នកដាក់ពាក្យសុំបីប្រភេទបន្ថែមទៀតគឺ៖ ប្រភេទទី ១ គឺអ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្មដោយសារ “ផែនការរួមទូទាំងប្រទេសដែលបានដាក់ជាបទចោទ អនុវត្តយ៉ាងហោចណាស់ពីឆាំង១៩៧៦ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដើម្បីលុបបំបាត់ខ្មែរក្រោមទាំងស្រុង ឬមួយផ្នែក”, ទីពីរ គឺអ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្មដោយសារឧក្រិដ្ឋកម្មមួយចំនួន “ដែលត្រូវបានចោទនៅមន្ទីរសន្តិសុខវត្តប្រធាតុយ៉ាងហោចណាស់រវាងខែកញ្ញា-តុលា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”, ទីបី គឺអ្នកដាក់សុំណា

ជាមួយដីកាសម្រេចដែលរងការជំទាស់ បានផ្តល់នូវសំអាងហេតុបន្ថែម ពាក់ព័ន្ធភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ[234]។ ចៅក្រមអន្តរជាតិបានពិចារណាថា ដីកាសម្រេចដែលរងការជំទាស់ និងឧបសម្ព័ន្ធរបស់ដីកាសម្រេចនោះ គួរត្រូវបានបកស្រាយរួមគ្នា។

100. ទោះបីជាសហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "បានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើនលើសលប់ជារួម ដោយពុំបានធ្វើការពិចារណាត្រឹមត្រូវលើពាក្យសុំនីមួយៗនោះឡើយ"[235] ក្តី តែចៅក្រមអន្តរជាតិយល់ឃើញថា ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចដែលរងការជំទាស់[236] តាមពិតទៅបានចង្អុលបញ្ជាក់យ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណារាល់ពាក្យសុំនីមួយៗ។ ដោយផ្ទុយពីការគ្រាន់តែបញ្ជាក់ថា "ទំនាក់ទំនងហេតុនិងផលចាំបាច់ រវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុទាំងឡាយដែលស្ថិតក្រោមការស៊ើបអង្កេត មិនត្រូវបានបង្ហាញ" ដូចដែលបានធ្វើឡើងនៅក្នុងសំណុំរឿង ០០២ នោះ[237] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងឧបសម្ព័ន្ធ ខ នៃដីកាសម្រេចដែលរងការជំទាស់ បានបង្ហាញនូវមូលដ្ឋាននៃការសន្និដ្ឋានរបស់គាត់។ ពិសេសជាងនេះទៀតនោះ សហចៅក្រមស៊ើប

---

ដែលបានទទួលរងព្យសនកម្មដោយសារឧក្រិដ្ឋកម្មមួយចំនួន "ដែលត្រូវបានចោទនៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីកន្លែងសម្លាប់មនុស្សភូមិព្រេល ទីកន្លែងសម្លាប់មនុស្សវត្តអង្គញ្ចី ទីកន្លែងសម្លាប់មនុស្សភូមិព្រៃស្វែង ឬព្រៃសុខុន និងទីកន្លែងសម្លាប់មនុស្សវត្តអង្គសិរីមុនី" ដែលជាកម្មវត្ថុនៃលក្ខខណ្ឌបន្ថែម ដូចជា ភ័ស្តុតាងត្រូវបញ្ជាក់ថា ពួកគេធ្លាប់ជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែលមានចែងក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក, ឧក្រិដ្ឋកម្មមួយ ឬលើសពីមួយក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក, ឧក្រិដ្ឋកម្មមួយ ឬលើសពីមួយក្នុងចំណោមអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់ អ.វ.ត.ក, ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មថ្នាក់ជាតិដែលមានចែងក្នុងមាត្រា ៣ ថ្មី នៃច្បាប់ អ.វ.ត.ក ហើយឧក្រិដ្ឋកម្មបែបនោះអាចកើតឡើងដោយសារ យឹម ទិត្យ)។

[234] ឧបសម្ព័ន្ធ ក នៃដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384.1)។ ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (D384.2)។

[235] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៨។

[236] ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384.2)។

[237] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៧។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៧។

01678835



អង្កេតអន្តរជាតិ បានបញ្ជាក់ពីព័ត៌មានចម្បងដែលបានពិចារណា និងផ្តល់ការសន្និដ្ឋានរបស់គាត់ដែលថា "អង្គហេតុដែលបានរៀបរាប់ ស្ថិតនៅក្រៅវិសាលភាពសំណុំរឿង" ឬ "ទំនងជាពិតជាងមិនពិតដែលថា គាត់បានទទួលរងការឈឺចាប់ ដោយសារឧក្រិដ្ឋកម្មមួយ ក្នុងចំណោមឧក្រិដ្ឋកម្មដែលបានដាក់ជាបទចោទ" ដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យរបស់គាត់ទៅលើអង្គហេតុដែលបានរំឮកឡើង នៅក្នុងពាក្យសុំតាំងខ្លួននីមួយ រួមទាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទ ព្រមទាំងទីតាំង និងពេលវេលានៃឧក្រិដ្ឋកម្មនោះ[238]។

101. ចំពោះ ពាក្យសុំតាំងខ្លួនចំនួនបី ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថាមិនអាចទទួលយកបាន ដោយគ្រាន់តែបញ្ជាក់ឡើងវិញនូវអង្គហេតុ និងមិនមានសំអាងហេតុនោះ[239] ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានលុបចោលនូវការសម្រេចសន្និដ្ឋានដូចជាថា "អង្គហេតុដែលបានរៀបរាប់ ស្ថិតនៅក្រៅវិសាលភាពសំណុំរឿង"។ ទោះជាយ៉ាងនេះក្តី ចៅក្រមអន្តរជាតិពិចារណាថា សំអាងហេតុនៅពីក្រោយការបដិសេធពាក្យសុំតាំងខ្លួនចំនួនពីរ ក្នុងចំណោមពាក្យសុំតាំងខ្លួនចំនួនបីគឺមានភាពច្បាស់លាស់ តាមរយៈអង្គហេតុ

---

[238] សូមមើល ឧទាហរណ៍ *ក្នុងចំណោមផ្សេងទៀត* ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384.2) ទំព័រ ២៣ នៅត្រង់ ERN 01623028 បន្ទាត់ទី ១២ [ជ័យ ភាន] (11-VSS-00026)។ (សេចក្តីពិចារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជ័យ ភាន៖ អ្នកដាក់ពាក្យសុំបានរៀបរាប់ពី "ការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀតនៅ កំពង់សៀម និងស្រុកចម្ការលើ ខេត្តកំពង់ចាម នៅពេញមួយរបបខ្មែរក្រហម។ អំពើអមនុស្សធម៌ផ្សេងទៀត៖ ការបាត់ខ្លួនជីដូនមួយរបស់អ្នកដាក់ពាក្យសុំ នៅស្រុកចម្ការលើ" ដែលបង្កើតបានជាមូលដ្ឋាននៃការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា "អង្គហេតុដែលបានរៀបរាប់ស្ថិតនៅក្រៅវិសាលភាពសំណុំរឿង")។ សូមមើលផងដែរ ឧទាហរណ៍ ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384.2) ទំព័រ ៣៥ នៅត្រង់ ERN 01623040 បន្ទាត់ទី ៤ [គឹម សេង (11-VSS-00129)]។ (សេចក្តីពិចារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គឹម សេង៖ យោងទៅអង្គហេតុជាក់លាក់ទាក់ទងនឹងពាក្យសុំរបស់គាត់៖ អ្នកដាក់ពាក្យសុំបានរៀបរាប់ហេតុការណ៍នៅខេត្តកំពង់ស្ពឺ និង "នៅពេលដែលអ្នកដាក់ពាក្យសុំរៀបរាប់ថាត្រូវគេបង្ខំឱ្យធ្វើពលកម្មនៅខេត្តកំពង់ស្ពឺ នៅឆ្នាំ១៩៧៥-៧៦ តែគាត់ក៏អះអាងថាត្រូវបានផ្លាស់ទីទៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង នៅឆ្នាំ១៩៧៥។ ហេតុនេះ កាលៈទេសៈមិនច្បាស់លាស់ [...]" ដែលបង្កើតបានជាមូលដ្ឋាននៃការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា "អ្នកដាក់ពាក្យសុំមិនបានបញ្ជាក់ថា ទំនងជាពិតជាងមិនពិតដែលថា គាត់បានទទួលរងការឈឺចាប់ដោយសារឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានដាក់ជាបទចោទ")។

[239] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៤៨-៤៩ និង ជើងទំព័រ ១២៦ *យោងទៅ* ឈុន សាម៉ុន (12-VSS-00582), ញឹម កុល (12-VSS-00672), អ៊ី ម៉ុយ (13-VSS-00707)។

ដែលបានបញ្ជាក់ឡើងនៅក្នុងឧបសម្ព័ន្ធ ខ (ក្រោមតារាង "សំអាងហេតុមិនទទួលស្គាល់ពាក្យសុំ") ហើយវិសាលភាពនៃភាពអាចទទួលយកបាន ដែលបានកំណត់នៅក្នុងដីកាសម្រេចដែលរងការជំទាស់។

102. ទីមួយ ចំពោះឈ្មោះ អ៊ី ម៉ុយ (13-VSS-00707) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរៀបរាប់ "ស្ថានភាពរស់នៅអមនុស្សធម៌ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត (រួមមានការធ្វើបាប) មកលើអ្នកដាក់ពាក្យសុំ នៅស្រុកគីរីវង់ ខេត្តតាកែវ នៅឆ្នាំ១៩៧៦"[240] មិនពាក់ព័ន្ធជាមួយទីតាំងឧក្រិដ្ឋកម្មណាមួយ ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មទាំងប្រាំមួយ នៅភូមិភាគនិរតី[241]។ ទីពីរ ចំពោះឈ្មោះ ញឹម កុល (12-VSS-00672) អង្គហេតុដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ខ ពាក់ព័ន្ធជាមួយហេតុការណ៍នៅមន្ទីរសន្តិសុខ ស-២១ (ភ្នំពេញ) និងស្រុកកំពង់សៀម ខេត្តកំពង់ចាម (ភូមិភាគកណ្ដាល)[242] ដែលច្បាស់ណាស់គឺស្ថិតក្រៅវិសាលភាពទីតាំងភូមិសាស្ត្រនៃសំណុំរឿង ដូចដែលបានរៀបរាប់នៅក្នុងដីកាសម្រេចដែលរងការជំទាស់[243]។

---

[240] ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D384.2) ទំព័រ ៥៥ នៅត្រង់ ERN 01623060 បន្ទាត់ទី ៦ [អ៊ី ម៉ុយ]។

[241] ទោះជាយ៉ាងនេះក្ដី ចៅក្រមអន្តរជាតិបានពិនិត្យពាក្យសុំនេះ និងយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការសន្និដ្ឋានថាពាក្យស្នើសុំនេះមិនអាចទទួលយកបានទេ។ នៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា គាត់ត្រូវគេឃុំខ្លួននៅវត្តប្រធាតុ ក្នុងឆ្នាំ១៩៧៨។ ប៉ុន្តែ ក្រោយមក គាត់បានបញ្ជាក់នៅក្នុងឯកសារបន្ថែមថា គាត់មិនត្រូវបានគេឃុំខ្លួននៅក្នុងវត្តប្រធាតុទេ (ប៉ុន្តែ នៅវត្តភ្នំតូច) និងថា ហេតុការណ៍ដែលនាំឱ្យមានការឃុំខ្លួនរបស់គាត់ បានកើតឡើងនៅឆ្នាំ១៩៧៦។ ដូច្នេះហើយ មិនមានភាពស៊ីចង្វាក់គ្នារវាងហេតុការណ៍ដែលបានពិពណ៌នា និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅទីតាំងជាក់លាក់ចំនួនប្រាំមួយ នៅភូមិភាគនិរតីទេ ហើយពាក្យសុំមិនអាចទទួលយកបានទេ។ សូមមើល ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ៊ី ម៉ុយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D5/1580 នៅត្រង់ ERN 01091978-01091979។ ទម្រង់បែបបទព័ត៌មានបន្ថែមរបស់ អ៊ី ម៉ុយ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D5/1580/3 នៅត្រង់ ERN 01337572។

[242] ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D384.2) ទំព័រ ៨ នៅត្រង់ ERN 01623013 បន្ទាត់ទី ១២ [ញឹម កុល]។

[243] ទោះជាយ៉ាងនេះក្ដី ចៅក្រមអន្តរជាតិបានពិនិត្យពាក្យសុំនេះ ហើយយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការសន្និដ្ឋានថា ពាក្យសុំនេះមិនអាចទទួលយកបានទេ ពីព្រោះអង្គហេតុដែលបានពិពណ៌នានៅក្នុងពាក្យសុំ ស្ថិត

103. ជាចុងក្រោយ ចំពោះឈ្មោះ ឈុន សាម៉ន (12-VSS-00582)[244] ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរៀបរាប់អំពីអង្គហេតុដូចខាងក្រោម ដោយមិនបានបញ្ជាក់អំពីមូលហេតុ ដែលបដិសេធពាក្យសុំតាំងខ្លួន៖

> អ្នកដាក់ពាក្យសុំបានរៀបរាប់ថា ត្រូវគេចាប់ខ្លួន និងវាយនៅតំបន់២៣ និង២៤ ខេត្តស្វាយរៀង និងខេត្តព្រៃវែង។ គាត់ក៏បានរៀបរាប់អំពីការបាត់ខ្លួន បងប្អូនប្រុសសាច់ថ្លៃនៅឆ្នាំ១៩៧៦ ពីស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង និងរៀបរាប់អំពី*ការបាត់ខ្លួនបងប្អូនប្រុសគាត់ នៅឆ្នាំ១៩៧៧ ក្រោយពីគាត់ត្រូវបានបញ្ជូនទៅខេត្តបន្ទាយមានជ័យ*[...][245]។

ទោះបីជាហេតុការណ៍ដែលកើតឡើងនៅខេត្តស្វាយរៀង និងព្រៃវែង គឺច្បាស់ណាស់ថាស្ថិតក្រៅវិសាលភាពទីតាំងភូមិសាស្ត្រនៃសំណុំរឿង[246] ការបាត់ខ្លួននិង/ឬការសម្លាប់បងប្អូនប្រុសអ្នកដាក់ពាក្យសុំ នៅភ្នំយ៉ាត នៅខេត្តបន្ទាយមានជ័យ (បច្ចុប្បន្ន) (ភូមិភាគពាយ័ព្យ) នៅក្នុងឆ្នាំ១៩៧៧ គឺស្ថិតក្នុងវិសាលភាពពេលវេលា និងទីតាំងភូមិសាស្ត្រនៃសំណុំរឿង[247]។ ចំពោះពាក្យសុំតាំងខ្លួននេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ការពន្យល់ឲ្យបានគ្រប់គ្រាន់អំពីមូលហេតុដែលបដិសេធពាក្យសុំតាំងខ្លួននេះ ហើយមានកំហុសឆ្គងក្នុងការសម្រេចថា ពាក្យសុំតាំងខ្លួនមិនអាចទទួលយកបាន។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន (12-VSS-00582) គួរត្រូវបានទទួលស្គាល់។

---

នៅក្រៅវិសាលភាពដែនដីនៃសំណុំរឿង។ *សូមមើលបន្ថែម* ការវាយតម្លៃយោងតាមមូលដ្ឋានទី ៤ ឧបសម្ព័ន្ធ ៣ នៃសេចក្តីពិចារណានេះ។

[244] ចៅក្រមអន្តរជាតិកត់សម្គាល់ថា ខណៈដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន (12-VSS-00582) បានស្លាប់ មេធាវីរបស់គាត់នៅតែបន្តតំណាងឲ្យផលប្រយោជន៍របស់គាត់។ សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំធ្វើជាសិទ្ធិវន្តដើម្បីបន្តបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២១ ឯកសារ F57/1។

[245] ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384.2) ទំព័រ ៧៤ នៅត្រង់ ERN 01623079 បន្ទាត់ទី ១០ [ឈុន សាម៉ន] (គូសបញ្ជាក់បន្ថែម)។

[246] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈុន សាម៉ន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ឯកសារ D5/387។ សំណុំរឿង ០០២/២ ប្រតិចារឹកសវនាការ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ (CS) ឯកសារ D5/387/4.1។ សំណុំរឿង ០០២ ប្រតិចារឹកសវនាការ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ (CS) ឯកសារ D5/387/4.1។

[247] ទម្រង់បែបបទព័ត៌មានបន្ថែមរបស់ ឈុន សាម៉ន ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D5/387/3 នៅត្រង់ ERN 01118451-01118452។ *សូមមើលផងដែរ* ការវាយតម្លៃយោងតាមមូលដ្ឋានទី ៤ ឧបសម្ព័ន្ធ ៣ នៃសេចក្តីពិចារណានេះ។

104. ចំពោះពាក្យសុំតាំងខ្លួនដែលត្រូវបានបដិសេធដទៃទៀត ដែលមានក្នុងឧបសម្ព័ន្ធ ច នៃបណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់ការពន្យល់គ្រប់គ្រាន់ ដោយមានការយោងទៅលើព័ត៌មាននៃពាក្យសុំតាំងខ្លួនពាក់ព័ន្ធ[248]។ ឧបសម្ព័ន្ធ ខ នៅពេលអានរួមគ្នាជាមួយដីកាសម្រេចដែលរងការជំទាស់ បានបង្ហាញយ៉ាងគ្រប់គ្រាន់ នូវសម្ភារៈដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយកមកពិចារណា នៅពេលធ្វើសេចក្តីសម្រេចលើភាពអាចទទួលយកបាន ហើយបានបង្ហាញថា ពាក្យសុំតាំងខ្លួននីមួយៗ ត្រូវបាន "យកមកពិចារណាយ៉ាងត្រឹមត្រូវ និងពេញលេញ"[249]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា ដីកាសម្រេចដែលរងការជំទាស់ និងឧបសម្ព័ន្ធ ខ ដែលពាក់ព័ន្ធ គឺមានសំអាងហេតុគ្រប់គ្រាន់ ដែលអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនម្នាក់ៗ អាចដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងការបដិសេធពាក្យសុំតាំងខ្លួនរបស់គាត់បាន។ មូលដ្ឋានទីបីត្រូវបានតម្កល់ផ្នែកខ្លះ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន (12-VSS-00582) ហើយសម្រាប់ម្ចាស់បណ្តឹងឧទ្ធរណ៍ដទៃទៀត ត្រូវបានបដិសេធ។

## ឃ. មូលដ្ឋានទី៤៖ ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ និងកំហុសអង្គហេតុចំពោះការមិនបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់

### *១. អំណះអំណាង*

105. សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ដោយបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់[250]។ សហមេធាវីបានចោទប្រកាន់ថា បទដ្ឋានបង្ហាញភស្តុតាង និងភាពគ្រប់គ្រាន់នៃព័ត៌មាន ដូចដែលបានតម្រូវតាមវិធាន ២៣ស្ទួន(១) និង (៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៣.២ នៃសេចក្តីណែនាំអនុវត្ត ត្រូវបានបំពេញ[251]។ និយាយជារួម "ព័ត៌មានត្រូវបានចាត់

---

[248] ឧបសម្ព័ន្ធ ច នៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5.2.6)។

[249] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៩។

[250] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥០។

[251] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥០-៥១ *យោងទៅ* សំណុំរឿង ០០៤ ឧបសម្ព័ន្ធ ឆ(១)៖ ទឡ្ហីករណ៍លើភាពអាចទទួលយកបាន សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសម្រេចថាមិន

ទុកថាគ្រប់គ្រាន់ នៅពេលដែលព័ត៌មាននោះអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតជឿជាក់បានថា អង្គហេតុដែលបានអះអាង អាចជាការពិត"[252]។

106. តាមទស្សនៈរបស់សហមេធាវី គោលដៅនិងគោលបំណងនៃវិធាន ២៣ស្ទួន នៃវិធានផ្ទៃក្នុង គឺមិនរឹត បណ្តឹង ឬកម្រិតកំណត់ទស្សនៈនៃបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក[253] ឡើយ ហើយវិធាននេះចាំបាច់ត្រូវអានរួមជាមួយវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលចែងកំណត់អំពី ភារកិច្ចជាមូលដ្ឋានក្នុងការការពារ ផលប្រយោជន៍របស់ជនរងគ្រោះ[254]។ សហចៅក្រមស៊ើបអង្កេត "ត្រូវតែសម្រេចថា តើមានមូលដ្ឋានដែលអាចជឿជាក់បានជាបឋមដែរឬទេ ដែលចង្អុលបង្ហាញថា អ្នកដាក់ពាក្យសុំបានទទួលរងព្យសនកម្ម ដែលទាក់ទងជាមួយអង្គហេតុ ដែលស្ថិតក្រោមការស៊ើបអង្កេត ដោយផ្អែកលើមូលដ្ឋាននៃធាតុផ្សំ នៅក្នុងសំណុំរឿង"[255] និងនៅពេលសម្រេចនោះ ត្រូវធ្វើការពិចារណាទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានលើកឡើងនៅ អ.វ.ត.ក ដោយផ្អែកលើ "ស្ថានភាពពិសេសនៃជម្លោះ"[256]។ សហមេធាវីយោងទៅការទទួលស្គាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា កត្តាមួយចំនួនសម្រាលបន្ទុកទៅដល់លក្ខខណ្ឌតម្រូវក្នុងការបង្ហាញ

---

អាចទទួលយកបាន ដោយសារមិនមានភស្តុតាងគ្រប់គ្រាន ឬមូលដ្ឋានពាក់ព័ន្ធ (ក្រុមអ្នកច្បាប់ជាតិ-អន្តរជាតិ) ឧបសម្ព័ន្ធភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5.2.7។ សំណុំរឿង ០០៤ ឧបសម្ព័ន្ធ ឆ(២)៖ ទឡ្ហីករណ៍លើភាពអាចទទួលយកបាន សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសម្រេចថាមិនអាចទទួលយកបាន ដោយសារមិនមានភស្តុតាងគ្រប់គ្រាន់ ឬមូលដ្ឋានពាក់ព័ន្ធ (ក្រុមអ្នកច្បាប់ជាតិ) ឧបសម្ព័ន្ធភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5.2.7.1។

[252] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥១ *យោងទៅ* សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៥។

[253] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥២ *យោងទៅ* សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៦២។

[254] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥២ *យោងទៅ* សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៦១។

[255] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៣។

[256] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៣ ដកស្រង់ពី សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៧០។

ភស្តុតាង សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ដូចជាពេលវេលាកន្លងផុតទៅយូរ ជាដើម)[257]។

107. សហមេធាវីបានលើកឡើងបន្ថែមថា សហចៅក្រមស៊ើបអង្កេត បានរំលោភទៅលើវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង ដោយមិនបានផ្ដល់ដំណឹងដល់ជនរងគ្រោះ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី[258]។ ពួកគាត់អះអាងថា ការទទួលបានព័ត៌មានដោយត្រឹមត្រូវ និងទាន់ពេលវេលា គឺជាកត្តាគន្លឹះសំខាន់ សម្រាប់ជនរងគ្រោះដែលចង់ក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណី ព្រោះពួកគេមិនមានសិទ្ធិចូលពិនិត្យសំណុំរឿង ហើយត្រូវពឹងផ្អែកលើព័ត៌មាន ដែលចេញដោយសហចៅក្រមស៊ើបអង្កេត[259]។ សហចៅក្រមស៊ើបអង្កេត មិនបានផ្ដល់ព័ត៌មានដល់ជនរងគ្រោះ ព្រោះសហចៅក្រមស៊ើបអង្កេត បានដាក់បង្ហាញជូនដល់ជនរងគ្រោះ នូវទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ នៅរយៈពេលបីឆ្នាំបន្ទាប់ពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ហើយមិនបានបញ្ជាក់ច្បាស់ អំពីទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធជាមួយ យឹម ទិត្យ ឡើយ នៅមុនថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥[260]។ បន្ថែមលើនេះ នៅក្នុងការដាក់បង្ហាញជាលើកដំបូងរបស់ពួកគាត់ អំពីទីតាំងឧក្រិដ្ឋកម្មសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេត បានបង្កនូវការយល់ច្រឡំ និងធ្វើឱ្យបាត់បង់នូវជំនឿរបស់ជនរងគ្រោះ ចំពោះលទ្ធផលនៃការស៊ើបសួរ ដោយការកត់សម្គាល់អំពី ""មន្ទិលសង្ស័យខ្លាំងក្លា" របស់ពួកគាត់ អំពីបញ្ហាថាតើសំណុំរឿង ០០៤ នឹងបន្តទៅមុខដែរឬយ៉ាងណា"[261]។ នៅក្នុងសារណារបស់សហមេធាវី អង្គជំនុំជម្រះគួរតែធ្វើការពិចារណា អំពីការ

---

[257] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៤ *យោងទៅ* ដីកាសម្រេចលើ ដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៤១។

[258] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៥ *យោងទៅ* វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង ។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៥២។

[259] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៥។

[260] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៥

[261] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៥ ដកស្រង់ សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤ (០០៤/០៧-០៩-២០០៩-អវតក/កសចស)" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកមើលបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/press-release-co-investigating-judges-regarding-civil-parties-case-004។

01678841



រំលោភបំពានទៅលើសិទ្ធិរបស់ជនរងគ្រោះនេះ ដោយសារតែការដែលសហចៅក្រមស៊ើបអង្កេត មិនបានដាក់បង្ហាញនូវព័ត៌មានឱ្យទាន់ពេលវេលា ធ្វើឱ្យរារាំងដល់លទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការបំពេញកិច្ចស៊ើបសួរទាន់ពេលវេលា ធ្វើការវិភាគឱ្យបានត្រឹមត្រូវទៅលើភស្តុតាងពាក់ព័ន្ធ និងផ្តល់នូវព័ត៌មានលម្អិតអំពីព្យសនកម្មពាក់ព័ន្ធនានា[262]។ ការនេះគឺជា "កត្តាសម្រាលបន្ថែមទៀត សម្រាប់ការបង្ហាញភស្តុតាងអំពីព្យសនកម្ម"[263]។

108. ហេតុដូច្នេះ សហមេធាវីស្នើសុំដល់អង្គបុរេជំនុំជម្រះ បដិសេធនូវការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើភាពមិនអាចទទួលយកបានរបស់ជនរងគ្រោះ ដែលត្រូវបានបដិសេធចោល ដោយផ្អែកលើមូលដ្ឋានពាក់ព័ន្ធនឹងភាពគ្រប់គ្រាន់ និងគុណភាពនៃព័ត៌មាន[264] ហើយជាលទ្ធផលត្រូវផ្តល់នូវឋានៈ ជាដើមបណ្តឹងរដ្ឋប្បវេណី ដល់ជនរងគ្រោះទាំងអស់នេះ[265]។

## *២. ការពិភាក្សា*

109. អនុលោមតាមវិធាន ២៣ស្ទួន(៤) នៃវិធានផ្ទៃក្នុង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ចាំបាច់ត្រូវមានព័ត៌មានគ្រប់គ្រាន់ ដើម្បីអាចផ្ទៀងផ្ទាត់បាន អំពីភាពសមស្របរបស់ពាក្យសុំតាំងខ្លួន ជាមួយវិធានផ្ទៃក្នុង[266]។ ជាពិសេស "ពាក្យបណ្តឹងត្រូវផ្តល់ព័ត៌មានលម្អិត អំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្ម ដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬការបង្ហាញអំពីវិទ្ធភាពរបស់ឧក្រិដ្ឋជន ដែលត្រូវចោទប្រកាន់"[267]។ ដោយពិចារណាថា គោលដៅនិងគោលបំណងនៃវិធានទាំងនេះ គឺមិនមែន "រឹតបន្តឹង

[262] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៥។

[263] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៥។

[264] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៦ និងជើងទំព័រ ១៣៩-១៤១។

[265] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៧ (ពាក់ព័ន្ធជនរងគ្រោះ ដែលសហមេធាវីបានកំណត់អត្តសញ្ញាណ នៅក្នុងឧបសម្ព័ន្ធ ឆ(១) និង ឆ(២) នៃបណ្តឹងឧទ្ធរណ៍របស់ពួកគេ)។

[266] វិធាន ២៣ស្ទួន(៤) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ០២/២០០៧/វិ.លើកទី១ ធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ("សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ") មាត្រា ៣.២, ៣.៥, ៣.៦។

[267] វិធាន ២៣ស្ទួន(៤) នៃវិធានផ្ទៃក្នុង។

01678842



ឬកំណត់ទៅលើសកម្មភាពរបស់ជនរងគ្រោះ ឬសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក នោះទេ" ប៉ុន្តែវិធាននេះបង្កើតឡើងសម្រាប់កំណត់ លក្ខណៈវិនិច្ឆ័យក្នុងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[268] នោះ អង្គបុរេជំនុំជម្រះបានអនុម័តយក "វិធីសាស្ត្រមួយដែលមានការបត់បែន" ពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌតម្រូវសម្រាប់អ្នកដាក់ពាក្យសុំទាំងអស់ ដើម្បីធ្វើការបញ្ជាក់ឲ្យបានច្បាស់ពីអត្តសញ្ញាណរបស់ខ្លួន[269]។

110. ដោយអនុលោមទៅតាមវិធាន ២៣ស្ទួន(១) នៃវិធានផ្ទៃក្នុង នៅពេលធ្វើការពិចារណាទៅលើភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ "សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះអាចជាការពិត"[270]។ ចៅក្រមអន្តរជាតិសង្កេតឃើញថា នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរកឃើញកត្តាកាលៈទេសៈមួយចំនួន ដែលសម្រាលដល់កម្រិតតម្រូវនៃការបង្ហាញភស្តុតាងអំពីព្យសនកម្ម[271] ដូចជា ក) ពេលវេលាកន្លងផុតទៅយូរ ខ) សមត្ថភាពក្នុងការកំណត់ និងកត់ត្រាផលប៉ះពាល់សុខភាពផ្លូវចិត្ត និង គ) សមត្ថភាពក្នុងការផ្តល់ភស្តុតាង អំពីកម្មសិទ្ធិ និងចំណូល ដោយសារតែការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ[272]។ ចៅក្រមអន្តរជាតិពិចារណាថា វិធីសាស្ត្រដែលមានការបត់បែននេះ សម្រាប់ភស្តុតាងជាឯកសារ និងការផ្តល់អត្តសញ្ញាណ គឺជាការសមស្របដោយពិចារណាលើមូលដ្ឋានសង្គមនិង

---

[268] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៦២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៦២។

[269] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៥។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៩៥។ សូមមើលផងដែរ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៩៤។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D269/4) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១០៥។

[270] វិធាន ២៣ស្ទួន(១) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៤។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៩៤។

[271] ដីកាសម្រេចលើ ដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៥២។

[272] ដីកាសម្រេចលើ ដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៥១។

វប្បធម៌ជាពិសេសរបស់កម្ពុជា និងកម្រិតនៃភស្តុតាងដែលអាចរកបានជាក់ស្តែង បន្ទាប់ពីមានអំពើសាហាវយង់ឃ្នង ដូចបានចោទប្រកាន់ក្នុងសំណុំរឿងនេះ[273]។

111. ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហមេធាវីបានស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យ "ធ្វើការពិចារណា" លើការចោទពីការរំលោភបំពាន ទៅលើវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង នៅពេលធ្វើការពិចារណា ទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធ[274]។ ដូចដែលចៅក្រមអន្តរជាតិបានសម្រេចកន្លងមក "ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការជូនព័ត៌មានដល់ជនរងគ្រោះឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលានោះ សហចៅក្រមស៊ើបអង្កេត ត្រូវបំពេញការងារដោយយកចិត្តទុកដាក់ ក្នុងការការពារផលប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះ ក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេតទាំងមូល"[275]។ ហេតុដូច្នេះ ចំពោះរយៈពេលចន្លោះពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ (ការបញ្ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត)[276] ដល់ពេលចេញសេចក្តីប្រកាសព័ត៌មានខែសីហា ឆ្នាំ២០១១ ចៅក្រម

---

[273] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៩៥។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D269/4) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១០៦។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣, ៩៥។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣, ៩៥។

[274] សូមមើល បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៥៥។

[275] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១០២។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៥១-៥២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៥១-៥២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់លោកស្រី សេង ចាន់ធារី (D5/1/4/2) យោបល់របស់ចៅក្រម DOWNING និងចៅក្រម LAHUIS កថាខណ្ឌ ៦។

[276] ទោះបីជាការពិតដែលថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ចុះកាលបរិច្ឆេទថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ក្តី តែចៅក្រមអន្តរជាតិសូមរំឭកថា ដីកាសន្និដ្ឋាននេះគឺជាកម្មវត្ថុនៃការខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញាទាំងពីរ។ រហូតដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ គឺបន្ទាប់ពីអង្គបុរេជំនុំជម្រះ បានចេញសេចក្តីពិចារណារបស់ខ្លួនលើការខ្វែងយោបល់គ្នានេះ ទើបដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ត្រូវបានបញ្ជូនទៅការិយាល័យ សហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរប្រឆាំង យឹម ទិត្យ។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិ នឹងចាត់ទុកថានេះគឺជាចំណុចចាប់ផ្តើមត្រឹមត្រូវ ក្នុងការវាយតម្លៃទៅលើការគោរពរបស់សហចៅក្រមស៊ើបអង្កេត ទៅតាមភារកិច្ចរបស់ខ្លួន តាម វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង។

អន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេត មិនបានដាក់បង្ហាញព័ត៌មានឱ្យទាន់ពេលវេលា ជូនទៅជនរងគ្រោះ អំពីការស៊ើបអង្កេតទៅលើ យឹម ទិត្យ ដោយរំលោភបំពានទៅលើវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង[277]។ ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមថា រហូតដល់ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ទើបទីតាំងឧក្រិដ្ឋកម្ម ពាក់ព័ន្ធនឹង យឹម ទិត្យ ត្រូវបានដាក់បង្ហាញជាសាធារណៈ[278]។

112. សំអាងហេតុដែលសហចៅក្រមស៊ើបអង្កេតបានផ្តល់ជូន អំពីការពន្យារពេលការដាក់បង្ហាញ រហូតដល់ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ អំពីទីតាំងឧក្រិដ្ឋកម្ម និងដំណាក់កាលនៃឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការស៊ើបអង្កេត គឺដោយសារតែ "មន្ទិលសង្ស័យ" របស់ពួកគាត់ អំពីសមត្ថកិច្ចយុត្តាធិការរបស់តុលាការ[279]។ ដូចគ្នាក្នុងសំណុំរឿង ០០៤/២[280] ចៅក្រមអន្តរជាតិមិនចាត់ទុកថា សំអាងហេតុនេះគឺជាសំអាងហេតុមានសុពលភាព ដើម្បីទុកចោលជនរងគ្រោះក្នុងភាពងងឹត មិនដឹងអំពីបញ្ហាដែលស្ថិតក្រោមការស៊ើបអង្កេតនោះឡើយ បើយោងទៅតាមភារកិច្ចជាកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការផ្តល់ព័ត៌មានដល់ជនរងគ្រោះ ផ្អែកតាមវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង។ រយៈពេលពីរឆ្នាំចាប់ពីពេលបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការពាក់ព័ន្ធ យឹម ទិត្យ រហូតដល់សេចក្តីប្រកាសព័ត៌មានខែសីហា ឆ្នាំ២០១១ គឺជាភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេត

---

277 *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១០៥។

278 សូមមើលសេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធសំណុំរឿង ០០៤" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ អាចរកមើលបាននៅលើគេហទំព័រ https://www.eccc.gov.kh/en/node/35023។

279 សូមមើលសេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០៤ (០០៤/០៧-០៩-២០០៩-អវតក/កសចស)" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកមើលបាននៅលើគេហទំព័រ https://www.eccc.gov.kh/en/document/public-affair/press-release-co-investigating-judges-regarding-civil-parties-case-004។

280 សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១០៧។

01678845



ក្នុងការដាក់បង្ហាញព័ត៌មាន ដើម្បីឱ្យជនរងគ្រោះដែលចាប់អារម្មណ៍ អាចចាប់ផ្ដើមត្រៀមរៀបចំឱ្យបានគ្រប់គ្រាន់ នូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[281]។

113. ដោយមិនគិតអំពីការរំលោភបំពាននេះ នៅពេលវាយតម្លៃលើដំណោះស្រាយដែលត្រូវផ្ដល់ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ព្យសនកម្មណាមួយចំពោះជនរងគ្រោះ ដែលបណ្ដាលមកពីការផ្ដល់ព័ត៌មានដោយយឺតយ៉ាវនោះ គឺហាក់ដូចជាតិចតួចបំផុត ក្នុងកាលៈទេសៈនេះ[282]។ ជាពិសេសគឺរយៈពេលជាច្រើនឆ្នាំបានកន្លងផុតទៅ បន្ទាប់ពីព័ត៌មានពាក់ព័ន្ធនានា អំពីការស៊ើបអង្កេត ត្រូវបានផ្សព្វផ្សាយជាសាធារណៈ[283] រហូតដល់កាលបរិច្ឆេទសម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដូចដែលនឹងពិភាក្សានៅផ្នែកខាងក្រោម។

114. ក្នុងន័យបនេះ បើតាមវិធាន ២៣ស្ទួន(២) នៃវិធានផ្ទៃក្នុង “ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ យ៉ាងយូរ (១៥)ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេត ជូនដំណឹងដល់ភាគីទាំងអស់ អំពីការបញ្ចប់កិច្ចស៊ើបសួរ តាមផ្លូវតុលាការដោយអនុលោមតាមវិធាន ៦៦ (១) នៃវិធានផ្ទៃក្នុង”។ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងអំពីការបិទបញ្ចប់ការស៊ើបសួរប្រឆាំង យឹម ទិត្យ ចំនួនពីរដង នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ និងថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧[284]។ ចៅក្រមអន្តរជាតិសូមរំឭកអំពីការសម្រេចកន្លងមករបស់អង្គជំនុំជម្រះដែលថា សហចៅក្រមស៊ើបអង្កេតមានកំហុសនីតិវិធី ដោយមិនបានផ្ដល់ដល់

[281] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១០៧។ *សូមមើលផងដែរ* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់លោក Robert HAMILL (D5/2/4/3) យោបល់របស់ចៅក្រម DOWNING និងចៅក្រម LAHUIS កថាខណ្ឌ ៦។

[282] សូមមើលសំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១០៩។

[283] សូមមើលសេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក “សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០៤ (០០៤/០៧-០៩-២០០៩-អវតក/កសចស)” ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកមើលបាននៅលើគេហទំព័រ https://www.eccc.gov.kh/en/document/public-affair/press-release-co-investigating-judges-regarding-civil-parties-case-004។

[284] សេចក្ដីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) ជាលើកទីមួយ (ឯកសារ D358)។ សេចក្ដីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) ជាលើកទីពីរ (ឯកសារ D368)។

ភាគីនានានូវរយៈពេល១៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងជាលើកទីពីរ អំពីការបិទបញ្ចប់ ដើម្បីស្នើសុំកិច្ចស៊ើបសួរបន្ថែមទៀត[285]។ ចៅក្រមអន្តរជាតិពិចារណាថា ការសម្រេចនេះត្រូវអនុវត្តដូចគ្នា ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងជាលទ្ធផលគឺជនរងគ្រោះ មានសិទ្ធិដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីការបិទបញ្ចប់ជាលើកទីពីរ[286]។

115. សរុបមក បើទោះបីជាចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានទៅលើកាតព្វកិច្ចរបស់ខ្លួន ក្នុងការជូនដំណឹងដល់ជនរងគ្រោះឲ្យបានទាន់ពេលវេលាក្តី តែព្យសនកម្មដែលអាចនិយាយបានថា កើតចេញពីការរំលោភបំពាននោះ គឺហាក់ដូចជាតិចតួចណាស់[287]។ រយៈពេលជាច្រើនឆ្នាំដែលបានកន្លងផុត សម្រាប់ជនរងគ្រោះក្នុងការត្រៀមរៀបចំពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នឹងអាចជួយសម្រាល ឬក៏អាចលប់បំបាត់លែងជាបញ្ហាជាក់ស្តែងទៀតហើយ[288] ចំពោះព្យសនកម្មណាមួយ ដែលអាចកើតចេញពីការពន្យារពេលរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការដាក់បង្ហាញព័ត៌មានអំពីការស៊ើបសួរ។

---

[285] សូមមើលសំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ៦៥។ សំណុំរឿង ០០៣ (អបជ ៣៥) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35 យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១៤២។

[286] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១១០។ សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) ជាលើកទីពីរ (ឯកសារ D368)។ ហេតុដូច្នេះ កាលបរិច្ឆេទកំណត់ សម្រាប់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីនេះ គឺនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៧។

[287] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១១១។

[288] ចាប់តាំងពីមានសេចក្តីប្រកាសព័ត៌មានខែសីហា ឆ្នាំ២០១១ មក ជនរងគ្រោះដែលមានសិទ្ធិដាក់ពាក្យ បានដឹងស្ទើរតែទាំងអស់ នូវទីតាំងឧក្រិដ្ឋកម្ម និងដំណាក់កាលឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការស៊ើបអង្កេត នៅភូមិភាគពាយ័ព្យ ហើយពួកគេមានរយៈពេលជាងប្រាំមួយឆ្នាំ ដើម្បីត្រៀមរៀបចំ និងផ្តល់ព័ត៌មានបន្ថែម ទៅលើពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ។ ចំពោះការចោទប្រកាន់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ សេចក្តីប្រកាសរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការចោទប្រកាន់នេះ ព្រមទាំងសេចក្តីប្រកាសព័ត៌មានជាសាធារណៈ ដែលចេញដោយសហចៅក្រមស៊ើបអង្កេត

116. សហមេធាវីមិនបានផ្តល់ឧទាហរណ៍ជាក់លាក់ អំពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឬអ្នកដាក់ពាក្យពាក្យសុំតាំងខ្លួនសក្តានុពល) ដែលទទួលរងព្យសនកម្ម ដោយសារតែការដាក់បង្ហាញមិនទាន់ពេលវេលា របស់សហចៅក្រមស៊ើបអង្កេត នូវព័ត៌មានអំពីកិច្ចស៊ើបសួរប្រឆាំង យឹម ទិត្យ។ មិនមានករណីជាក់ស្តែងណាមួយ ត្រូវបានដាក់ជូនមកអង្គបុរេជំនុំជម្រះអំពីឧទាហរណ៍ដូចជា ការចោទពីការពន្យាពេល ដែលបណ្តាលឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួន ទទួលបានព័ត៌មានពាក់ព័ន្ធនឹងពាក្យសុំរបស់ខ្លួន យឺតពេលជ្រុលមិនអាចដាក់ពាក្យបាន ឬថាជនរងគ្រោះដែលអាចដាក់ពាក្យបាន នឹងដាក់ពាក្យសុំតាំងខ្លួនបាន ប្រសិនបើសហចៅក្រមស៊ើបអង្កេត បានផ្សព្វផ្សាយព័ត៌មានឱ្យបានទាន់ពេលវេលានោះឡើយ។ ក្នុងករណីទាំងអស់នេះ ចៅក្រមអន្តរជាតិពិចារណាថា ទឡ្ហីករណ៍របស់សហមេធាវី គឺជាការទាយស្មានប៉ុណ្ណោះ[289]។

117. ចំពោះទឡ្ហីករណ៍របស់សហមេធាវី ដែលលើកឡើងថា អង្គបុរេជំនុំជម្រះគួរលើកលែង ឬបន្ធូរបន្ថយជាក់ស្តែងលើលក្ខខណ្ឌតម្រូវនីតិវិធី និងច្បាប់ជាធរមាន ដើម្បីធ្វើការពិចារណាទៅលើភាពអាចទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ចៅក្រមអន្តរជាតិបដិសេធការលើកឡើងនេះ[290]។ ដូចគ្នានេះ ចៅក្រមអន្តរជាតិកត់សម្គាល់លើសំណើសុំដំណោះស្រាយទីបីរបស់សហមេធាវី ដែលស្នើដល់អង្គជំនុំជម្រះ "ទទួលយកព័ត៌មានបន្ថែមនានា ដែលសហមេធាវីតំណាងដើមបណ្តឹង

---

អន្តរជាតិ រួមជាមួយការចោទប្រកាន់របស់គាត់ទៅលើ យឹម ទិត្យ នឹងអាចកាត់បន្ថយជាអតិបរមា ទៅលើបុរេនិច្ច័យដែលកើតឡើង នៅកម្រិតអនុវត្តជាក់ស្តែង។ សូមមើលសេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង០០៤" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ អាចរកមើលបាននៅលើគេហទំព័រ https://www.eccc.gov.kh/en/node/30196។ សូមមើលសេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០៤" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ អាចរកមើលបាននៅលើគេហទំព័រ https://www.eccc.gov.kh/en/node/35023។ បន្ថែមលើនេះសេចក្តីប្រកាសព័ត៌មានជាសាធារណៈខែធ្នូ ឆ្នាំ២០១៥ បានរៀបរាប់លម្អិតអំពីទីតាំងឧក្រិដ្ឋកម្ម នៅភូមិភាគឦសាន និងភូមិភាគពាយ័ព្យ ត្រូវបានផ្សព្វផ្សាយជិតពីរឆ្នាំមុនកាលបរិច្ឆេទកំណត់ជាធរមាន សម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០៤។

[289] សូមមើលសំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១១២។

[290] សូមមើលសំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១១៣។

រដ្ឋប្បវេណី បានដាក់ជូន"[291]។ ដោយផ្អែកលើការរំលោភបំពាន ដែលបានសម្រេចពីខាងលើ ចៅក្រមអន្តរជាតិនឹងត្រៀមរៀបចំ ធ្វើការពិចារណាលើព័ត៌មានបន្ថែមនានា ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដាក់មកដើម្បីគាំទ្រពាក្យសុំរបស់ពួកគេ ដែលរកឃើញយឺត ដោយសារតែសហចៅក្រមស៊ើបអង្កេតខកខានមិនបានជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យបានទាន់ពេលវេលា។ ប៉ុន្តែសហមេធាវីមិនបានកំណត់អត្តសញ្ញាណ ចំពោះព័ត៌មានបន្ថែមបែបនេះណាមួយឡើយ ហើយស្រដៀងគ្នានេះដែរ ចៅក្រមអន្តរជាតិមិនអាចរកឃើញឯកសារបែបនេះ នៅពេលពិនិត្យមើលទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ[292]។

118. ចៅក្រមអន្តរជាតិ បានត្រួតពិនិត្យយ៉ាងលម្អិតទៅលើទឡ្ហីករណ៍របស់សហមេធាវី ដែលបានលើកឡើងនៅក្នុងឧបសម្ព័ន្ធ ឆ(១) និង ឆ(២) សម្រាប់ការបដិសេធនូវការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធមិនទទួលស្គាល់នោះ។ ក្នុងន័យនេះ ចៅក្រមអន្តរជាតិ បានត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ទៅលើព័ត៌មានដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជូន[293] ដើម្បីធ្វើការវាយតម្លៃថាតើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសទេនៅក្នុងការវាយតម្លៃរបស់គាត់ទៅលើបញ្ហាថាតើ "អាចពិតប្រាកដ" ដែរឬទេ ដែលអ្នកដាក់ពាក្យសុំតាំងខ្លួន បានទទួលព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងវិសាលភាពពេលវេលា ឬទីតាំងភូមិសាស្ត្រនៃសំណុំរឿង៖ គឺថាយ៉ាងហោចណាស់ដោយសារឧក្រិដ្ឋកម្មមួយ ដែលបានចោទប្រកាន់ទៅលើ យឹម ទិត្យ ថាបានប្រព្រឹត្ត (ក) នៅក្នុងភូមិភាគពាយ័ព្យចាប់ពីដើមឆ្នាំ ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ (ខ) ជាផ្នែកនៃផែនការរួមទូទាំងប្រទេស ក្នុងការលុបបំបាត់ខ្មែរក្រោម ពីឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ (គ) នៅមន្ទីរសន្តិសុខ

---

[291] សូមមើល បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៦៥(៣)។

[292] នៅក្នុងសេចក្តីពិចារណានេះ ចៅក្រមអន្តរជាតិបានវាយតម្លៃទៅលើព័ត៌មានបន្ថែមដែលបានផ្តល់ជូននៅក្នុងបណ្តឹងឧទ្ធរណ៍ ក្រោយពេលចេញដីកាដែលរងការជំទាស់ រួមទាំងការកែតម្រូវអំពីថ្ងៃខែឆ្នាំកំណើតរបស់ ជិន សាវៃ (13-VSS-00073)។ ទោះបីចំណុចនេះមិនជាប់ពាក់ព័ន្ធទៅនឹងការដាក់បង្ហាញឱ្យបានទាន់ពេលវេលារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នូវការស៊ើបអង្កេតទៅលើ យឹម ទិត្យ ក្តី តែចៅក្រមអន្តរជាតិបានពិចារណាទៅលើសម្ភារៈនេះ និងបានសន្និដ្ឋានថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះគួរតែត្រូវបានទទួលយក។ *សូមមើល* ឧបសម្ព័ន្ធ ១-៣ ដែលភ្ជាប់មកជាមួយ។

[293] នៅពេលពិនិត្យមើលលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមអន្តរជាតិ បានពិនិត្យលើទម្រង់ព័ត៌មានជនរងគ្រោះ និងឧបសម្ព័ន្ធនានា និងក្នុងករណីដែលមាន ពិនិត្យរួមទាំងព័ត៌មានបន្ថែមរបស់ជនរងគ្រោះ របាយការណ៍សង្ខេប កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកសក្ខីកម្មនៅក្នុងតុលាការ ដែលអ្នកដាក់ពាក្យសុំបានផ្តល់ជូននៅចំពោះមុខ អ.វ.ត.ក។

វត្តប្រធាតុ ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ និង (ឃ) នៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្សភូមិព្រៃល ទីតាំងសម្លាប់មនុស្សវត្តអង្គញ្ញដី ទីតាំងសម្លាប់មនុស្សភូមិព្រៃស្លែង ឬព្រៃសុខុន និងទីតាំងសម្លាប់មនុស្សវត្តអង្គសិរីមុន្នី[294]។ ដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ៣ រួមមាន សេចក្តីពិចារណារបស់ចៅក្រមអន្តរជាតិ ទាក់ទិនទៅនឹងរាល់អំណះអំណាងទាំងអស់នេះ។ បន្ទាប់ពីបានពិនិត្យមើលទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងឧបសម្ព័ន្ធ ៣ រួចមក ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ទៅលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០៤ នាក់ និងពិចារណាថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោមនេះ គួរត្រូវបានទទួលស្គាល់ ដូចមានសំអាងហេតុនៅក្នុងឧបសម្ព័ន្ធ ៣៖ ទូន ប្រុញ (11-VSS-00337) ឈុន សាម៉ន (12-VSS-00582) ជិន សាវី (13-VSS-00073) និង ស្តើង មាច (13-VSS-00429)។

## ខ. មូលដ្ឋានទី ៥÷ ការចោទប្រកាន់ពីកំហុសឆ្គងត្រង់ចំណុចថា ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២ និងសំណុំរឿង ០០៤/០១ ពីសំណុំរឿង០០៤ មិនគួរកម្រិតទៅលើភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ

### *១. អំណះអំណាង*

119. សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "បកស្រាយមិនត្រឹមត្រូវ" លើដីកាសម្រេចបំបែកសំណុំរឿង ០០៤/០២ និង សំណុំរឿង០០៤/០១[295] (រួមគ្នាហៅថា "ដីកាសម្រេចបំបែកសំណុំរឿង") ដោយកម្រិតការពិចារណារបស់គាត់លើឧក្រិដ្ឋកម្មដែលបានចោទ

---

[294] វិធាន នៃវិធានផ្ទៃក្នុង ២៣*ស្ទួន*។ ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384) កថាខណ្ឌ ៣៧-៣៨។

[295] សំណុំរឿង ០០៤ ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D334/1 ("ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង០០៤ (D334/1)")។ សំណុំរឿង ០០៤ ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D286/7 ("ដីកាសម្រេចបំបែកសំណុំរឿងទាក់ទងអ៊ឹម ចែម ចេញពីសំណុំរឿង០០៤ (D286/7)")។

ប្រកាន់ នៅក្នុងសំណុំរឿង០០៤ ដែលមានលក្ខណៈទូលាយ មុនពេលបំបែកកិច្ចដំណើរការនីតិវិធី ដូច្នេះហើយទើបបណ្តាលឱ្យមានព្យសនកម្ម[296] ។

120. សហមេធាវីអះអាងថា ខណៈដែលសហចៅក្រមស៊ើបអង្កេតបង្ហាញយ៉ាងច្បាស់ នៅក្នុងដីកាសម្រេចបំបែកសំណុំរឿងថា ការបំបែកសំណុំរឿងមិនបណ្តាលឱ្យមានព្យសនកម្មដល់សិទ្ធិណាមួយឡើយ[297] និងថា វាជាផលប្រយោជន៍របស់ភាគីទាំងអស់នោះ[298] ដីកាសម្រេចដែលរងការជំទាស់កាត់បន្ថយយ៉ាងច្រើននូវវិសាលភាពពេលវេលា និងភូមិសាស្ត្រនៃភាពអាចទទួលបានជាដើមបណ្តឹងរដ្ឋប្បវេណីដែល កាលពីដំបូងគ្របដណ្តប់ដោយឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង០០៤។ ការណ៍នេះរារាំងយ៉ាងមានប្រសិទ្ធភាព ដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ទៀត ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីមុន មិនឱ្យពួកគេចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដោយកម្រិតការពិនិត្យត្រឹមតែអ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មនៅភូមិភាគពាយ័ព្យពីដើមឆ្នាំ១៩៧៧ ដល់យ៉ាងតិចថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ និង/ឬពាក់ព័ន្ធជាមួយគោលនយោបាយទូទាំងប្រទេសក្នុងការលប់បំបាត់ខ្មែរក្រោម ឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខវត្តប្រធាតុ និងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ ទៀតក្នុងភូមិភាគនិរតី[299]។

121. សហមេធាវីលើកឡើងថា ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើអានុភាពនៃដីកាសម្រេចបំបែកសំណុំរឿងទៅលើវិសាលភាពនៃឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនោះ "គឺប្រឆាំងជាមួយសិទ្ធិរបស់ជនរងគ្រោះ"[300]។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់រួចហើយថា វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យការពារផលប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះ និងថា ការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ គឺត្រូវធានាឱ្យស្របទៅនឹងគោលដៅផ្សះផ្សាជាតិរបស់ អ.វ.ត.ក[301]។

---

[296] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៥៨។

[297] ដីកាសម្រេចបំបែកសំណុំរឿង អោ អាន (D334/1) កថាខណ្ឌ ៥។

[298] ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម (D286/7) កថាខណ្ឌ ៥។

[299] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៥៩ *យោងទៅ* ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384) កថាខណ្ឌ ៣៧។

[300] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦០។

[301] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦០ *យោងទៅ* សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦១។

ដីកាដែលរងការជំទាស់បានអនុវត្តផ្ទុយពីគោលដៅនេះយ៉ាងច្បាស់ក្រឡែត ដោយកម្រិតកំណត់យ៉ាងខ្លាំងទៅលើវិសាលភាពនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤[302]។

122. ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយពុំបានពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណីមុនពេលចេញដីកាសម្រេចបំបែកសំណុំរឿងឡើយ ទោះបីជាវិធាន ៦៦ ស្ទួននៃវិធានផ្ទៃក្នុងតម្រូវថាភាគីទទួលបានឱកាសក្នុងការដាក់សារណាលើបញ្ហានានាក្តី[303]។ មិនតែប៉ុណ្ណោះ សហចៅក្រមស៊ើបអង្កេតថែមទាំងខកខានពុំបានផ្តល់សេចក្តីសម្រេច ដែលមានសំអាងហេតុទៅលើឥទ្ធិពលនៃដីកាដំណោះស្រាយទៅលើភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬ ព័ត៌មានពាក់ព័ន្ធនឹងជំហររបស់សហចៅក្រមស៊ើបអង្កេតលើធាតុផ្សំនៃវិសាលភាព នៃសំណុំរឿង ០០៤, ០០៤/១ និង ០០៤/២ តាមលក្ខខណ្ឌតម្រូវដោយវិធាន៦៦ ស្ទួន(៣) នៃវិធានផ្ទៃក្នុង[304]។ ជាងនេះទៀត ដីកាសម្រេចបំបែកសំណុំរឿងបានបណ្តាលឱ្យមានអសមធម៌ក្នុងនីតិវិធី ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ខណៈដែលអង្គភាពគាំពារជនរងគ្រោះរបស់ អ.វ.ត.ក នៅតែបន្តចុះឈ្មោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកដាក់ពាក្យសុំ ក្នុងសំណុំរឿង០០៤ ដោយមិនបានញែកដាច់ពីគ្នាទៅតាមសំណុំរឿងដែលបំបែកឡើយ[305] ដីកាសម្រេចបំបែកសំណុំរឿងបណ្តាលឱ្យមានកាលបរិច្ឆេទដាច់ពីគ្នា សម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធី ៣ ដាច់ពីគ្នាក្នុងសំណុំរឿង ០០៤[306]។

123. សហមេធាវីអះអាងថា ការបដិសេធជារួមរបស់ដីកាដែលរងការជំទាស់ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលគួរតែមានគុណវុឌ្ឍិជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ គឺផ្ទុយទៅនឹងការប្រកាសដោយផ្ទាល់របស់ដីកាសម្រេចបំបែកសំណុំរឿងដែលថា ការចេញដីកាសម្រេចនេះនឹងមិនប៉ះពាល់ដល់សិទ្ធិ ឬផលប្រយោជន៍របស់ភាគីឡើយ[307]។ ផ្ទុយទៅវិញ

---

[302] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦០។

[303] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦១។

[304] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦១។

[305] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦១។

[306] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦១ និងជើងទំព័រ ១៥០។

[307] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦២។

ដីកាសម្រេចបំបែកសំណុំរឿង "ក្លាយជាកត្តាកំណត់នៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ក្រុមអ្នកដាក់ពាក្យសុំជាច្រើន"[308]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយមិនបានពិចារណាទៅលើការចោទប្រកាន់ទ្រង់ទ្រាយធំនៅក្នុងសំណុំរឿង ០០៤ ក្នុងនោះរួមមានឧក្រិដ្ឋកម្មនៅក្នុងភូមិភាគកណ្តាល ភូមិភាគពាយ័ព្យ និង ភូមិភាគនិរតី និងពិនិត្យដោយកំហុសផ្តួងតែទៅលើការចោទប្រកាន់នៅក្នុងវង្វង់សំណុំរឿង ០០៤ ដែលមានការកម្រិតកំណត់ថ្មី[309]។ ការបំបែកកិច្ចនីតិវិធីជាធម្មតានេះ ដែលមានបំណងពន្លឿនកិច្ចដំណើរការនីតិវិធីមិនគួរដកសិទ្ធិជនរងគ្រោះក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាព នៅក្នុងកិច្ចនីតិវិធីដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងឧក្រិដ្ឋកម្មនិងគោលនយោបាយ ដែលបានធ្វើឱ្យពួកគេទទួលរងនូវព្យសនកម្មយ៉ាងធំធេងឡើយ[310]។

124. ហេតុដូច្នេះ សហមេធាវីស្នើសុំដល់អង្គបុរេជំនុំជម្រះសម្រេចថា ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើដីកាសម្រេចបំបែកសំណុំរឿង គឺបង្កព្យសនកម្មដែលមិនអាចអនុញ្ញាតបានចំពោះសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ និងស្នើបដិសេធចោលដីកាដែលរងការជំទាស់សម្រាប់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ខ, គ និង ង នៃបណ្តឹងឧទ្ធរណ៍ដែលបានទទួលរងការខូចខាតដែលជាផលវិបាកផ្ទាល់ពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០៤ មុនពេលបំបែកសំណុំរឿង[311]។

## ២. ការពិភាក្សា

125. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានបកស្រាយមិនត្រឹមត្រូវទៅលើដីកាសម្រេចបំបែកសំណុំរឿង ឬកម្រិតមិនត្រឹមត្រូវទៅលើការពិចារណាលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ នៅក្នុងសំណុំរឿង០០៤ ដែលមានលក្ខណៈទូលាយមុនពេលបំបែកកិច្ចដំណើរការនីតិវិធី ដោយដកសិទ្ធិជនរងគ្រោះក្នុងការចូលរួមប្រកបដោយអត្ថន័យនោះឡើយ។

---

308 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦២។

309 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦២។

310 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦២។

311 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦៣។

01678853



126. ទីមួយ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ចៅសហចៅក្រមអន្តរជាតិពុំបានយោងដល់ដីកាសម្រេចបំបែកសំណុំរឿងក្នុងដីកាដែលរងការជំទាស់ឡើយ[312]។ គោលការណ៍ច្បាប់ណែនាំដែលគាត់បានអនុវត្ត ក្នុងការសម្រេចភាពអាចទទួលយកបាននៃពាក្យសុំទាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺវិធាន ២៣ស្ទួន(១) នៃវិធានផ្ទៃក្នុង និងមាត្រា៣.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ[313]។ ហេតុដូច្នេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបង្ហាញចំណងទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ គឺត្រូវបានទទួលយកក្នុងសំណុំរឿង០០៤ អនុលោមតាមវិធាន២៣ស្ទួន(១)(ខ)នៃវិធានផ្ទៃក្នុង[314]។ ជាការពិត សេចក្តីសម្រេចបំបែកសំណុំរឿង ០០៤/២ និង សំណុំរឿង ០០៤/១ ពុំមានអានុភាពទៅលើការសម្រេចនេះឡើយ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានពិចារណា ឬ "បកស្រាយ" ទៅលើដីកាសម្រេចបំបែកសំណុំរឿងនោះឡើយ នៅពេលគាត់វាយតម្លៃលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

127. ជាងនេះទៀត ចៅក្រមអន្តរជាតិរម្លឹកថា ដីកាសម្រេចបំបែកសំណុំរឿងគ្រាន់តែ "ត្រួតគ្នា និងប្រមូល" ការចោទប្រកាន់លើអង្គហេតុដដែលពីសំណុំរឿង ០០៤ ដើម្បីបង្កើតសំណុំរឿង ០០៤/០២ ថ្មី ឬសំណុំរឿង ០០៤/១ ដោយទុកការចោទប្រកាន់ព្រហ្មណ្ឌក្នុងសំណុំរឿង ០០៤ ដើមដដែល[315]។ ទោះបីជាដីកាសម្រេចបំបែកសំណុំរឿងបានបំបែកការចោទប្រកាន់ព្រហ្មទណ្ឌ

---

[312] ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (D384), កថាខណ្ឌ ១២-១៦។

[313] សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២។

[314] *សូមមើលខាងលើ* គោលការណ៍គតិយុត្តិនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី (ពិភាក្សាអំពីភាពអាចទទួលយកបាននៃអ្នកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រួមមាន *ជាអាទិ៍* ការតម្រូវឲ្យមានទំនាក់ទំនងហេតុនិងផល រវាងព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ អនុលោមតាមវិធាន ២៣ ស្ទួន នៃវិធានផ្ទៃក្នុង)។

[315] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (សំអាងហេតុ) (D308/3/1/20)") កថាខណ្ឌ ៣៨-៤០ ពាក់ព័ន្ធនឹងការបំបែកសំណុំរឿង ០០៤/១ (អ៊ុំ ចែម) ចេញពីសំណុំរឿង ០០៤ កន្លងមក អង្គបុរេជំនុំជម្រះ បានសម្រេចថា "សហចៅក្រមស៊ើបអង្កេត បានបំបែកដោយប្រយោលនូវការចោទប្រកាន់ពីបទព្រហ្មទណ្ឌទាំងអស់ប្រឆាំងនឹងអ៊ុំ ចែម ដើម្បី

01678854



ទាំងអស់ប្រឆាំងនឹង អ៊ឹម ចែម និង អោ អាន ក៏ដោយ ក៏ការចោទប្រកាន់អង្គហេតុដូចគ្នា "នៅតែមានសេសសល់នៅក្នុងសំណុំរឿងដើមដែរ" ហើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅតែរក្សាឋានៈរបស់ខ្លួននៅក្នុងសំណុំរឿង ០០៤[316]។ ការកម្រិតការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី គឺដោយផ្អែកលើលក្ខខណ្ឌតម្រូវចំណងទំនាក់ទំនង អនុលោមតាមវិធាន ២៣ ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្ត។ ទឡ្ហីករណ៍របស់សហមេធាវីពាក់ព័ន្ធនឹងដីកាសម្រេចបំបែកសំណុំរឿង គឺមិនសមហេតុផលឡើយ។

128. **ទីពីរ** ចំពោះការតវ៉ារបស់សហមេធាវីដែលថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរំលោភវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង ដោយមិនបានពិគ្រោះជាមួយដើមបណ្តឹងរដ្ឋប្បវេណី "មុនពេលចេញដីកាសម្រេចបំបែកសំណុំរឿង" ឬថា ដីកាសម្រេចបំបែកសំណុំរឿងមិនបាន "រួមបញ្ចូលនូវសេចក្តីសម្រេចដោយមានសំអាងហេតុណាមួយ" ស្តីពីផលប៉ះពាល់ជាសក្តានុពលទៅលើដើមបណ្តឹងរដ្ឋប្បវេណីនោះ[317] ទឡ្ហីករណ៍ទាំងនេះមិនត្រឹមត្រូវឡើយ ដោយហេតុថា បទប្បញ្ញត្តិនេះគឺមិនពាក់ព័ន្ធឡើយ។ វិធាន៦៦ស្ទួន(១)(២)និង(៣) នៃវិធានផ្ទៃក្នុង[318] ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

> ១. ដើម្បីធានាបាននូវកិច្ចដំណើរការនីតិវិធីមួយប្រកបដោយយុត្តិធម៌ អត្តន័យ និងឆាប់រហ័ស ជាពិសេស ដោយពិចារណាលើលក្ខខណ្ឌតម្រូវជាក់លាក់នៃកិច្ចដំណើរការ

---

បង្កើតសំណុំរឿង ០០៤/០១ មិនមែនជាការបំបែកបុគ្គលទេ"។ លើសពីនេះ អង្គជំនុំជម្រះបានសម្រេចយ៉ាងច្បាស់ថា ការចោទប្រកាន់ពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌទាំងអស់ប្រឆាំងនឹង អ៊ឹម ចែម "មានភាពត្រួតគ្នា និងប្រមូលផ្តុំក្នុងសំណុំរឿង ០០៤/១ ដោយពុំមានការចោទប្រកាន់ណាមួយសេសសល់នៅក្នុងសំណុំរឿង ០០៤ ទេ"។ ជាការសំខាន់ "*រាល់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌទាំងអស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម រួមទាំងការចោទប្រកាន់នានាដែលត្រួតគ្នានៅក្នុងសំណុំរឿង ០០៤/១ ប្រឆាំងនឹង អ៊ឹម ចែម ក៏មាននៅសេសសល់ក្នុងសំណុំរឿង ០០៤ ដែរ ប្រឆាំងនឹងបុគ្គលដែលមានឈ្មោះ និងអញ្ញាតជនផ្សេងទៀត*" (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ដីកាសម្រេចបំបែកសំណុំរឿង អោ អាន (D334/1)។ ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម (D286/7)។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ (D362/6) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៧៥។

[316] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (សំអាងហេតុ) (D308/3/1/20) កថាខណ្ឌ ៣៨។

[317] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦១។

[318] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦១ ជើងទំព័រ ១៤៨ និង១៤៩។

នីតិវិធីចំពោះមុខ អ.វ.ត.ក នៅពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ សហចៅក្រមស៊ើបអង្កេតត្រូវធានាថាអង្គហេតុដែលនៅសល់ អាចយកមកធ្វើជាតំណាងចំពោះវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនិងដីកាសន្និដ្ឋាន និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

២. មុនពេលកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងអំពីព័ត៌មានលម្អិតស្តីពីគោលបំណងនៃការកាត់បន្ថយ ទៅសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀត។ ភាគីទាំងអស់ត្រូវដាក់សារណាក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយូរ។

៣. សហចៅក្រមស៊ើបអង្កេតត្រូវកំណត់អំពីអានុភាពនៃសេចក្តីសម្រេច ដែលបានធ្វើឡើង អនុលោមតាមអនុវិធាន(១)ខាងលើ ទៅលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ។

129. ភាសាសាមញ្ញនៃបទប្បញ្ញត្តិនេះអនុវត្តចំពោះការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ពោល គឺជាយន្តការគតិយុត្តិដែលខុសគ្នាទាំងស្រុងពីការបំបែកសំណុំរឿង។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា វិធាន៦៦ស្ទួន(១), (២) និង (៣) មិនអាចយកមកអនុវត្តចំពោះដីកាសម្រេចបំបែកសំណុំរឿងឡើយ។

130. ទីបី ចំពោះអសមធម៌ផ្នែករដ្ឋបាលបង្កដោយដីកាសម្រេចបំបែកសំណុំរឿង ចៅក្រមអន្តរជាតិយល់ឃើញថា ទឡ្ហីករណ៍ទាំងនេះ ដែលពាក់ព័ន្ធនឹងការបន្តចុះឈ្មោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ដោយមិនបានញែកដាច់ពីគ្នាទៅតាមសំណុំរឿងដែលបំបែក ឬកាលបរិច្ឆេទដាច់ពីគ្នាសម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណីខុសគ្នាបី[319] គឺមិនបានបង្ហាញកំហុសឆ្គងដែលអាចវិនិច្ឆ័យបាន នៅក្នុងដីកាដែលរងការជំទាស់ឡើយ។

[319] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦១ និងជើងទំព័រ ១៥០។

131. ទីបួន ពាក់ព័ន្ធនឹងការអះអាងដែលថាដីកាសម្រេចបំបែកសំណុំរឿង "ក្លាយជាកត្តាកំណត់" នៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ក្រុមអ្នកដាក់ពាក្យសុំជាច្រើន និងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើការចោទប្រកាន់ទ្រង់ទ្រាយធំ នៅក្នុងសំណុំរឿង០០៤ ដើម ក្នុងនោះរួមមានឧក្រិដ្ឋកម្មនៅក្នុងភូមិភាគកណ្តាល ភូមិភាគពាយ័ព្យ និងភូមិភាគនិរតី[320] ចៅក្រមអន្តរជាតិយល់ឃើញថា ការចោទប្រកាន់នេះគឺគ្មានមូលដ្ឋាន និងថាដីកាសម្រេចបំបែកសំណុំរឿងមិនបានកាត់បន្ថយ ឬមិនរួមបញ្ចូលដែលបណ្តាលឱ្យមានព្យសនកម្មនោះឡើយ ដូចដែលបានបដិសេធ ផ្អែកលើហេតុផលខាងលើ។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការកម្រិតវិសាលភាពនៃភាពអាចទទួលយកបាន ត្រឹមតែ *ក្នុងចំណោមបញ្ហាផ្សេងៗទៀត* ព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មយ៉ាងហោចណាស់ចំនួនមួយនៃឧក្រិដ្ឋកម្មនានាដែលចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ ដូចដែលមានចែងនៅក្នុងវិធាន ២៣ស្ទួន នៃវិធានផ្ទៃក្នុងឡើយ[321]។

132. ដោយយោងលើសំអាងហេតុខាងលើ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សារណានៃឧបសម្ព័ន្ធ ខ ឧបសម្ព័ន្ធ គ និង ឧបសម្ព័ន្ធ ង របស់សហមេធាវី[322] ពុំមានលក្ខណៈត្រឹមត្រូវសម្រាប់ធ្វើការពិចារណាទេ ហេតុដូច្នេះ បដិសេធមូលដ្ឋានទី៥[323]។

---

[320] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦២។

[321] *សូមមើល* វិធានផ្ទៃក្នុង ២៣ ស្ទួន។ *សូមមើលខាងលើផងដែរ* គោលការណ៍គតិយុត្តិនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី។

[322] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) កថាខណ្ឌ ៦៣។

[323] ចៅក្រមអន្តរជាតិ កត់សម្គាល់ថា ឧបសម្ព័ន្ធ ង ដែលសហមេធាវី បានដាក់ផងដែរ ក្រោមមូលដ្ឋានទី២ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D384/5) ត្រូវបានពិចារណា ដោយហេតុថា ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ស្ថិតនៅក្នុងវិសាលភាពដែនដីនៃសំណុំរឿងនេះ (*សូមមើលខាងលើ* មូលដ្ឋានទី២ និងឧបសម្ព័ន្ធអម ២)។

01678857



# សេចក្តីសន្និដ្ឋាន

133. ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់សហចៅក្រមស៊ើបអង្កេតជាតិ (ជាតិ)[324] មិនបានច្រានចោលជាមុននូវការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលអនាគត ដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះត្រូវបានទទួលស្គាល់ នៅក្នុងកិច្ចនីតិវិធីប្រឆាំងនឹង យឹម ទិត្យ ក្នុងពេលខាងមុខនោះឡើយ។ នៅក្នុងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតជាតិបានផ្តល់សំអាងហេតុពិសេសតែមួយ លើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង យឹម ទិត្យ[325]។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ចៅក្រមអន្តរជាតិរម្លឹកថា ការលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិគឺ *ហួសដែនអំណាច* របស់ខ្លួន ទុកជាមោឃៈ និងពុំមានអានុភាពគតិយុត្តិឡើយ[326] និងបន្ថែមថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះតម្កល់ទុកជាបានការ និងគួរបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង[327]។

134. សុពលភាពនៃដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ជាតិ) ដែលមាននៅក្នុងសំអាងហេតុនៃការលើកលែងចោទប្រកាន់ គឺមានចំណងឥស្សរចិត្ត និងមិនអាចដោះស្រាយបានចំពោះសុពលភាពគតិយុត្តនៃដីកាសម្រេចលើកលែងចោទប្រកាន់នេះផ្ទាល់។ ដោយហេតុថា ការចេញដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ពុំមានមូលដ្ឋានគតិយុត្តនៅក្នុងក្របខ័ណ្ឌជាសារវ័ន្តរបស់ អ.វ.ត.ក និងទុកជាមោឃៈពីដំបូងមក[328] ចៅក្រម

---

[324] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមជាតិ) (ឯកសារ D383)។

[325] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមជាតិ) (ឯកសារ D383) កថាខណ្ឌ ១២ ("នៅថ្ងៃនេះ យើងបានលើកលែងការចោទប្រកាន់ទាំងអស់នៅក្នុងសំណុំរឿង ០០៤ ពីព្រោះថា យឹម ទិត្យ ដែលជាជនត្រូវចោទតែម្នាក់គត់នៅក្នុងសំណុំរឿងនេះ មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឡើយ")។

[326] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (D381/45 & D382/43) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១៧៥-១៧៦។

[327] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (D381/45 & D382/43) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១៧៥-១៧៦, ៥២២-៥៣៣។

[328] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (D381/45 & D382/43) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១៧៥-១៧៦ ទំព័រ ៣៥០។

អន្តរជាតិយល់ឃើញថា ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមជាតិ) ក៏ទុកជាមោឃៈ និងមិនអាចចាត់ទុកជាអានុភាពគតិយុត្តិឡើយ។ ហេតុដូចនេះដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) គឺជាដីកាដែលកំពុងមានអានុភាពអនុវត្តលើការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤។

135. ចំពោះសំណើរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសេចក្តីសន្និដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន[329] ចៅក្រមអន្តរជាតិរម្លឹកថា "លើកលែងនិងលុះត្រាតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធចោល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីបាន"[330] និងចាត់ទុកថា សំណើដែលមានភាពប្រទាក់ក្រឡាគ្នាទាំងនេះ ត្រូវបានដោះស្រាយនៅក្នុងសំអាងហេតុ និងការសន្និដ្ឋាននានានៃសេចក្តីពិចារណាទាំងនេះរួចហើយ។

136. ហេតុដូច្នេះ ផ្អែកលើសំអាងហេតុខាងលើ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺអាចទទួលយកបាន និងបដិសេធមូលដ្ឋានទី១(១), ១(២) និង ៥។ ចៅក្រមអន្តរជាតិទុកជាបានការដោយផ្នែក និងបដិសេធដោយផ្នែកចំពោះមូលដ្ឋានទី១(៣), ២, ៣ និង ៤។ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គង នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ស្តីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រង់ចំណុច (i) មូលដ្ឋានទី១(៣) ពីព្រោះថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០ និងឯកសារពាក់ព័ន្ធគួរត្រូវបានទទួលយក (ដូចដែលមានសំអាងហេតុក្នុងឧបសម្ព័ន្ធ១)[331] (ii) មូលដ្ឋានទី២ ពីព្រោះថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤ និងឯកសារពាក់ព័ន្ធគួរត្រូវបានទទួលយក (ដូចដែលមានសំអាងហេតុក្នុងឧ

---

329 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D384/5) កថាខណ្ឌ ៦៥។

330 វិធាន ២៣ ស្ទួន (២) នៃវិធានផ្ទៃក្នុង។

331 សូមមើល មូលដ្ឋាន ១(៣) ខាងលើ ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាន់ យន់ (11-VSS-00081) ជិន សាវ៉ៃ (13-VSS-00073) ហង់ សុខានី (13-VSS-00645) ឃុត ទូច (17-VSS-00016) ម៉ែន សាមឿន (13-VSS-00680) នួន សាម៉ាន (15-VSS-00141) ប្រាក់ ស៊ីណាន (13-VSS-00374) សួរ សារឿន (15-VSS-00073) ទូន ប្រុញ (11-VSS-00337) និង អោម ផៃឡាង (13-VSS-00358)។

បសម្ព័ន្ធ ២)[332] (iii) មូលដ្ឋានទី៣ ពីព្រោះថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១ និងឯកសារពាក់ព័ន្ធគួរតែត្រូវបានទទួលយក[333] និង (iv) មូលដ្ឋានទី៤ ពីព្រោះថាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៤ និង ឯកសារពាក់ព័ន្ធគួរត្រូវបានទទួលយក (ដូចមានសំអាងហេតុក្នុងឧបសម្ព័ន្ធ៣)[334]។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១៤ ខាងក្រោមគួរត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤៖ ចាន់ យន់ (11-VSS-00081), ជិន សាវ៉ៃ (13-VSS-00073), ហង់ សុខាឌី (13-VSS-00645), ឃុត ទូច (17-VSS-00016), ម៉ែន សាមឿន (13-VSS-00680), នួន សាម៉ាន (15-VSS-00141), ប្រាក់ ស៊ីណាន (13-VSS-00374), សូរ សារឿន (15-VSS-00073), ទូន ប្រុញ (11-VSS-00337), អោម ផៃឡាង (13-VSS-00358), ជ្រុក ភ័ស (13-VSS-00335), ឃុត ខុញ (13-VSS-00085), ឈុន សាម៉ន (12-VSS-00582) និង ស្ដើង មាច (13-VSS-00429)[335]។

## វិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង

137. វិធាន៧៧ (១៣)(ក) នៃវិធានផ្ទៃក្នុងចែងថា បើសំឡេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្ដីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ ត្រូវតម្កល់ទុកជាបានការ។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចាត់ទុកជាបានការ[336]។ ដូច្នេះ ចៅក្រមអន្តរជាតិសម្រេចថា ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវបានសម្រេច

---

[332] សូមមើល មូលដ្ឋាន ២ ខាងលើ ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជិន សាវ៉ៃ (13-VSS-00073) ជ្រុក ភ័ស (13-VSS-00335) ឃុត ខុញ (13-VSS-00085) និង អោម ផៃឡាង (13-VSS-00358)។

[333] សូមមើល មូលដ្ឋាន ៣ ខាងលើ ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន (12-VSS-00582)។

[334] សូមមើល មូលដ្ឋាន ៤ ខាងលើ ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទូន ប្រុញ (11-VSS-00337) ឈុន សាម៉ន (12-VSS-00582) ជិន សាវ៉ៃ (13-VSS-00073) និង ស្ដើង មាច (13-VSS-00429)។

[335] ចៅក្រមអន្តរជាតិរំឭកថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ៤ នាក់ (13-VSS-00073, 11-VSS-00337; 12-VSS-00582; និង 13-VSS-00358) ដែលគួរត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានដាក់ជូននៅក្នុងមូលដ្ឋានជាច្រើននៃបណ្ដឹងឧទ្ធរណ៍ ហើយត្រូវបានអនុម័តទទួលយកនៅក្នុងមូលដ្ឋាននីមួយៗ។

[336] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384)។

01678860



ទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានសិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីនៅពេលខាងមុខប្រឆាំងនឹង យឹម ទិត្យ[337]។

**រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១**

**ចៅក្រម Olivier BEAUVALLET** **ចៅក្រម Kang Jin BAIK**

---

[337] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ចៅក្រមអន្តរជាតិ) (ឯកសារ D384)។